# ការស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ

## អ្នកដើរតាមព្រះយេស៊ូ ការអភិវឌ្ឍសហគមន៍
## និងសហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់



សៀវភៅសម្រាប់សិក្ខាកាម

# ការស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ

អ្នកដើរតាមព្រះយេស៊ូ ការអភិវឌ្ឍសហគមន៍
និងសហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់

សៀវភៅសម្រាប់សិក្ខាកាម

Khmer

# ការណែនាំ និងគោលការណ៍

**តើខ្ញុំអាចរំពឹងអ្វីខ្លះពីវគ្គសិក្សា *ការស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ*?**

យើងរង់ចាំឱ្យព្រះអង្គទទួលការលើកតម្កើនៈ នៅក្នុងជីវិតរបស់យើង ទោះបីជាអ្នកដែលមិនស្គាល់ព្រះអង្គក៏ដោយ សូមឱ្យសន្តិករទាំងអស់នៅលើផែនដីស្រែកសរសើរតម្កើនព្រះអង្គ (វិវរណៈ ៥:១៣)។

យើងតែងតែអធិស្ឋានទៅកាន់ព្រះបិតាដែលគង់នៅស្ថានសួគ៌ថា “សូមឱ្យព្រះរាជ្យព្រះអង្គបានមកដល់លើផែនដីដូចនៅស្ថានសួគ៌ដែរ”។

តើយើងអាចធ្វើឱ្យពាក្យអធិស្ឋានរបស់យើងបានសម្រេចដោយរបៀបណា? តើអ្នកផ្សាយដំណឹងល្អមានលក្ខណៈបែបណា ហើយថាតើពួកគេធ្វើអ្វីខ្លះ គឺពួកគេដើរប្រកាសថាព្រះជាម្ចាស់សោយរាជ្យមែនទេ (អេសាយ ៥២: ៧)?

**ការស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ** គឺត្រូវបានបង្កើតឡើងលើគោលការណ៍ទាំងដប់នៅក្នុងសៀវភៅ *បេសកកម្មគ្រប់ជ្រុងជ្រោយ*។ *អ្នកដើរតាមព្រះយេស៊ូវ ការអភិវឌ្ឍសហគមន៍ និងសហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់* (Regnum ២០២០)។ គោលការណ៍ទាំងនោះគឺដកស្រង់ចេញពីអ្នកអភិវឌ្ឍន៍សហគមន៍ដែលមានបទពិសោធន៍ជាមួយនឹងអង្គការ OM ជាមួយនឹងសិក្ខាកាមមកពីមណ្ឌល Oxford សម្រាប់ការសិក្សាពីបេសកម្ម (Oxford Centre for Mission Studies) សកលវិទ្យាល័យគ្រិស្តបរិស័ទគ្រប់ជាតិសាសន៍ និងស្ថាប័នពីរផ្សេងទៀត។

ចាប់ផ្តើមជាមួយនឹងព្រះរាជ្យ និងរបៀបចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ គោលការណ៍នឹងស្របទៅតាមប្រធានបទនៃការថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ តាមរយៈបេសកម្មដំណឹងល្អ និងការអភិវឌ្ឍសហគមន៍។ ការពិភាក្សាអំពីសង្គ្រាមខាងវិញ្ញាណ បន្ទាប់មកនឹងភ្ជាប់ជាមួយនឹងការខ្វល់ខ្វាយពីស្នាព្រះហស្ត និងតម្រូវការក្នុងការមានឆន្ទៈនៅក្នុងបេសកកម្មគ្រប់ជ្រុងជ្រោយរបស់យើង។ តម្រូវការក្នុងការធ្វើឱ្យបានល្អប្រសើរនៅក្នុងការអភិវឌ្ឍសហគមន៍របស់យើង គឺមានគោលការណ៍មួយចំនួនដែលនិយាយអំពីការដាំសហគមន៍អ្នកដើរតាមព្រះយេស៊ូវថ្មី បន្ទាប់មកនឹងបញ្ចប់ជាមួយនឹងការឆ្លុះបញ្ចាំងនៅលើមូលហេតុដែលយើងតែងតែមើលរំលងសហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់។

វគ្គសិក្សានេះ គឺត្រូវបានបង្កើតឡើងដើម្បីបង្រៀនក្នុងរយៈពេល ១១ សប្តាហ៍ មេរៀនមួយគឺសម្រាប់គោលការណ៍មួយ បន្ទាប់មកយើងនឹងមានវគ្គសង្ខេបមួយដើម្បីគិតគូរពិចារណាទៅលើអ្វីដែលយើងបានសិក្សាកន្លងមក អ្វីដែលយើងចង់បន្តសិក្សារៀនសូត្រ និងរបៀបដែលយើងចង់បន្តទៅមុខ។ នៅក្នុងវគ្គសិក្សាប្រចាំសប្តាហ៍បានណែនាំថាគួរតែចំណាយពេល ៧៥ នាទី ប៉ុន្តែយើងសុំណែនាំអ្នកដោយរៀបចំពេល ៩០ នាទី ដើម្បីឱ្យអ្នកមានពេលគ្រប់គ្រាន់ដើម្បីស្វាគមន៍ និយាយគ្នាលេង និងអធិស្ឋានជាមួយគ្នា។

គ្រូបង្គោលត្រូវចាប់ផ្តើមវគ្គសិក្សា ការសិក្សានឹងទទួលបានតាមរយៈការឆ្លុះបញ្ចាំង និងការពិភាក្សា (មិនមែនចេញមកពីការបង្រៀននោះទេ)។ សៀវភៅ *បេសកកម្មគ្រប់ជ្រុងជ្រោយ* គឺជាធនធានដ៏ប្រសើរ យើងសុំលើកទឹកចិត្តសិស្សឱ្យមានសៀវភៅ និងអានវាតាមតែអាចធ្វើទៅបាន។ យ៉ាងណាមិញ សិក្ខាកាមអាចបញ្ចប់ការសិក្សានេះបាន ព្រមទាំងអាចទទួលបានអត្ថប្រយោជន៍ជាច្រើនបាន ទោះបីមិនបានអានសៀវភៅក៏ដោយ។

នៅពេលដែលយើង *សិក្សាស្វែងយល់ពីបេសកកម្មគ្រប់ជ្រុងជ្រោយ* ជាមួយគ្នា យើងសង្ឃឹមថា អ្នកនឹងទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅជាងមុនអំពីអត្ថន័យនៃពាក្យថាមនុស្សពេញលក្ខណៈ។ ដំណឹងល្អមិនមែនគ្រាន់តែជាការប្រាប់មនុស្សអំពីដំណឹងល្អ ឬធ្វើកិច្ចការល្អនោះទេ។ ការបង្ហាញ និងការពន្យល់ដំណឹងល្អ មិនអាចធ្វើដាច់ដោយឡែកពីគ្នា ឬត្រូវដាក់ចូលក្នុងប្រភេទអាទិភាពនោះទេ។ មនុស្សដែលយើងឈោងចាប់ គឺជាមនុស្សពេញលក្ខណៈ ពួកគេមិនមែនជារូបកាយដែលត្រូវការការព្យាបាល ឬព្រលឹងដែលត្រូវការការសង្គ្រោះនោះទេ។ តាមរយៈគំរូរបស់ព្រះយេស៊ូវ យើងចូលមកកាន់សហគមន៍ក្នុងនាមជាមនុស្សពេញលក្ខណៈ បើមិនដូច្នោះទេ យើងមិនចាំបាច់មកនោះទេ។

យើងនឹងសិក្សាស្វែងយល់ជាមួយគ្នា!

ការសិក្សាស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ៖ សៀវភៅណែនាំគ្រូបង្គោល © 2025 ដោយលោក David Greenlee និងក្រុមគឺត្រូវបានផ្តល់លិខិតបញ្ជាក់ការអនុញ្ញាតក្រោម Creative Commons Attribution-NonCommercial-NoDerivatives 4.0 International. ដើម្បីទទួលបានច្បាប់ចម្លងពេញសិទ្ធិ សូមចូលទៅកាន់ https://creativecommons.org/licenses/by-nc-nd/4.0/

Cover photograph ©Quang Nguyen Minh from pixabay.com. Other photographs courtesy of OM International by Justin Lovett, Alex Coleman, Rebecca Rempel and Garrett Nasrallah.



# គោលការណ៍ទីមួយៈ
# ការស្វែងយល់អំពីព្រះរាជ្យព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះ

*សូមបើកឯកសារអំពីគោលការណ៍ទាំង ១០ បើអាច*

គោលបំណងនៃការពិភាក្សាៈ

1. មនុស្សដែលនៅក្រុមរបស់យើងនឹងទទួលស្គាល់អំពីរបៀបដែលព្រះយេស៊ូបង្ហាញ និងពន្យល់មនុស្សដើម្បីជួយពួកគេឱ្យយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។
2. មនុស្សដែលនៅក្រុមរបស់យើងនឹងចាប់ផ្តើមគិតថា ពួកគេអាចផ្លាស់ប្តូរសហគមន៍ពួកគេបានតាមរយៈការយល់ដឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។

## សេចក្តីផ្តើមការសិក្សាអំពី *ការស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ*

1. សូមអាន "អ្វីដែលត្រូវរំពឹងទុកពីការសិក្សានេះ" នៅទំព័រមុន។

## ព្រះរាជ្យរបស់ព្រះជាម្ចាស់ (១៥-២០ នាទី)

2. សូមចាប់ផ្តើមតាមរយៈការមើលទៅកាន់គោលការណ៍ទីមួយ។

គោលការណ៍ទីមួយ ការសង្ខេបៈ "ការស្វែងយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះ"

3. ការស្វែងយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះ ដូចនេះសូមមើលថាតើព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាអ្វី។ រាជាណាចក្រអាចមានន័យថាជាកន្លែងដែលព្រះរាជាសោយរាជ្យ។ ប្រសិនបើមានរាជាណាចក្រ មានន័យថាក៏មានព្រះរាជាដែរ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺនៅលើស្តេចរបស់យើង។

4. តើយើងអាចស្វែងយល់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់បានយ៉ាងដូចម្តេច? កន្លែងដែលធ្វើឱ្យយើងយល់ អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់គឺតាមរយៈការសម្លឹងមើលទៅកាន់ព្រះយេស៊ូ ទ្រង់គឺជាស្តេច!

5. យើងចង់ផ្តោតលើរបៀបពីរដែលព្រះយេស៊ូជួយយើងឱ្យយល់អំពីព្រះរាជ្យ – តាមរយៈការបង្ហាញ និងការពន្យល់។

   ក. ការបង្ហាញៈ តាមរយៈការបង្ហាញ មានន័យថា *សកម្មភាព* កិច្ចដែលព្រះយេស៊ូបានធ្វើដែលបង្ហាញយើងថាតើព្រះរាជ្យរបស់ព្រះជាម្ចាស់មានលក្ខណៈបែបណា។

   ខ. ការពន្យល់ៈ ការពន្យល់គឺជាពាក្យដែលព្រះយេស៊ូមានព្រះបន្ទូលដើម្បីជួយយើងឱ្យយល់អំពីព្រះរាជ្យ។ ព្រះយេស៊ូជួយយើងឱ្យយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ តាមរយៈការប្រាប់រឿងទៅកាន់បណ្តាជន បន្ទាប់មក ទ្រង់ក៏ពន្យល់ពួកសាវ័ក។ ព្រះយេស៊ូពន្យល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរយៈការបង្រៀន តាមរយៈការសួរ និងការឆ្លើយសំណួរ។

6. សូមឱ្យយើងមើលទៅកាន់ចំណុចទាំងពីរនេះឱ្យកាន់តែលម្អិត ចាប់ផ្តើមពីការបង្ហាញ។ ខាងក្រោមនេះគឺជាឃ្លាមួយចំនួនអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយយោងទៅតាមសកម្មភាពរបស់ព្រះយេស៊ូ។

   ក. ព្រះរាជ្យព្រះជាម្ចាស់គឺជាកន្លែងដែលមនុស្សឈឺបានជា។

   ខ. ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាកន្លែងដែលមនុស្សស្រេកឃ្លានបានឆ្អែត។

គ. ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាកន្លែងដែលយើងយកឈ្នះលើអំណាចនៃភាពងងឹត។

ឃ. ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាកន្លែងដែលមនុស្សគ្រប់ៗរូបមានតម្លៃ។

ង. ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាកន្លែងដែលមនុស្សគ្រប់ៗរូបទទួលបានការស្វាគមន៍។

7. បន្ទាប់មក សូមមើលអំពីការពន្យល់។ មានកន្លែងមួយចំនួនដែលខគម្ពីរបានចែងថា ព្រះយេស៊ូមានព្រះ បន្ទូលថា "ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបដូចជា..." បន្ទាប់មកទ្រង់បានប្រាប់រឿងមួយដើម្បីជួយយើងឱ្យយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ តើមានរឿងអ្វីខ្លះដែលព្រះយេស៊ូបានប្រាប់បន្ទាប់ពីទ្រង់មានព្រះបន្ទូលថា "ព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រៀបដូចជា..."?

✓
✓
✓
✓

8. តើមានរបៀបអ្វីខ្លះដែលព្រះយេស៊ូបានមានព្រះបន្ទូលដើម្បីពន្យល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់?

ចម្លើយរបស់អ្នក

✓
✓
✓
✓

9. តាមអ្វីដែលអ្នកបានឃើញ តើការបង្ហាញ និងការពន្យល់មានទំនាក់ទំនងគ្នាដូចម្ដេចអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់?

ចម្លើយរបស់អ្នក

✓
✓
✓
✓

10. ជីវិតរបស់ព្រះយេស៊ូគឺជាឧទាហរណ៍អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ វាគឺជាឧទាហរណ៍ដើម្បីឱ្យយល់អំពី *ការបង្ហាញ និងការពន្យល់* អំពី ព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅកាន់អស់អ្នកដែលនៅជុំវិញយើង។ តើការដើរតាមគំរូព្រះយេស៊ូមានលក្ខណៈដូចម្ដេច?

ចម្លើយរបស់អ្នក

✓
✓
✓
✓

## រឿងពីប្រទេសឥណ្ឌា (១៥-២០ នាទី)

11. គោះ យើងមើលអំពីរឿងពីប្រទេសឥណ្ឌា។

*កាលពីដប់ឆ្នាំមុន ខ្ញុំបានទៅលេងភូមិមួយពេលដែលកំពុងតែធ្វើការជាមួយអង្គការផ្សាយដំណឹងល្អអន្តរជាតិ និងចលនាបេសកម្មដ៏ល្បីមួយ ភូមិនោះគឺជាភូមិក្រីក្រ ខ្សត់ខ្សោយ គឺជាភូមិកាន់សាសនាហិណ្ឌូ។*

*អង្គការបានបង្កើតកម្មវិធីក្រុមជួយខ្លួនឯងនៅក្នុងភូមិនោះ ដែលមានការសម្របសម្រួលពីសមាជិកក្រុមជំនុំ ដែលបានទទួលការបណ្តុះបណ្តាលមូលដ្ឋានក្នុងការបង្កើតក្រុមស្ត្រីជួយខ្លួនឯង។ ពួកគេគឺជាអ្នករៀបចំសហគមន៍ (FOs)។ ក្រុមនេះមានគោលបំណងដើម្បីបង្កើតក្រុមសន្សំខ្នាតតូច និងក្រុមកម្ចី ផ្តល់ការបណ្តុះបណ្តាលអំពីជំនាញមុខរបរចិញ្ចឹមជីវិត និងលើកកម្ពស់សកម្មភាពនានាដើម្បីដោះស្រាយបញ្ហាសង្គម សេដ្ឋកិច្ច ព្រលឹងវិញ្ញាណ និងបរិស្ថាននៅក្នុងសហគមន៍ដែលពួកគេកំពុងជួបប្រទះ។ នៅក្នុងភូមិនោះ*

*ក្រុមរៀបចំសហគមន៍កំពុងតែមានលទ្ធផលជាមួយក្រុមដែលទើបតែបង្កើតថ្មីមួយ ដែលបានជួបជាមួយម្ចាស់ដីមិនស្មោះត្រង់ម្នាក់ដែលចង់លក់ដីដាំដំណាំក្នុងភូមិទៅឱ្យម្ចាស់ចំការម្នាក់។ ការលក់ដីនេះ មិនត្រឹមតែធ្វើឱ្យអ្នកភូមិបាត់បង់ដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងបង្កើតបញ្ហាបរិស្ថានផ្សេងៗដែលបណ្តាលមកពីការខ្វះទឹក ការសាយភាយសារធាតុគីមី និងការសឹកដីផងដែរ។ ម្ចាស់ដីមានបំណងចង់បំបែកអ្នកភូមិតាមរយៈសំណងមិនសមរម្យ។ ក្រុមជួយខ្លួនឯងបានបង្កើតការសន្សំ និងកម្ចីដោយជោគជ័យ មានស្ត្រីមួយចំនួនបានចាប់ផ្តើមអាជីវកម្មខ្នាតតូច ហើយខ្លះទៀតបានជួយស្វាមីរបស់ខ្លួនក្នុងការបង្កើតអាជីវកម្មខ្នាតតូចផងដែរ។ អ្នករៀបចំសហគមន៍បានជួយស្ត្រីបង្កើតប្រាក់សន្សំខ្នាតតូចដើម្បីជួយផ្គត់ផ្គង់ការចំណាយសម្រាប់ពិធីបុណ្យសាសនារបស់ពួកគេ។  តាមរយៈក្រុមសន្សំនេះ ទំនាក់ទំនងរបស់ស្ត្រីៗត្រូវបានបង្កើតឡើងយ៉ាងស្អិតរមួត។*

*ថ្ងៃមួយ មានស្ត្រីម្នាក់ពីក្នុងក្រុមបានសួរអ្នករៀបចំសហគមន៍ថាតើគាត់បានរៀបការហើយឬនៅ។ គាត់បានឆ្លើយថាគាត់បានរៀបការរួចហើយ បន្ទាប់មកពួកគេក៏សួរថាហេតុអ្វីបានជាមិនពាក់គ្រឿងអលង្ការតាមប្រពៃណីសាសនាហិណ្ឌូ។ គាត់បានពន្យល់ថា ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូ គាត់មិនចាំបាច់ពាក់ទេ។ ចម្លើយនេះពិតជាបានធ្វើឱ្យពួកគេចាប់អារម្មណ៍ខ្លាំងណាស់។ ពួកគេក៏បានសួរអំពីជំនឿរបស់គាត់ និងចង់អានព្រះគម្ពីរដ៏វិសុទ្ធ។*

*នៅពេលដែលគាត់ទៅជួបពួកគេលើកក្រោយ គាត់បាននាំព្រះគម្ពីរ គាត់ក៏អានព្រះគម្ពីរ។ ពេលនោះ មានស្ត្រីពីរនាក់ដែលបានថ្វាយខ្លួនទៅកាន់ព្រះយេស៊ូ។ តាមជំនឿរបស់សាសនាហិណ្ឌូ នៅក្នុងភូមិនោះ ស្ត្រីដែលបានថ្វាយខ្លួនទៅព្រះយេស៊ូ ត្រូវបានចាត់ទុកថាមិនមែនជាគ្នារបស់ “ពួកគេ” ទៀតទេ ហើយទោះបីជាពួកគេគឺជាសមាជិកក្រុមក៏ដោយ ក៏នៅតែមានការបៀតបៀនដែរ។*

*ថ្ងៃមួយ កូនរបស់អ្នកជឿម្នាក់បានឈឺធ្ងន់។ គ្រូពេទ្យបានប្រាប់ថាបើមិនបញ្ចូលឈាមទេ កូននេះនឹងស្លាប់។ ដោយសារតែពួកគេជឿលើព្រះយេស៊ូ អ្នកភូមិមិនហ៊ានផ្តល់ឈាមដល់ពួកគេទេ។ ពួកគេក៏បានទូរសព្ទទៅកាន់អ្នករៀបចំសហគមន៍ ហើយគាត់បានផ្តល់ឈាម និងបានអធិស្ឋានសម្រាប់ការព្យាបាល។ ពេលនោះ កុមារនោះក៏បានជា។*

*តាមរយៈការអស្ចារ្យ និងសេចក្តីស្រឡាញ់របស់អ្នករៀបចំសហគមន៍នេះ សហគមន៍កាន់តែចង់ស្គាល់ព្រះយេស៊ូ ហើយសព្វថ្ងៃនេះមាន VCJF នៅក្នុងសហគមន៍ពួកគេថែមទៀតផង។*

12. តាមរយៈការបង្ហាញ និងការពន្យល់ តើយើងអាចមើលឃើញពីព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរបៀបណាខ្លះ?

ចម្លើយរបស់អ្នក

✓

✓

✓

13. យើងមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរយៈកិច្ចការអស្ចារ្យជាច្រើនតាមរយៈម្ចាស់ដី ក្មេងឈើ និងតាមរយៈការបង្រៀនដល់អ្នកជឿលើសាសនាហិណ្ឌូដែលបានរំដោះពួកគេ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺបានបង្ហាញតាមរយៈការព្យាបាល ការសង្គ្រោះ ការអស្ចារ្យ ជីវិតដែលបានផ្លាស់ប្តូរ និងការខ្វល់ខ្វាយពីពួកគេជារៀងរាល់ថ្ងៃ។ នៅក្នុងសៀវភៅដំណឹងល្អ និងសៀវភៅកិច្ចការ យើងបានឃើញពួកសាវ័កបានអនុវត្តគោលការណ៍ទាំងនេះ ហើយគ្រីស្ទបរិស័ទជាច្រើននាក់ទៀតក៏បានអនុវត្តបែបនេះដែរ។ តើយើងរំពឹងថាព្រះជាម្ចាស់ នឹងធ្វើកិច្ចការ ទាំងនេះមែនទេ? បើមិនដូច្នេះទេ យើងប្រហែលជាមិនស្វែងរក ឬអធិដ្ឋានសម្រាប់បែបនេះទេ ហើយយើងក៏មិនងាយទទួលបានបទពិសោធន៍នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរ។

14. គ្រោះថ្នាក់នៃការអានរឿងខ្លីបែបនេះនោះគឺ មើលទៅរឿងនេះគឺជារឿងខ្លី ប៉ុន្តែតាមពិត រឿងនេះបានកើត ឡើងដោយត្រូវការរយៈពេលពីរ ឬបីឆ្នាំឯណោះ។ នៅពេលដែលយើងចង់ឱ្យព្រះរាជ្យរបស់ព្រះជាម្ចាស់មកក្នុងសហគមន៍របស់យើង គ្មានផ្លូវកាត់នោះទេ។ វាទាមទារពេលវេលា។ ចំណុចសំខាន់ដែល ត្រូវ ចងចាំនោះគឺ យើងមិនត្រូវបាក់ទឹកចិត្តឡើយ។

## ការអនុវត្ត (១៥-២០ នាទី)

15. គោលការណ៍ទីមួយ “ការស្វែងយល់អំពីព្រះរាជ្យព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះ”។

ក. ក្នុងនាមជាក្រុម

តើការយល់ដឹងអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់អាចជួយបង្កើតរបៀបដែលយើងមានទំនាក់ទំនងជាមួយសហគមន៍ដោយរបៀបណា?

ខ. តើពេលណាដែលអ្នកទន្ទឹងរង់ចាំចង់ឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ចូលមកផ្លាស់ប្រែ?

16. តើការពិភាក្សាអ្វីនៅថ្ងៃនេះដែលមានន័យសម្រាប់អ្នក? ហេតុអ្វី?

17. ក្នុងសប្ដាហ៍នេះ សូមចំណាយពេលផ្ទាល់ខ្លួនខ្លះដើម្បីឆ្លុះបញ្ចាំង និងឆ្លើយសំណួរទាំងនេះ។ អ្នកនឹងមានឱកាសចែករំលែកអ្វីដែលអ្នកបានសរសេរនៅសប្ដាហ៍ក្រោយ។

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

ទ្រឹស្ដីវិទូអំពីព្រះរាជ្យព្រះជាម្ចាស់ និងអ្នកគិតគូអំពីការអភិវឌ្ឍ ប្រើប្រាស់ពាក្យថា *ហ្សាឡូម (shalom)* ឬ សេចក្ដីសុខសាន្តរបស់ព្រះជាម្ចាស់។ នេះគឺជាពាក្យសម្រាប់ផ្សះផ្សារ និងស្ដារទំនាក់ទំនងឡើងវិញ។ លោក Bryant Meyers បាននិយាយថា៖

> *គោលបំណងរបស់ព្រះជាម្ចាស់គឺចង់ស្ដារយើង និងស្នាព្រះហស្តរបស់ព្រះអង្គឱ្យមកកាន់គោលបំណងដើមរបស់ព្រះអង្គវិញ គឺជាអ្នកតំណាង និងជាអ្នកមើលការខុសត្រូវរបស់ព្រះអង្គ រស់នៅជាមួយគ្នាប្រកបដោយយុត្តិធម៌ និងមានទំនាក់ទំនងដែលពេញទៅដោយសេចក្ដីសុខសាន្ត។ គោលបំណងនៃការផ្លាស់ប្ដូរ...គឺជាគោលបំណងសម្រាប់ទាំងសហគមន៍ និងអ្នកសម្របសម្រួលការអភិវឌ្ឍ។ (ការដើរជាមួយមនុស្សក្រីក្រ Orbis, ២០១១ ទំព័រទី ៣៣០)*

តើ *ហ្សាឡូម* នៃការព្យាបាល ការផ្លាស់ប្ដូរ និងការយកឈ្នះចូលមកក្នុងជីវិតរបស់យើងដោយរបៀបណា?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីមួយ *ស្នូរបន្ទាល់៖ អ្នកដើរតាមព្រះយេស៊ូ ការអភិវឌ្ឍសហគមន៍ និងសហគមន៍ដែលមិនទាន់ឮដំណឹងល្អ* (Regnum ២០២០)។



# គោលការណ៍ទីពីរៈ ការយល់ដឹងពីរបៀបដែលមនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ជួយយើងឱ្យចេះធ្វើពន្ធកិច្ច

គោលបំណងនៃការពិភាក្សាៈ
1. ក្រុមរបស់យើងនឹងកាន់តែយល់ច្បាស់ជាងមុននៅពេលដែលពួកគេសម្រេចចិត្តដើរតាមព្រះយេស៊ូសម្រាប់មនុស្សផ្សេងទៀត គឺត្រូវការពេលវេលា មិនមែនកើតឡើងភ្លាមៗនោះទេ។
2. ក្រុមរបស់យើងនឹងទទួលស្គាល់ថា កត្តាជំរុញចិត្តក្នុងការចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់គឺអាចនឹងខុសគ្នាទៅតាមមនុស្សផ្សេងៗគ្នា។
3. ក្រុមរបស់យើងនឹងទទួលបានការយល់ដឹងថ្មីពីសារៈសំខាន់នៃការផ្តល់សេរីភាពដល់មនុស្សក្នុងការទទួល ឬបដិសេធដំណឹងល្អ។

ការរំលឹក

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីមួយៈ ការស្វែងយល់អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះ។ ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវឆ្លើយសំណួរថាៈ "តើ ហ្សាឡូម នៃការព្យាបាល ការផ្លាស់ប្តូរ និងការយកឈ្នះចូលមកក្នុងជីវិតរបស់យើងដោយរបៀបណា?"

2. សូមចំណាយពេល ៣-៤ នាទីដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## តើមនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានដោយរបៀបណា (១០-១៥នាទី)

3. ថ្ងៃនេះ យើងនឹងសិក្សាអំពីគោលការណ៍ទីពីរ។

គោលការណ៍ទីពីរ ការសង្ខេបៈ
*"ការយល់ដឹងពីរបៀបដែលមនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ជួយយើងឱ្យចេះធ្វើពន្ធកិច្ច"*

4. តើមនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានដោយរបៀបណា? ពេលដែលយើងមើលទៅក្នុងសម្ពន្ធមេត្រីថ្មី យើងឃើញថាគ្មានចម្លើយសាមញ្ញនោះទេ។ មនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់តាមរបៀបផ្សេងៗគ្នា។

ក. សូមមើលពីគំរូរបស់លោកប៉ូល។ តើលោកប៉ូលមានជំនឿលើព្រះយេស៊ូដោយរបៀបណា?

ចម្លើយរបស់អ្នក
- ✓
- ✓
- ✓
- ✓

ខ. មនុស្សខ្លះ ឧ. លោកប៉ូល អាចចងចាំពីពេលដែលពួកគេទទួលបានជីវិតអស់កល្ប។

គ. ចុះសម្រាប់លោកពេត្រុស? តើដំណើរជំនឿរបស់គាត់មកលើព្រះយេស៊ូមានលក្ខណៈដូចម្តេច?

ចម្លើយរបស់អ្នក
- ✓
- ✓
- ✓

ឃ. ពេលដែលយើងគិតអំពីលោកពេត្រុស កាន់តែពិបាកនៅក្នុងការរំលឹកអំពីពេល ឬព្រឹត្តិការណ៍នៅពេលដែលគាត់មានជំនឿលើព្រះយេស៊ូ។
នេះគឺជារឿងពិតសម្រាប់មនុស្សជាច្រើន
ដំណើររបស់ពួកគេគឺជាដំណើរនៃការកែប្រែចិត្តគំនិតបន្តិចម្តងៗ។

5. ចុះអ្នកវិញ? តើអ្នកអាចនិយាយថាដំណើរនៃជំនឿរបស់អ្នកគឺជាព្រឹត្តិការណ៍ ឬគឺជាដំណើរនៃការកែប្រែចិត្តគំនិតបន្តិចម្តងៗ?

6. ចំណុចសំខាន់នោះគឺ

មិនមែនគ្រប់ៗគ្នាសុទ្ធតែមានដំណើរដូចគ្នាក្នុងការចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់នោះទេ។ ពេលវេលានៃដំណើររបស់យើងគឺខុសៗគ្នា។

## កត្តាជំរុញចិត្ត - អ្វីដែលធ្វើឱ្យយើងចង់ចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់? (១០-១៥ នាទី)

7. មិនសូវខុសគ្នានោះទេ កត្តាជំរុញចិត្តរបស់យើងក្នុងការមានជំនឿលើព្រះយេស៊ូនោះ ប្រហែលជាខុសគ្នាដែរ។

8. សូមគិតអំពីដំណើរនៃជំនឿផ្ទាល់ខ្លួនរបស់អ្នក។ តើអ្វីដែលទាក់ទាញអ្នកឱ្យមកជឿលើដំណឹងល្អ? តើការល្អអ្វីពីដំណឹងល្អ សម្រាប់អ្នក?

9. នៅក្នុងខគម្ពីរ យើងឃើញថាមនុស្សចូលមកកាន់ព្រះយេស៊ូដោយសារមូលហេតុខុសៗគ្នា។ សូមគិតអំពីឧទាហរណ៍ចេញពីដំណឹងល្អ។ តើមនុស្សចូលមកកាន់ព្រះយេស៊ូដោយសារមូលហេតុអ្វីខ្លះ?

ចម្លើយរបស់អ្នក
✓
✓
✓
✓

10. មនុស្សជាច្រើនបានចូលមកកាន់ព្រះយេស៊ូ ដោយសារទ្រង់អាចបំពេញតាមសេចក្តីត្រូវការភ្លាមៗរបស់ពួកគេបាន។ ទ្រង់បានបំពេញតាមសេចក្តីត្រូវការរបស់ពួកគេដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់។ យើងអាចនិយាយបានថា ទ្រង់ឱ្យពួកគេមានសេរីភាពដើម្បីទទួល ឬបដិសេធដំណឹងល្អ ព្រមទាំងឱ្យពួកគេមានពេលដើម្បីសម្រេចចិត្ត។

## សេរីភាពក្នុងការទទួល ឬបដិសេធដំណឹងល្អ (៥-១០ នាទី)

11. ខ្ញុំឆ្ងល់ថា តើយើងតែងតែយល់ពីភាពសំខាន់ក្នុងការផ្តល់ឱ្យពួកគេមានសេរីភាពដើម្បីទទួល ឬបដិសេធដំណឹងល្អដែរឬទេ។

*ជាច្រើនឆ្នាំបន្ទាប់ពីចារ៉ារ៉ា (បានផ្លាស់ប្តូរឈ្មោះ) ចាប់ផ្តើមមកលេងក្រុមជំនុំរបស់លោកដាវីដ នៅក្នុងប្រទេសស្វីស។ ចារ៉ារ៉ា គឺជាជនភៀសខ្លួនឥស្លាមដែលបានមកដល់អាហ្វ្រិកខាងលិច។ មនុស្សជាច្រើននៅក្នុងក្រុមជំនុំបានស្វាគមន៍គាត់យ៉ាងកក់ក្តៅ ផ្តល់អំណោយដូចជាខោអាវក្រាស់ៗ ដើម្បីឱ្យគាត់អាចសម្របខ្លួននឹងអាកាសធាតុត្រជាក់បាន។ ប៉ុន្មានសប្តាហ៍ក្រោយមក ចារ៉ារ៉ា បានប្រាប់សមាជិកក្រុមជំនុំថាគាត់បានទុកចិត្តព្រះយេស៊ូ និងចង់ទទួលពិធីជ្រមុជទឹក។*

*ហើយភ្លាមៗនោះ ចារ៉ារ៉ាក៏បានបាត់ខ្លួន។ គាត់ឈប់មកក្រុមជំនុំទៀតហើយ។ គាត់មិនលើកទូរសព្ទអ្នកដែលបានទូរសព្ទទៅគាត់ ហើយព្យាយាមគេចពីសមាជិកក្រុមជំនុំ។ ក្រោយមក ដាវីដ បានដឹងថាចារ៉ារ៉ាបានរស់នៅក្នុងជីវិតដ៏ល្អមួយក្នុងនាមជាអ្នកស្វែងរកសិទ្ធិជ្រកកោន - ជាអ្នកដែលរដ្ឋាភិបាល*

*ស្វីសបានផ្តល់សិទ្ធិរស់នៅ។*

*មនុស្សជាច្រើននៅក្នុងក្រុមជំនុំមានការមន្ទិលសង្ស័យថាតើចារ៉ារ៉ាបានធ្វើឱ្យខូចដល់ប្រព័ន្ធរដ្ឋាភិបាលដែរឬទេ។ តើគាត់ធ្វើពុតជាជឿដើម្បីកេងចំណេញលើការអាណិតអាសូររបស់ពួកគេមែនដែរឬទេ? ប៉ុន្តែដាវីដចង់បានការពន្យល់ច្បាស់ជាងនេះ។*

*មិនខុសពីជនភៀសខ្លួនផ្សេងៗទៀតនៅក្នុងប្រទេសស្វីសនោះទេ រដ្ឋាភិបាលបានផ្តល់ជីវិតសាមញ្ញមួយដល់ជនភៀសខ្លួនទាំងអស់។ ប៉ុន្តែគាត់នៅតែមានអារម្មណ៍ថាមិនទាន់សុំជាមួយនឹងប្រទេសថ្មីនេះ។ គាត់តែងតែមានអារម្មណ៍ថាច្របូកច្របល់ ឯកា និងគ្មានភាពកក់ក្តៅ។ មនុស្សដែលមកពីក្រុមជំនុំបានស្វាគមន៍គាត់ និងបានជួយគាត់កុំឱ្យមានអារម្មណ៍ឯកា។ ពួកគេបានផ្តល់តាមសេចក្តីត្រូវការរបស់គាត់ ហើយគាត់មានអារម្មណ៍ថាគាត់ជំពាក់ពួកគេ។ នៅពេលដែលមនុស្សសុំឱ្យគាត់ដើរតាមព្រះយេស៊ូ តើឱ្យគាត់បដិសេធបានយ៉ាងដូចម្តេច គាត់ត្រូវតែធ្វើតាមមែនទេ?*

*មនុស្សនៅក្នុងក្រុមជំនុំមានលុយ អំណាច និងមានឥទ្ធិពល ការនិយាយថា “ទេ” ទៅកាន់ពួកគេ គឺដូចជាមិនឱ្យតម្លៃពួកគេអញ្ចឹង។ ដូច្នេះ ចារ៉ារ៉ា បាននិយាយថាគាត់នឹងដើរតាមព្រះយេស៊ូ។*

*ចិត្តរបស់គាត់មិនទាន់បានត្រៀមរួចរាល់នៅឡើយទេ ហើយគាត់ដឹងថាបើគាត់មិនជឿដោយស្មោះចេញពីចិត្តនោះទេ មិត្តថ្មីៗរបស់គាត់នឹងខកចិត្ត។ អ្វីដែលគាត់អាចធ្វើបានគឺត្រូវគេចចេញពីក្រុមជំនុំ។*

ក. តើចារ៉ារ៉ាមានសេរីភាពប៉ុណ្ណាដើម្បីទទួល ឬបដិសេធដំណឹងល្អ?

ចម្លើយរបស់អ្នក

✓
✓
✓
✓

ខ. ហេតុអ្វីបានជាអ្នកគិតថាវាគឺជារឿងសំខាន់ក្នុងការមានសេរីភាពដើម្បីទទួល ឬបដិសេធដំណឹងល្អ?

ចម្លើយរបស់អ្នក

✓

✓

✓

## ការអនុវត្ត (១០-១៥នាទី)

12. តើការយល់អំពីរបៀបដែលមនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់អាចជួយក្រុមរបស់យើងឱ្យធ្វើព័ន្ធកិច្ចបាន?

13. ក្នុងសប្តាហ៍នេះ សូមចំណាយពេលផ្ទាល់ខ្លួនខ្លះដើម្បីឆ្លុះបញ្ចាំង និងឆ្លើយសំណួរខាងក្រោមនេះ។ អ្នកនឹងមានឱកាសចែករំលែកអ្វីដែលអ្នកបានសរសេរ។

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

នៅពេលដែលយើងជឿលើព្រះយេស៊ូគ្រិស្ត តើមនុស្សបានធ្វើ ឬនិយាយអ្វី ដែលបានជួយអ្នក? តើពួកគេបានធ្វើអ្វីដែលបង្កើតទៅជារនាំង ឬធ្វើឱ្យអ្នកយល់ខុសពីដំណឹងល្អ? តើកិច្ចការដែលអ្នក និងក្រុមរបស់អ្នកបានធ្វើ ដើម្បីចង់ឱ្យមនុស្សមកស្គាល់ព្រះយេស៊ូ? តាមរយៈការពិភាក្សានេះ តើវាបានជះឥទ្ធិពលដល់យុទ្ធសាស្ត្ររបស់អ្នកនៅពេលអនាគតដូចម្តេចខ្លះ?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីពីរ *បេសកកម្មគ្រប់ជ្រុងជ្រោយ*



# គោលការណ៍ទីបី៖
# ដំណឹងល្អមានឥទ្ធិពលគ្រប់លក្ខណៈរបស់មនុស្សទាំងអស់ និងគ្រប់បរិបទទាំងអស់

គោលបំណងនៃការពិភាក្សា៖

1. ក្រុមរបស់យើងនឹងកាន់តែយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ពីលក្ខណៈរបស់មនុស្សទាំងអស់ និងគ្រប់បរិបទទាំងអស់
2. ក្រុមរបស់យើងនឹងកាន់តែយល់ពីបេសកម្មគ្រប់ជ្រុងជ្រោយ និងការអភិវឌ្ឍសហគមន៍ដោះស្រាយបញ្ហារបស់បុគ្គល និងលក្ខណៈរបស់បុគ្គលទាំងមូល។

## ការរំលឹក (៥ នាទី)

1. សប្ដាហ៍មុន យើងបានមើលពីគោលការណ៍ទីពីរ៖ ការយល់ដឹងពីរបៀបដែលមនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ជួយយើងឱ្យចេះធ្វើព័ន្ធកិច្ច។ ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវគិតទៅលើ៖

    នៅពេលដែលយើងជឿលើព្រះយេស៊ូគ្រិស្ត តើមនុស្សបានធ្វើ ឬនិយាយអ្វីដែលបានជួយអ្នក? តើពួកគេបានធ្វើអ្វីដែលបង្កើតទៅជារនាំង ឬធ្វើឱ្យអ្នកយល់ខុសពីដំណឹងល្អ?

    តើកិច្ចការដែលអ្នក និងក្រុមរបស់អ្នកបានធ្វើដើម្បីចង់ឱ្យមនុស្សមកស្គាល់ព្រះយេស៊ូ? តាមរយៈការពិភាក្សានេះ តើវាបានជះឥទ្ធិពលដល់យុទ្ធសាស្ត្ររបស់អ្នកនៅពេលអនាគតដូចម្ដេចខ្លះ?

2. សូមចំណាយពេល ៣-៤ នាទីដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## លក្ខណៈរបស់មនុស្សទាំងអស់ (៥ នាទី)

3. ថ្ងៃនេះ យើងនឹងសិក្សាអំពីគោលការណ៍ទីបី។

គោលការណ៍ទីបី ការសង្ខេប៖<br>*‘ដំណឹងល្អមានឥទ្ធិពលគ្រប់លក្ខណៈរបស់មនុស្សទាំងអស់ និងគ្រប់បរិបទទាំងអស់របស់មនុស្ស។’*

4. ចំណុចស្នូលរបស់គោលការណ៍នេះគឺ ព្រះជាម្ចាស់ស្រឡាញ់យើងដោយសារយើងគឺជាស្នាព្រះហស្តរបស់ព្រះអង្គ ទ្រង់បានបង្កើតយើងមកឱ្យពេញលក្ខណៈ

5. តើយើងអាចឱ្យនិយមន័យនៃពាក្យ “លក្ខណៈទាំងអស់របស់មនុស្ស” បានយ៉ាងដូចម្ដេច?

    ចម្លើយរបស់អ្នក

    ✓
    ✓
    ✓
    ✓

    ព្រះជាម្ចាស់បានបង្កើតយើងឱ្យមានរូបកាយ និងព្រលឹង។ នៅពេលដែលយើងនិយាយលក្ខណៈទាំងអស់របស់មនុស្ស យើងចង់សំដៅទៅលើមនុស្សម្នាក់ដែលមានសមាសធាតុច្រើនជាងមួយ។ ព្រះជាម្ចាស់ខ្វល់ខ្វាយពីរូបកាយ និងព្រលឹងរបស់យើង។

6. នៅក្នុងខគម្ពីរ
តើអ្នកបានឃើញពីឧទាហរណ៍ជាក់លាក់អ្វីដែលនិយាយថាព្រះជាម្ចាស់ខ្វល់ខ្វាយពីរូបកាយរបស់មនុស្ស ? សូមព្យាយាមគិតពីឧទាហរណ៍ពីសម្ព័ន្ធមេត្រីចាស់ និងថ្មី។

ចម្លើយរបស់អ្នក

✓
✓
✓
✓

7. នៅក្នុងខគម្ពីរ
តើអ្នកបានឃើញពីឧទាហរណ៍ជាក់លាក់អ្វីដែលនិយាយថាព្រះជាម្ចាស់ខ្វល់ខ្វាយពីព្រលឹងរបស់មនុស្ស?

ចម្លើយរបស់អ្នក

✓
✓
✓
✓
✓

8. ពេលដែលយើងនិយាយថា “ដំណឹងល្អមានឥទ្ធិពលគ្រប់លក្ខណៈរបស់មនុស្សទាំងអស់…” គឺដោយសារតែព្រះជាម្ចាស់ខ្វល់ខ្វាយពីលក្ខណៈរបស់មនុស្សទាំងអស់។

## គ្រប់បរិបទទាំងអស់ (១៥ នាទី)

9. គោលការណ៍ទីបី គឺនិយាយអំពី “ដំណឹងល្អមានឥទ្ធិពលគ្រប់លក្ខណៈរបស់មនុស្សទាំងអស់ និងគ្រប់បរិបទទាំងអស់របស់មនុស្ស” នៅពេលដែលយើងនិយាយថា “បរិបទ” យើងមិនត្រឹមតែសំដៅលើទីកន្លែង និងទីតាំងប៉ុណ្ណោះទេ ប៉ុន្តែក៏សំដៅលើបញ្ហាសង្គមនៅក្នុងសហគមន៍ដែលមនុស្សកំពុងតែរស់នៅដែរ។ ឧទាហរណ៍៖

- មេរោគអេដស៍/ជំងឺអេដស៍
- អត្រាបទល្មើសខ្ពស់
- ភាពក្រីក្រ
- ក្រុមគ្រួសារគ្មានសុភមង្គល
- ការជួញដូរមនុស្ស

10. ហេតុអ្វីបានជាអ្នកគិតថាវាគឺជារឿងសំខាន់ដែលដំណឹងល្អមានឥទ្ធិពលគ្រប់លក្ខណៈមនុស្សទាំងអស់ និងគ្រប់បរិបទទាំងអស់?

- ពេលដែលដំណឹងល្អមានឥទ្ធិពលលើបរិបទទាំងអស់ វាអាចបើកទ្វារដើម្បីឱ្យមនុស្សទទួលស្គាល់ថាព្រះជាម្ចាស់ទ្រង់ខ្វល់ខ្វាយពីពួកគេ។
- ពេលដែលដំណឹងល្អមានឥទ្ធិពលលើគ្រប់បរិបទទាំងអស់ ព្រះរាជ្យរបស់ព្រះជាម្ចាស់នឹងមកដល់ ហើយព្រះហឫទ័យទ្រង់នឹងបានសម្រេច។

តើមានមូលហេតុអ្វីខ្លះ?

- ✓
- ✓
- ✓
- ✓

11. លោក Rupen Das ដែលជាសាសនាវិទូជនជាតិកាណាដា និងជាអ្នកធ្វើការអភិវឌ្ឍសហគមន៍ដែលមានបទពិសោធន៍បាននិយាយថា៖

*“អ្វីដែលទាក់ទាញជនក្រីក្រភាគច្រើនគឺដោយសារព្រះជាម្ចាស់ គឺជាព្រះដែលឆ្លើយតប យល់ពីភាពឈឺចាប់របស់ពួកគេ និងភាពឈឺចាប់ដែលនៅក្នុងពួកគេ – ទ្រង់គឺជា អេម៉ាញ៉ូអែល។” (លោក Rupen Das)*

12. ព្រះយេស៊ូគ្រិស្តគឺជាព្រះអម្ចាស់នៃជីវិត និងស្នាព្រះហស្តរបស់ព្រះអង្គ ហើយយើង គឺជាការសង្គ្រោះ និងជាបន្ទាល់របស់ព្រះអង្គ។

## បេសកម្មគ្រប់ជ្រុងជ្រោយ (១០ នាទី)

13. នេះគឺជាអត្ថន័យនៃបេសកម្មគ្រប់ជ្រុងជ្រោយរបស់យើង តើយើងអាចឱ្យនិយមន័យនៃពាក្យ “គ្រប់ជ្រុងជ្រោយ” បានយ៉ាងដូចម្ដេច?

ចម្លើយរបស់អ្នក

14. ពេលដែលយើងនិយាយអំពីបេសកកម្មគ្រប់ជ្រុងជ្រោយ យើងនិយាយអំពីព័ន្ធកិច្ចដែលដោះស្រាយបញ្ហាលក្ខណៈរបស់មនុស្សទាំងអស់ និងគ្រប់បរិបទទាំងអស់របស់មនុស្ស។

សាសនាវិទូជនជាតិអេក្វាទ័រលោក Rene Padilla បាននិយាយថា “ការធ្វើបេសកកម្មគ្រប់ជ្រុងជ្រោយ គឺជាការផ្ដោតលើព្រះយេស៊ូព្រះអង្គផ្ទាល់ និងក្រុមជំនុំនៅទសវត្សរ៍ដំបូង។”

ព្រះយេស៊ូទទួលស្គាល់ពីតម្រូវការរូបកាយរបស់មនុស្ស ហើយទ្រង់ក៏បំពេញតម្រូវការទាំងនោះ។ ទ្រង់ក៏យល់ពីតម្រូវការនៃការព្យាបាលរូបកាយមុនពេលព្យាបាលពីខាងក្នុងវិញ្ញាណរបស់មនុស្ស។

15. សូមមើលពីអ្វីដែលបានកើតឡើងបើយើងមិនទទួលស្គាល់ពីសារៈសំខាន់នៃតម្រូវការទាំងពីរគឺ រូបកាយ និងវិញ្ញាណ។

ក. នៅពេលដែលព័ន្ធកិច្ចផ្ដោតលើតែខាងវិញ្ញាណ ហើយមិនខ្វល់ពីតម្រូវការរូបកាយ តើនឹងមានហានិភ័យអ្វីខ្លះ?

ចម្លើយរបស់អ្នក

ខ. តើអាចនឹងមានបញ្ហាកើតឡើងអ្វីខ្លះបើយើងផ្តោតតែលើតម្រូវការរូបកាយ ប៉ុន្តែមិនដែលផ្សព្វផ្សាយ ឬបង្រៀនពួកគេពីដំណឹងល្អ?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓

## ការអនុវត្ត (១០ នាទី)

16. តើក្រុមរបស់យើងធ្វើវាយ៉ាងដូចម្តេច?
តើព័ន្ធកិច្ចរបស់យើងមានឥទ្ធិពលលើលក្ខណៈរបស់មនុស្សទាំងអស់
និងគ្រប់បរិបទទាំងអស់របស់មនុស្សដោយរបៀបណាខ្លះ?

17.
តើយើងអាចធ្វើអ្វីដែលខុសពីមុនដើម្បីដើរតាមគំរូរបស់ព្រះយេស៊ូក្នុងការធ្វើបេសកម្មគ្រប់ជ្រុងជ្រោយឱ្យកាន់តែប្រសើរជាងមុន?

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

ពេលដែលនិយាយថា ព្រះជាម្ចាស់ខ្វល់ខ្វាយពី “លក្ខណៈពេញលេញ”
របស់ខ្ញុំតើវាមានអត្ថន័យសម្រាប់ខ្ញុំយ៉ាងដូចម្តេច?

លក្ខណៈពេញលេញរបស់ “ខ្ញុំគឺជាខ្ញុំ” គឺត្រូវបានបង្ហាញនៅក្នុងសហគមន៍។
តើនៅក្នុងសហគមន៍បានបង្ហាញពីលក្ខណៈពេញលេញរបស់ “ខ្ញុំគឺជាខ្ញុំ” ដោយរបៀបណា? (ក្រុម សហគមន៍ ។ល។)

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីបី *បេសកកម្មគ្រប់ជ្រុងជ្រោយ*



# គោលការណ៍ទីបួន៖ និមិត្តផ្គត់ក្នុងការថ្វាយសិរីរុងរឿងដល់ព្រះគ្រិស្ត

គោលបំណងនៃការពិភាក្សា៖

1. ក្រុមរបស់យើងនឹងកាន់តែយល់ពីអត្ថន័យនៃការថ្វាយសិរីរុងរឿងដល់ព្រះគ្រិស្ត។
2. យើងនឹងពិចារណាពីរបៀបក្នុងការថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់នៅពេលដែលយើងបម្រើដល់សហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់ និងចាប់ផ្ដើមអនុវត្តអ្វីដែលយើងរៀនពីព័ន្ធកិច្ចរបស់យើង។

## ការរំលឹក (៥ នាទី)

1. សប្ដាហ៍មុន យើងបានមើលពីគោលការណ៍ទីបី៖ ដំណឹងល្អជះឥទ្ធិពលដល់លក្ខណៈទាំងអស់របស់មនុស្ស និងបរិបទទាំងអស់។ ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវគិតទៅលើ៖

   ពេលដែលនិយាយថា ព្រះជាម្ចាស់ខ្វល់ខ្វាយពីលក្ខណៈ “ពេញលេញ” របស់ខ្ញុំ តើវាមានអត្ថន័យសម្រាប់ខ្ញុំយ៉ាងដូចម្ដេច?

   លក្ខណៈពេញលេញរបស់ “ខ្ញុំគឺជាខ្ញុំ” គឺត្រូវបានបង្ហាញនៅក្នុងសហគមន៍។ តើនៅក្នុងសហគមន៍បានបង្ហាញពីលក្ខណៈពេញលេញរបស់ “ខ្ញុំគឺជាខ្ញុំ” ដោយរបៀបណា? (ក្រុម សហគមន៍ ។ល។)

2. សូមចំណាយពេល ៣-៤ នាទីដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## សេចក្ដីផ្ដើម (១០ នាទី)

3. សប្ដាហ៍នេះ យើងនឹងសិក្សាអំពីគោលការណ៍ទីបួន។

គោលការណ៍ទីបួន ការសង្ខេប៖ *“យើងមាននិមិត្តដ៏ធំរួមគ្នាគឺដើម្បីថ្វាយសិរីរុងរឿងដល់ព្រះគ្រិស្ត នៅពេលដែលមនុស្សជឿលើព្រះអង្គ ហើយសហគមន៍ទទួលបានការប៉ះពាល់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់។”*

4. “ការថ្វាយសិរីរុងរឿង” គឺជាពាក្យដែលយើងច្រើនឮនៅក្នុងសង្គមគ្រិស្តបរិស័ទ។ ប៉ុន្តែតើវាមានន័យដូចម្ដេចក្នុងការសរសើរនរណាម្នាក់? តោះ ស្វែងយល់ជាមួយគ្នា។

   សូមគិតអំពីពាក្យនេះ ជាពាក្យនៅក្នុងព្រះគម្ពីរ។ បើអាច សូមចំណាយពេលបន្តិចដើម្បីមើលពាក្យថា “ថ្វាយសិរីរុងរឿង” នៅក្នុងទូរសព្ទ កុំព្យូទ័រ ឬនៅក្នុងវចនានុក្រមតាមតែអាចធ្វើទៅបាន។

5. តើវាបាននិយាយយ៉ាងដូចម្ដេច?

   ចម្លើយរបស់អ្នក
   - ✓
   - ✓
   - ✓

6. តើអត្ថន័យនេះមានដូចម្តេចចំពោះអ្នក ក្នុងការថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់?

ចម្លើយរបស់អ្នក

✓
✓
✓

## ការដើរតាមគំរូព្រះយេស៊ូ (១៥ នាទី)

7. ព្រះយេស៊ូថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ មិនមែនតែតាមរយៈកិច្ចការ និងព្រះបន្ទូលរបស់ព្រះអង្គប៉ុណ្ណោះទេ ប៉ុន្តែក៏តាមរយៈលក្ខណៈរបស់ព្រះអង្គផងដែរ។ លក្ខណៈរបស់ព្រះអង្គបានថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ តាមរយៈសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះមនុស្ស និងទំនាក់ទំនងដែលទ្រង់មានជាមួយពួកគេ។

8. សូមចំណាយពេលបន្តិចដើម្បីគិតអំពីកិច្ចដែលយើង "ធ្វើ" ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ហើយគិតអំពី "លក្ខណៈ" នៃជីវិតរបស់យើង ចិត្តរបស់យើង ចរិត និងឥរិយាបទរបស់យើង។ ឧ. ព្រះយេស៊ូតែងតែអត់ធ្មត់ជាមួយសាវ័ករបស់ព្រះអង្គ។ ដែលថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ដោយសារតែការនេះគឺបង្ហាញពីចរិតពិតប្រាកដរបស់ព្រះតាមសេចក្តីពិត។

9. តើឥរិយាបទ ឬចរិតអ្វីខ្លះដែលយើងមាន ឬចង់មាន ដើម្បីបង្ហាញពីព្រះហឫទ័យរបស់ព្រះជាម្ចាស់?

ចម្លើយរបស់អ្នក

✓
✓
✓
✓
✓

10. សូមគិតអំពីរបៀបដែលព្រះយេស៊ូឆ្លើយតបទៅតាមតម្រូវការរបស់មនុស្ស។ តើដំណឹងល្អបានជំរុញព្រះហឫទ័យព្រះអង្គអ្វីខ្លះ?

ចម្លើយអាចជា ៖

✓
✓
✓
✓
✓

11. សូមគិតអំពីរបៀបដែលអ្នក ក្រុមរបស់អ្នក និងក្រុមជំនុំរបស់អ្នកឆ្លើយតបទៅតាមតម្រូវការរបស់មនុស្ស។

ក. តើពួកគេបានឆ្លើយតបតាមរបៀបណាខ្លះ?

ចម្លើយរបស់អ្នក

✓
✓
✓

ខ. តើអ្នកគិតថា តើអ្វីជាការជំរុញអ្នក? តើអ្នកចង់ទទួលបានលទ្ធផលអ្វី?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓
- ✓

គ. តើអ្នកនឹងបន្តឆ្លើយតបទៅតាមសេចក្តីត្រូវការរបស់មនុស្សតាមរបៀបទាំងនេះ ទោះបីជាអ្នកដឹងថាមានតែមនុស្សបន្តិចបន្តួចប៉ុណ្ណោះដែលនឹងដើរតាមព្រះយេស៊ូ?ហេតុអ្វី? សូមគិតអំពីកិច្ចការដែលអ្នកបានធ្វើ និងអ្នកដែលព្រះយេស៊ូបានប្រទានអាហារ ព្យាបាល និងបានជួយ។

ឃ. តើការជំរុញតាមរបៀបណាខ្លះដែលអាចជួយថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់? តើពួកគេធ្វើផ្ទុយពីនេះដោយរបៀបណា?

សេចក្តីបញ្ចប់ (១០ នាទី)

12. សូមគិតអំពីព្រះយេស៊ូ។

*"ដែលទ្រង់ជារូបអង្គនៃព្រះដ៏មើលមិនឃើញជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក" កូឡុស ១:១៥*

13. ព្រះយេស៊ូបានយាងមកលើផែនដីនេះដើម្បីជាតំណាងរបស់ព្រះជាម្ចាស់ ដើម្បីជួយមនុស្សឱ្យឃើញពីលក្ខណៈពិតប្រាកដរបស់ព្រះអង្គ។ ឥឡូវនេះ យើងគឺជាអ្នកតំណាងរបស់ព្រះអង្គ ចាំងចែងសិរីរុងរឿងរបស់ព្រះជាម្ចាស់ទៅកាន់មនុស្សជុំវិញខ្លួន។ នៅពេលដែលយើងនាំការផ្លាស់ប្តូរ យើងកំពុងតែធ្វើជាតំណាងរបស់ព្រះអង្គ។ យើងមិនធ្វើកិច្ចការនេះដោយកម្លាំងរបស់យើងនោះទេ គឺដូចព្រះចន្ទមិនចាំងជះពន្លឺបានទេ វាចាំងពន្លឺដែលផ្លាតពីព្រះអាទិត្យមក។ យើងក៏ដូច្នោះដែរ យើងឆ្លុះបញ្ចាំងព្រះគ្រីស្តដោយពន្លឺរបស់ទ្រង់នៅក្នុងយើង។ (២ កូរិនថូស ៣:១៨)

14. តាមរយៈការពិភាក្សានេះ តើវាមានអត្ថន័យដូចម្ដេចចំពោះអ្នក?

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

តើលក្ខណៈរបស់ព្រះជាម្ចាស់បានឆ្លុះបញ្ចាំងនៅក្នុងជីវិតមនុស្សដែលអ្នកស្គាល់ដូចម្ដេចខ្លះ? តើអ្នកអាចពិចារណាថានឹងជួយលើកទឹកចិត្តមនុស្សម្នាក់(ច្រើន) ដោយចែកចាយពីរបៀបដែលលក្ខណៈរបស់ព្រះជាម្ចាស់ដែលបានឆ្លុះបញ្ចាំងនៅក្នុងជីវិតរបស់ពួកគេបានដែរឬទេ?

តើសិរីរុងរឿងរបស់ព្រះជាម្ចាស់បានមើលឃើញតាមរយៈក្រុមរបស់អ្នកដូចម្ដេចខ្លះ? តើយើងកំពុងជួយសហគមន៍របស់យើង និងអ្នកដែលយើងបម្រើបានឃើញលក្ខណៈរបស់ព្រះជាម្ចាស់ដែរឬទេ?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីបួន *បេសកកម្មគ្រប់ជ្រុងជ្រោយ*



# គោលការណ៍ទីប្រាំ៖ ការអធិស្ឋាន សង្គ្រាមខាងវិញ្ញាណ និងការផ្លាស់ប្រែ

គោលបំណងនៃការពិភាក្សា៖
1. សមត្ថភាពក្រុមរបស់អ្នកក្នុងការស្គាល់ពីសង្គ្រាមខាងវិញ្ញាណនឹងរីកចម្រើនឡើង។
2. ក្រុមរបស់យើងនឹងមានទំនុកចិត្តថាយើងគ្មានអ្វីដែលត្រូវខ្លាចនោះទេ។
3. ក្រុមរបស់យើងនឹងអាចកំណត់ពីជំនួយដែលយើងត្រូវការក្នុងការឆ្លើយតបទៅនឹងសង្គ្រាមខាងវិញ្ញាណ។

## ការរំលឹក (៥ នាទី)

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីបួន៖ និមិត្តដ៏ធំក្នុងការថ្វាយសិរីរុងរឿងដល់ព្រះគ្រិស្ត។ ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវគិតទៅលើ៖

តើជីវិតមនុស្សដែលអ្នកស្គាល់បានបង្ហាញពីលក្ខណៈរបស់ព្រះជាម្ចាស់ដូចម្តេចខ្លះ?
តើអ្នកអាចជួយលើកទឹកចិត្តគ្នាតាមរយៈការចែកចាយពីរបៀបដែលលក្ខណៈរបស់ព្រះជាម្ចាស់
នៅក្នុងជីវិតរបស់ពួកគេដែរឬទេ?

តើក្រុមរបស់ខ្ញុំបានចែងចាំងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមកិច្ចការអ្វីខ្លះ?
តើយើងកំពុងជួយសហគមន៍
និងអ្នកដែលយើងបម្រើបានឃើញសិរីរុងរឿងរបស់ព្រះជាម្ចាស់ដែរឬទេ?

2. សូមចំណាយពេល ៣-៤ នាទីដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## ការស្គាល់ពីសង្គ្រាមខាងវិញ្ញាណ (៣ នាទី)

3. សប្តាហ៍នេះ យើងនឹងសិក្សាអំពីគោលការណ៍ទីប្រាំ។
(សូមមើលឯកសារដែលបានបញ្ជាក់ពីគោលការណ៍ទាំងដប់
ដើម្បីអានពីគោលការណ៍នេះឱ្យបានពេញលេញ។)

គោលការណ៍ទីប្រាំ ការសង្ខេប៖ *"ពាក្យអធិស្ឋាន
និងសង្គ្រាមខាងវិញ្ញាណគឺជាចំណុចស្នូលនៃដំណើរការនៃការផ្លាស់ប្រែ*

4. ពេលដែលយើងគិតអំពី "សង្គ្រាមខាងវិញ្ញាណ" យើងគិតអំពីរឿងផ្សេង ហើយជាពិសេស ពេលដែលយើងគឺជាក្រុមអន្តរជាតិ។ សូមចាប់ផ្តើមដោយការអធិស្ឋាន សុំប្រាជ្ញា និងភាពវៃឆ្លាតនៅពេលដែលយើងចូលទៅក្នុងការពិភាក្សាដ៏សំខាន់។

## ទិដ្ឋភាពផ្សេងៗនៃសង្គ្រាមខាងវិញ្ញាណ (១០ នាទី)

5. សង្គ្រាមខាងវិញ្ញាណ និងការអធិស្ឋានគឺជាចំណុចស្នូលនៃការអភិវឌ្ឍសហគមន៍។ ចំណុចស្នូលនៃសង្គ្រាមខាងវិញ្ញាណគឺយើងមានសត្រូវដែលចង់ញែកយើងចេញពីព្រះជាម្ចាស់។ សត្រូវវាមិនខ្វល់ថាវាត្រូវធ្វើកិច្ចការនេះដោយរបៀបណានោះទេ។

អ្នកនិពន្ធជំពូកទី ៥ នៅក្នុងមេរៀន *បេសកកម្មគ្រប់ជ្រុងជ្រោយ* នេះបានសរសេរថា៖

*យើងអាចគិតអំពីរបួស
និងគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗនៅពេលដែលមានការវាយប្រហារខាងវិញ្ញាណ។ ប្រហែលជា
យើងអាចគិតអំពីមន្តអាគម និងបណ្តាសាវិញ្ញាណអាក្រក់។ ពេលខ្លះ
យើងគិតអំពីការលំបាកក្នុងការតយុទ្ធប្រឆាំងនឹងអំណាចពុករលួយនិងបោកប្រាស់ដែលបន្ត
ដាក់សម្ពាធលើមនុស្ស និង បង្វៀងពួកគេចេញពីព្រះជាម្ចាស់។*

ថ្ងៃនេះ យើងនឹងផ្តោតលើយុទ្ធសាស្ត្រទាំងបីដែលខ្មាំងសត្រូវតែងតែប្រើ៖ អំពើធ្មប់

អំណាចពុករលួយ និងទម្លាប់ជីវិតប្រចាំថ្ងៃ។

វាអាស្រ័យលើទំហំក្រុមសិក្សា និងសេវាអ៊ីនធឺណិតសម្រាប់វគ្គបណ្តុះបណ្តាលអនឡាញ។ យើងអាចបែងចែកជាបីក្រុម។ បើយើងបែងចែកជាបីក្រុម ក្រុមនីមួយៗនឹងផ្តោតលើទិដ្ឋភាពផ្សេងៗគ្នា ហើយត្រូវបង្ហាញដល់ក្រុមទាំងមូល។

ក. ក្រុមទីមួយនឹងមើលទៅលើអំពើផ្ទប់ ផ្នែកទីមួយខាងក្រោម។
ខ. ក្រុមទីពីរនឹងមើលទៅលើអំណាចពុករលួយ (ប្រព័ន្ធអាក្រក់) ផ្នែកទីពីរខាងក្រោម។
គ. ក្រុមទីបីនឹងមើលទៅលើបញ្ហាទម្លាប់ជាប្រចាំថ្ងៃ ផ្នែកទីបីខាងក្រោម។

យើងមានពេលដប់នាទីសម្រាប់ក្រុមនីមួយៗ។ ក្រុមនីមួយៗត្រូវមានអ្នកកត់ត្រាពីរ ឬបីចំណុច ហើយត្រូវចែករំលែកក្នុងក្រុមពេលដែលត្រលប់មកជុំគ្នាវិញ។

ត្រូវធានាថា បាននិយាយអំពីរបៀបបង្កើតការផ្លាស់ប្រែនៅក្នុងបញ្ហាទាំងនេះ។

## ក្រុមទីមួយ៖ អំពើផ្ទប់ (១០ នាទី)

សូមអានរឿងខាងក្រោមជាមួយគ្នា៖

*កាលពីឆ្នាំ ២០០៦ ពេលដែលអ្នកធ្វើការដំបូងរបស់យើងបានទៅរស់នៅព្រំដែនប្រទេសសាំបា នៅមាត់ទន្លេតាំហ្គាយីកា ពួកគេបានឮល្បីពីអំពើអាបធ្មប់ មានការសែនឈាមរបស់មនុស្ស និងសត្វជាច្រើនជំនាន់មកហើយ។ ពេលដែលខ្ញុំចូលរួមជាមួយពួកគេនៅក្នុងឆ្នាំ ២០០៨ ខ្ញុំទទួលស្គាល់ថាការងាររបស់ក្រុមភាគច្រើនមានភាពវៃឆ្លាតក្នុងការកសាងមូលដ្ឋានគ្រឹះរឹងមាំខាងវិញ្ញាណ។*

*យើងមានបញ្ហាដោយសារកង្វះខាតស្បៀងអាហារ សម្លៀកបំពាក់ ការថែទាំសុខភាព និងការអប់រំនៅក្នុងសហគមន៍ទាំងនេះ។ យ៉ាងណាមិញ យុទ្ធសាស្ត្ររបស់យើងគឺបានបញ្ចូលការថែទាំសុខភាព ការអប់រំ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព។ ប៉ុន្តែការផ្លាស់ប្រែគឺកំពុងតែចាប់ផ្តើមនៅក្នុងវិញ្ញាណរបស់ពួកគេបន្តិចម្តងៗ។ នៅក្នុងភូមិមួយមានជនជាតិអាមេរិកម្នាក់ដែលបានសង់សាលារៀនមួយ និងគ្លីនិកមួយ។ គាត់បានប្រាប់យើងពីទុក្ខលំបាករបស់គាត់អំពីការចំណាយលើការវិនិយោគដ៏ធំនៅក្នុងសហគមន៍ និងទម្លាប់អាក្រក់របស់ប្រជាជនដែលមិនបានផ្លាស់ប្តូរ។*

*តើការផ្លាស់ប្រែជារៀងរហូតកើតចេញមកដោយរបៀបណា? ក្រុមរបស់យើងបានចាប់ផ្តើមជាមួយសេចក្តីពិត ហើយសេចក្តីស្រឡាញ់ដែលពេញខ្នាត នោះបណ្តេញសេចក្តីភ័យខ្លាចចេញអស់ (១ យ៉ូហាន ៤:១៨)។ ដោយដឹងថាដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ (អេភេសូ ៦:១២) ហើយជាជាងការផ្តោតលើ ការថែទាំសុខភាព និងសកម្មភាពនៃការរស់នៅល្អទាំងនោះ ក្រុមរបស់យើងផ្តោតលើអាទិភាពនៃការអធិស្ឋាន និងការប្រកាសពីព្រះបន្ទូលព្រះជាម្ចាស់។ ជារៀងរាល់បីថ្ងៃក្នុងមួយសប្តាហ៍ យើងដើរអធិស្ឋាននៅក្នុងភូមិចាប់ពីម៉ោង ៦ ដល់ ៧ ព្រឹក ហើយប្រកាសលឺៗពីព្រះបន្ទូលព្រះជាម្ចាស់។ ការបន្តធ្វើបែបនេះគឺជាអាវុធខាងវិញ្ញាណដើម្បីប្រឆាំងនឹងសង្គ្រាមខាងវិញ្ញាណក្នុងសហគមន៍។*

*យើងទទួលស្គាល់ថាព្រះវិញ្ញាណបរិសុទ្ធកំពុងតែមកលើសហគមន៍នេះ ជាកន្លែងដែលមនុស្សកំពុងតែមានជំនឿយ៉ាងរឹងមាំលើវត្ថុស័ក្តសិទ្ធិរបស់ពួកគេ។ ពួកគេគ្រាន់តែផ្លាស់ប្តូរជំនឿដែលជឿថាបណ្តាសាទាំងនេះបានធ្វើឱ្យពួកគេឈឺ ឬស្រេកឃ្លាន មកជឿលើព្រះជាម្ចាស់ដែលជាព្រះអាទិករ ហើយទ្រង់ចង់ព្យាបាលពួកគេ។ មានមនុស្សជាច្រើនដែលទទួលបានការព្យាបាល និងរំដោះឱ្យមានសេរីភាពតាមរយៈការអធិស្ឋាន។ មនុស្សចាប់ផ្តើមមើលឃើញពីជម្រើសក្នុងការជឿលើព្រះជាម្ចាស់ និងអំពើផ្ទប់ពីគ្រូមន្តអាគមន៍ ដោយសារតែប្រពន្ធមេភូមិគឺជាគ្រូមន្តអាគមន៍ និងបានកែប្រែចិត្តគំនិតមកជាអ្នកជឿ ជាបន្ទាល់ពីអំណាចរបស់ព្រះជាម្ចាស់។*

*នៅក្នុងភូមិនោះ គ្លោរៀដែលជាភរិយាអ្នកនេសាទត្រីបានមកជួបសមាជិកក្រុមរបស់យើង*

*អាល់ហ្វ្រេដ ដោយសារគាត់បានបាត់បង់កូនក្នុងផ្ទៃច្រើនដងមកហើយ។ ក្នុងអំឡុងពេលមានផ្ទៃពោះមុនៗ គាត់បានយល់សប្តិឃើញមានកាំបិតមកចាក់គាត់ ហើយគាត់ក៏បាត់បង់កូនរបស់គាត់។ ពេលដែលគាត់មកជួបអាល់ហ្វ្រេដ គាត់ក៏បានមានផ្ទៃពោះម្តងទៀត គាត់បានសុំឱ្យអាល់ហ្វ្រេដអធិស្ឋានឱ្យកូនរបស់គាត់មានសុខភាពល្អ។ ប៉ុន្មានថ្ងៃមក គ្លោរៀបានមកជួបអាល់ហ្វ្រេដដោយក្តីបារម្ភដោយសារតែគាត់បានយល់សប្តិតឃើញកាំបិតទៀតហើយ។ បន្ទាប់ពីបានអធិស្ឋានសម្រាប់គ្លោរៀរួច គ្លោរៀក៏បានសម្រាលបានកូនដែលមានសុខភាពល្អមួយ។ ក្រោយមក អាល់ហ្វ្រេដបានយល់សប្តិឃើញកាំបិតមកចាក់គាត់ ប៉ុន្តែគាត់បានក្រោកឡើងបណ្តេញវិញ្ញាណអាក្រក់ក្នុងព្រះនាមព្រះយេស៊ូ និងបានសើចចំអកអារក្សដែលបានព្យាយាមធ្វើឱ្យគាត់ភ័យ ហើយគាត់ក៏បន្តគេងទៅវិញ។*

## សំណួរពិភាក្សា (១០ នាទី)

ក. តើអ្នកបានឃើញអំពើផ្ទប់ដែលជាប្រភេទនៃសង្គ្រាមខាងវិញ្ញាណក្នុងរឿងនេះនៅត្រង់ណា?

ខ. តើក្រុមបានចូលរួមតយុទ្ធដោយពាក់គ្រឿងសាស្ត្រាវុធរបស់ព្រះជាម្ចាស់ដោយរបៀបណា?

គ. តើវត្តមានក្រុមបានបង្ហាញពីព្រះរាជ្យរបស់ព្រះជាម្ចាស់ក្នុងសហគមន៍ដោយរបៀបណា?

ឃ. តើមានការផ្លាស់ប្រែអ្វីខ្លះកើតឡើង?

## ក្រុមទីពីរៈ អំណាចពុករលួយ (១០ នាទី)

ពេលដែលយើងនិយាយអំពីប្រព័ន្ធអាក្រក់ យើងមានន័យថាៈ

- មនុស្ស និងអំណាចដែលបង្កើតឱ្យមានការជួញដូរមនុស្ស។ ច្បាប់ និងមនុស្សដែលមានអំណាចដែលបន្តរក្សាមនុស្សឱ្យស្ថិតនៅក្នុងភាពក្រីក្រ និងប្រាក់ឈ្នួលទាប។
- ក្រុមហ៊ុនដែលមានខ្នងអ្នកនយោបាយ និងមន្ត្រីរដ្ឋាភិបាលដែលធ្វើឱ្យពួកគេគេចចេញពីច្បាប់ស្តីពីការបំពុល។
- ប៉ូលិស មន្ត្រីគយ និងអន្តោប្រវេសន៍ដែលពិន័យ ឬមិនធ្វើកិច្ចការដែលពួកគេគួរធ្វើ លុះត្រាតែមានការសូកប៉ាន់។

សូមអានរឿងខាងក្រោមជាមួយគ្នាៈ

*ក្មេងស្រីហូប *ត្រូវបានគេយកចេញពីប្រទេសរបស់នាងមកកាន់ប្រទេសក្រិចតាំងពីតូច ហើយត្រូវបានបង្ខំឱ្យបម្រើផ្លូវភេទ។ បន្ទាប់ពីបានជួបរ៉យស៍ និងក្រុមរបស់រ៉ស៍យ ព្រមទាំងបាននិយាយរឿងនេះ ហូបក៏ទទួលស្គាល់ថានេះគឺជារឿងខុសឆ្គង និងចង់ចាកចេញពីផ្លូវនេះ។ យ៉ាងណាមិញ វាមិនមែនជារឿងសាមញ្ញនោះទេ។*

*ហូប បានមកកាន់ប្រទេសក្រិចដោយគ្មានលិខិតស្នាមអ្វីទាំងអស់ ដូច្នេះការងារដែលនាងអាចធ្វើបានគឺការងារខុសច្បាប់ និងទទួលបានកម្រៃទាបបំផុត។ ចុងក្រោយ ហូបបានធ្វើការនៅក្នុងសណ្ឋាគារ និងផ្ទះបាយពេលដែលមានកំណើនទេសចរច្រើន ដោយទទួលបានកម្រៃទាប ព្យាយាមគេចពីចៅកែដែលព្យាយាមកេងប្រវ័ញ្ចមកលើនាងដែលជាអ្នកលាងចានដែលជាស្រីស្អាត។*

*ទោះបីជាហូបបានចាកចេញពីការងារផ្លូវភេទ និងរកការងារផ្សេងក៏ដោយ ក៏វាបានធ្វើឱ្យនាងរងការប៉ះទង្គិចផ្លូវចិត្តដែរ។ រហូតមកដល់ពេលនេះ នាងនៅតែពិបាកទុកចិត្តមនុស្ស ហើយព្យាយាមធ្វើការគេចចេញពីការងារជាក្រុម។ នាងគិតថាមនុស្សនឹងធ្វើបាបនាង។ រ៉យស៍ និងក្រុមរបស់រ៉យស៍បាននិយាយអំពីការអត់ទោស ប៉ុន្តែវាមិនមែនជារឿងងាយយល់សម្រាប់ជីវិតរបស់នាងនោះទេ។ ពេលដែលហូបកំពុងតែជឿលើព្រះជាម្ចាស់ នាងមិនដែលទទួលបានបទពិសោធន៍អំពីព្រះគុណ និងយល់ពីអត្ថន័យនេះនោះទេ។*

*រ៉យស៍បាននិយាយថា ព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ក្នុងជីវិតរបស់ហូប។ "ប៉ុន្តែនៅតែមានស្ត្រីជាច្រើនដែលនៅតែធ្វើការនៅក្នុងផ្ទះបន និងនៅតាមផ្លូវនៅក្នុងប្រទេសក្រិច។ ពួកគេមានសិទ្ធិដូចគ្នាក្នុងការដឹង និងរៀនទុកចិត្តព្រះ ជាព្រះសង្គ្រោះ និងការពារពួកគេ ហើយរៀនផ្តល់តម្លៃឱ្យពួកគេ។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ក្នុងការបង្កើតអង្គការមិនស្វែងរកប្រាក់ចំណេញតាមរយៈរ៉យស៍ និងក្រុមរបស់រ៉យស៍នឹងក្លាយទៅជាជម្រើសសម្រាប់ស្ត្រីដែលរងគ្រោះទាំងនោះនៅក្នុងប្រទេសក្រិច។*

**ឈ្មោះរបស់ហូប ត្រូវបានប្តូរដើម្បីរក្សាសិទ្ធិឯកជនរបស់នាង។ រឿងនេះមកពី 'សេចក្តីសង្ឃឹមរបស់ហូបនៅក្នុងប្រទេសក្រិច' ពីនាយកដ្ឋានប្រាស្រ័យទាក់ទងរបស់អង្គការ OM។*

## សំណួរពិភាក្សា

ក. តើអ្នកបានឃើញអំពើអំណាចប្រព័ន្ធពុករលួយក្នុងរឿងនេះនៅត្រង់ណា?

ខ. តើក្រុមបានប្រឆាំងនឹងអំណាចប្រព័ន្ធពុករលួយដោយរបៀបណា? តើពួកគេបានតយុទ្ធនឹងសង្គ្រាមខាងវិញ្ញាណក្រៅពីការអធិស្ឋាន តមអាហារ និងថ្វាយបង្គំដោយរបៀបណា?

គ.តើវត្តមានរបស់អ្នកជឿក្នុងសហគមន៍បានបង្ហាញពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយរបៀបណាខ្លះ?

ឃ. តើមានការផ្លាស់ប្រែអ្វីខ្លះកើតឡើង?

## ក្រុមទីបី៖ ទម្លាប់ជីវិតប្រចាំថ្ងៃ (១០ នាទី)

សូមអានរឿងខាងក្រោមជាមួយគ្នា៖

រឿងរបស់យូហាណា ដកស្រង់ចេញពីជំពូកទី ៥ *បេសកកម្មគ្រប់ជ្រុងជ្រោយ៖*

*ការប្រឆាំងនឹងភពខាងវិញ្ញាណអាចកើតចេញពីទម្លាប់ប្រចាំថ្ងៃ។ សហការីមកពីអាស៊ីបានសរសេរថា៖ យើងអាចដឹងថាមានការប្រឆាំងនឹងភពខាងវិញ្ញាណមកដូចជារលក ហើយភាគច្រើនគឺមកដោយយើងមិនបានរំពឹងទុក។ យើងមិនដែលមានការប្រឆាំងចេញមកពីការបង្កើតសាសនា ឬរដ្ឋាភិបាលនោះទេ ដោយសារពួកគេឃើញពីអត្ថប្រយោជន៍សម្រាប់កុមារ និងគ្រួសារដែលយើងធ្វើការជាមួយ។ ប៉ុន្តែខ្ញុំបានឃើញថាវាកើតឡើងតាមរបៀបផ្សេងៗនៅក្នុងក្រុមអភិវឌ្ឍន៍សហគមន៍ តាមរយៈការបំបាក់ទឹកចិត្ត ការយល់ខុស វិវាទ ជំងឺ បញ្ហាទិដ្ឋាការ និងការតានតឹងផ្សេងៗទៀតដែលតែងតែចង់មកបៀតបៀនយើង "ចេញពីខាងក្នុង"*

រឿងរបស់រេបេកា

*រេបេកាកំពុងតែអង្គុយនៅមុខកុំព្យូទ័រ ព្យាយាមផ្តោតលើវគ្គសិក្សាដែលនាង និងក្រុមរបស់នាងត្រូវបង្រៀនសប្តាហ៍ក្រោយនៅអាហ្វ្រិក។ មិនយូរនោះទេដែលនាងត្រូវធ្វើដំណើរសម្រាប់វគ្គសិក្សានោះ ប៉ុន្តែភ្លាមៗនោះក៏មានរឿងបែកអារម្មណ៍ជាច្រើនបានកើតឡើងសម្រាប់នាង។ យូរៗទៅកាន់តែមានរឿងច្រើនទៀតៗ ដែលកាន់តែធ្វើឱ្យនាងបែកអារម្មណ៍ តានតឹង ហើយពិបាកក្នុងការផ្តោតអារម្មណ៍ដើម្បីរៀបចំ។ នាងក៏បានក្រោកដើរចេញពីកុំព្យូទ័រ ដើរចេញក្រៅ។ ពេលកំពុងតែដើរ នាងលឺសម្លេង "ផ្លុក" ក្រោមជើងនាង។ ពេលនាងមើលទៅក្រោម នាងដឹងថាផ្ទះនាងកំពុងតែលិច។ ដោយសារតែស្ទះលូរ ហើយសុទ្ធតែសំរាមពេញផ្ទះ និងក្នុងបន្ទប់នាងទៀត។ ពេលនោះហើយដែលនាងទទួលស្គាល់ថា ការបែកអារម្មណ៍ទាំងអស់មិនមែនជារឿងចៃដន្យនោះទេ។ "ព្រះជាម្ចាស់ច្បាស់ជាចង់ធ្វើកិច្ចការដ៏អស្ចារ្យអ្វីមួយហើយតាមរយៈវគ្គសិក្សានេះ បានជាអារក្សព្យាយាមមករំខានខ្ញុំ" បន្ទាប់ពីនាងបានដឹងពីគម្រោងការរបស់អារក្ស*

*ផ្ទត់គំនិតរបស់នាងបានផ្លាស់ប្ដូរ។ នាងក៏ចាប់ផ្ដើមលើកកម្រាលព្រំដែលកំពុងតែជោគនោះ ហើយបន្ទាប់មកចំដោយចិត្តត្រេកអរ ពោរពេញទៅដោយអំណរដោយសារតែនាងដឹងថា ព្រះជាម្ចាស់នឹងធ្វើកិច្ចដ៏អស្ចារ្យដែលនាងនឹកស្មានមិនដល់។*

## សំណួរពិភាក្សា

ក. តាមរយៈរឿងខាងលើនេះ តើបានបង្ហាញពីការប្រឆាំងភពខាងវិញ្ញាណអ្វីខ្លះនៅក្នុងបញ្ហាទូទៅនៃជីវិតប្រចាំថ្ងៃ?

ខ. អ្វីដែលយើងបាននិយាយមុននេះអំពីរបៀបដែលអារក្សប្រើប្រាស់សង្គ្រាមខាងវិញ្ញាណដើម្បីរំខានយើង ឱ្យដាច់ចេញពីព្រះជាម្ចាស់។ តើអ្វីដែលយើងបានសរសេរមុននេះ បំបែកយើងចេញពីព្រះជាម្ចាស់ និងគោលបំណងព្រះអង្គសម្រាប់ជីវិតរបស់យើងដូចម្ដេចខ្លះ?

គ. នៅក្នុងបញ្ហាទូទៅនៃជីវិតប្រចាំថ្ងៃរបស់អ្នក តើអ្នកបានមានបទពិសោធន៍អំពីសង្គ្រាមខាងវិញ្ញាណដូចម្ដេចខ្លះ?

ឃ. តើមានការផ្លាស់ប្រែអ្វីខ្លះកើតឡើង?

## ការចែកចាយពីការពិភាក្សាក្រុម (១០ នាទី)

6. សូមស្ដាប់ពីការបង្ហាញរបស់ក្រុមនីមួយៗ។ ក្រុមនីមួយៗនឹងចែកចាយពីប្រភេទសង្គ្រាមខាងវិញ្ញាណដែលខ្លួនបានមើល ហើយត្រូវបង្ហាញមួយឬពីរចំណុចចេញពីការពិភាក្សា រួមបញ្ចូលទាំង ភស្តុតាងនៃការផ្លាស់ប្រែដែលបានកើតឡើង។

## គ្មានអ្វីដែលត្រូវភ័យខ្លាច (៥-១០ នាទី)

7. ចំណុចទីពីរដែលយើងចង់ផ្តោតនៅលើសេចក្តីពិត នោះគឺគ្មានអ្វីដែលត្រូវភ័យខ្លាចនោះទេ។

អ្នកស្រី Holly Steward បានសរសេរនៅក្នុងសៀវភៅ *បេសកកម្មគ្រប់ជ្រុងជ្រោយ* ថា៖

*"តាមរយៈបទពិសោធន៍របស់ខ្ញុំនៅក្នុងប្រទេសសាំបា សញ្ញាទីមួយដែលជាចំណងក្នុងសហគមន៍នោះគឺ សេចក្តីភ័យខ្លាច ក្រៅពីនេះវាអាចជាការអស់សង្ឃឹម ភាពលោភលន់ ហឹង្សា ឬភាពអាត្មា និយម។"*

*នៅក្នុងបរិបទក្រុមរបស់អ្នក តើអ្វីខ្លះទៅដែលអាចជាសញ្ញានៃចំណងក្នុងសហគមន៍សម្រាប់អារក្ស?*

*តើសញ្ញាអ្វីខ្លះដែលបញ្ជាក់ថា ចំណងនោះត្រូវបានបំបែក?*

អ្នកស្រី Holly Steward បានបន្តនៅក្នុងជំពូកក្នុងសៀវភៅ បេសកកម្មគ្រប់ជ្រុងជ្រោយ ថា៖

*សមាជិកក្រុមយើងភាគច្រើនគឺជាជនជាតិសាំបា ដែលមានចំណេះដឹង និងជំនាញមានកម្រិត។ នៅក្នុងភូមិនៅក្នុងទន្លេតាំហ្គាយីកា យើងបានដឹងថាមេភូមិ—ក៏ជាគ្រូមន្តអាគមន៍— គាត់អាចមើលឃើញពីខាងក្នុងពួកគេបាន។ គាត់បានប្រាប់ពួកគេថា "វិញ្ញាណដែលស្ថិតនៅជាមួយអ្នកខ្លាំងជាងវិញ្ញាណដែលនៅជាមួយខ្ញុំ មន្តអាគមន៍របស់ខ្ញុំលែងមានប្រសិទ្ធភាពទៀតហើយ ដោយសារតែវត្តមានវិញ្ញាណដែលនៅក្នុងអ្នកនៅក្នុងភូមិរបស់យើង"។*

8. ខគម្ពីរបានប្រាប់យើងថា "សេចក្តីស្រឡាញ់ដែលពេញខ្នាត នោះបណ្តេញសេចក្តីភ័យខ្លាចចេញ" (១ យ៉ូហាន ៤:១៨)។ តើអ្វីទៅដែលជាការឆ្លើយតបរបស់អ្នកទៅលើគំនិតដែលនិយាយថា សេចក្តីស្រឡាញ់ដែលពេញខ្នាត នោះបណ្តេញសេចក្តីភ័យខ្លាចចេញនៅក្នុងបរិបទសង្គ្រាមខាងវិញ្ញាណ?

9. អ្នកស្រី Holly ក៏បានសរសេរថា៖ "សូមអរព្រះគុណព្រះយេស៊ូ ដោយសារព្រះអង្គ យើងស្ថិតនៅក្រុមដែលមានជ័យជំនះ ដ្បិតទ្រង់បានយកឈ្នះរួចហើយ! យើងខ្ញុំវិសេសលើសជាងអ្នកដែលមានជ័យជំនះទៅទៀត (រ៉ូម ៨:៣៧) ទ្រង់មិនត្រឹមតែការពារយើងទេ តែធ្វើឱ្យយើងជាអ្នកដែលមានជ័យជំនះ ហើយខ្មាំងសត្រូវត្រូវតែរត់ចេញពីយើង។

## តើយើងត្រូវប្រើជំនួយ ឬយុទ្ធសាស្រ្តអ្វីខ្លះ? (៥ នាទី)

10. ការមានជ័យជំនះគឺមិនត្រឹមតែការទទួលស្គាល់ពីសង្គ្រាមខាងវិញ្ញាណ និងមិនភ័យខ្លាចនោះទេ។ ព្រះជាម្ចាស់បានប្រទានឱ្យយើងមានជំនួយដើម្បីឱ្យយើងអាចប្រឆាំងនឹងសង្គ្រាមខាងវិញ្ញាណ។ ការអនុវត្តសំខាន់ៗបី៖

ក. ការប្រកាសពីព្រះបន្ទូលព្រះជាម្ចាស់៖ ខគម្ពីរគឺជាមូលដ្ឋានគ្រឹះនៅក្នុងភពខាងវិញ្ញាណ ដោយសារព្រះបន្ទូលព្រះជាម្ចាស់គឺមានអំណាច។ "ពីព្រោះ ឯព្រះបន្ទូលនៃព្រះរស់នៅ ហើយពូកែផង ក៏មុតជាងដាវណាមានមុខពីរ (ហេប្រឺ ៤:១២)។ តើក្រុមរបស់យើងនឹងប្រកាសពីសេចក្តីពិតអ្វីខ្លះ? តើយើងនឹងធ្វើដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓

ខ. ការមានអំណរ៖
តើនៅក្នុងខគម្ពីរបាននិយាយអំពីការមានអំណរនៅក្នុងសង្គ្រាមខាងវិញ្ញាណត្រង់កន្លែងណា? តើវាអាចក្លាយទៅជាផ្នែកមួយនៃគោលបំណងរបស់អ្នក និងក្រុមរបស់អ្នកដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓

គ. ការកែប្រែចិត្តគំនិត៖
តើការកែប្រែចិត្តគំនិតអាចក្លាយជាវិធីដែលអ្នកប្រើដើម្បីតយុទ្ធនឹងសង្គ្រាមខាងវិញ្ញាណដោយរបៀបណា? (សូមអានដានីយ៉ែល ៩:៤-៦)

ចម្លើយរបស់អ្នក

✓
✓
✓

## សេចក្ដីបញ្ចប់ (៥ នាទី)

11. តើយើងអាចរៀនបានរួមគ្នាអ្វីខ្លះពីសង្គ្រាមខាងវិញ្ញាណ?

លោក Walter Wink (នៅក្នុងសៀវភៅលោកឈ្មោះ ការដាក់ឈ្មោះអំណាច)បាននិយាយថា៖

*យើងត្រូវតែបង្កើតការសម្គាល់ដែលចាស់បុរាណហៅថា "សង្គ្រាមនៅស្ថានសួគ៌" ... ការគ្រាស់ហៅដំអស្ចារ្យរបស់ក្រុមជំនុំដើម្បីបំផ្លាស់បំប្រែសហគមន៍គឺតាមរយៈការបញ្ជាក់ពីកិច្ចការរបស់យើង។ យើងកំពុងតែតយុទ្ធទាំងនៅលើផែនដី និងនៅស្ថានសួគ៌។*

បើយើងចង់ឃើញការផ្លាស់ប្រែ ចង់ឃើញសហគមន៍សកម្ម ហើយជាពិសេសសហគមន៍ដែលដើរតាមព្រះយេស៊ូ តើកិច្ចការនេះអាចកើតឡើងដោយរបៀបណា?

តើយើងត្រូវមានជំនួយអ្វី និងដោយរបៀបណា (យុទ្ធសាស្ត្រ ឬអាវុធ) ដែលយើងត្រូវប្រើនៅក្នុងសង្គ្រាមខាងវិញ្ញាណ ដើម្បីឱ្យការផ្លាស់ប្រែអាចកើតឡើងបាន?

*"ដែលទ្រង់ជារូបអង្គនៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក" កូឡុស ១:១៥*

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

តាមរយៈការពិភាក្សាថ្ងៃនេះ តើអ្នកទទួលបានចំណុចសំខាន់អ្វីខ្លះនៅក្នុងសង្គ្រាមខាងវិញ្ញាណ? តើអ្នកបានឆ្លុះបញ្ចាំងពីអ្វីដែលបានដឹង និងមានបទពិសោធន៍ ឬអ្នកបានរៀនពីអ្វីថ្មី? តាមរយៈជំនួយមកពីព្រះជាម្ចាស់ តើអ្នកអាចនឹងយកវាទៅអនុវត្តដោយវិធីណា?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីប្រាំ *បេសកកម្មគ្រប់ជ្រុងជ្រោយ*



# គោលការណ៍ទីប្រាំមួយៈ ការខ្វល់ខ្វាយពីស្នាព្រះហស្ត គឺជាការថ្វាយបង្គំ ការធ្វើជាបន្ទាល់ និងការស្តាប់បង្គាប់

គោលបំណងនៃការពិភាក្សាៈ

1. ក្រុមរបស់យើងនឹងយល់កាន់តែស៊ីជម្រៅពីអត្ថន័យនៃការខ្វល់ខ្វាយពីស្នាព្រះហស្ត និងមូលហេតុដែលវាគឺជារឿងសំខាន់ ដូចជាការថ្វាយបង្គំ និងស្តាប់បង្គាប់ និងការធ្វើជាបន្ទាល់ដល់អស់អ្នកដែលនៅជុំវិញយើង។
2. ក្រុមរបស់យើងនឹងគិតថា ការខ្វល់ខ្វាយពីស្នាព្រះហស្តរបស់ព្រះជាម្ចាស់នឹងក្លាយទៅជាគុណតម្លៃរបស់យើង របៀបដែលយើងរស់នៅ និងមិនមែនគ្រាន់តែជា កម្មវិធី ឬគម្រោងបដែលយើងធ្វើការប៉ុណ្ណោះទេ។"

## ការរំលឹក

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីប្រាំៈ "ពាក្យអធិស្ឋាន និងសង្គ្រាមខាងវិញ្ញាណគឺជាចំណុចស្នូលនៃដំណើរការនៃការផ្លាស់ប្រែ"

2. ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវគិតទៅអ្វីដែលយើងបានដឹង និងអ្វីដែលយើងបានរៀនពីសង្គ្រាមខាងវិញ្ញាណ។ តាមរយៈជំនួយដែលមកពីព្រះជាម្ចាស់ តើអ្នកចង់អនុវត្តអ្វី?

សូមចំណាយពេល ៣-៤ នាទី ដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## សេចក្តីផ្តើម (១០ នាទី)

3. សប្តាហ៍នេះ យើងនឹងសិក្សាអំពីគោលការណ៍ទីប្រាំមួយ។ (គោលការណ៍ទាំងអស់ត្រូវបានផ្តល់ជូនអ្នករួចហើយ។)

គោលការណ៍ទីប្រាំមួយ ការសង្ខេបៈ *ការខ្វល់ខ្វាយពីស្នាព្រះហស្ត គឺជាការថ្វាយបង្គំ ការធ្វើជាបន្ទាល់ និងការស្តាប់បង្គាប់"*

4, នៅជុំវិញយើង និងសហគមន៍របស់យើង តើអ្នកមើលឃើញការអស្ចារ្យអ្វីដែលព្រះអាទិករបានដាក់នៅកន្លែងដែលយើងរស់នៅ?

ចម្លើយរបស់អ្នក

✓
✓
✓

5. តើពិភពលោកដែលព្រះជាម្ចាស់បានបង្កើតនេះ ត្រូវបានខូចខាតត្រង់ណាខ្លះ?

ចម្លើយរបស់អ្នក

✓
✓
✓

6. តើពាក្យថា “ការខ្វល់ខ្វាយពីស្នាព្រះហស្ត” មានន័យដូចម្ដេចសម្រាប់អ្នក?

ចម្លើយរបស់អ្នក
✓
✓
✓

7. តើការខ្វល់ខ្វាយពីស្នាព្រះហស្តគឺជាសកម្មភាពនៃការថ្វាយបង្គំតាមរបៀបណាខ្លះ?

ចម្លើយរបស់អ្នក
✓
✓
✓

8. នៅពេលដែលគ្រិស្តបរិស័ទមិនខ្វល់ខ្វាយពីពិភពលោកនេះ តើវាមានន័យដូចម្ដេចចំពោះអ្នកដែលនៅជុំវិញយើង?

ចម្លើយរបស់អ្នក
✓
✓
✓
✓

9. តើការខ្វល់ខ្វាយពីស្នាព្រះហស្តអាចជាការធ្វើជាបន្ទាល់សម្រាប់អ្នកដែលនៅជុំវិញយើងដោយរបៀបណា?

ចម្លើយរបស់អ្នក
✓
✓
✓

10. គោលការណ៍នេះបាននិយាយថា ការខ្វល់ខ្វាយពីស្នាព្រះហស្តគឺជាសកម្មភាពនៃការស្ដាប់បង្គាប់។ តើខគម្ពីរនៅកន្លែងណាដែលបង្រៀនយើងឱ្យខ្វល់ខ្វាយពីស្នាព្រះហស្ត?

ចម្លើយរបស់អ្នក
✓
✓
✓

## សូមមើលទៅលើខគម្ពីរ (១០-១៥ នាទី)

11. តើខគម្ពីរបាននិយាយអ្វីអំពីការខ្វល់ខ្វាយពីស្នាព្រះហស្ត? សូមស្ដាប់ការសម្ភាសន៍ខ្លីមួយជាមួយបណ្ឌិត រ៉ូបឺត ស្លូកា ដែលជាជីវៈវិទូជើងទឹកដែលបានធ្វើការជាមួយអង្គការ រ៉ូឆា

ភ្នាក់ងារគ្រិស្តបរិស័ទសកលធ្វើការទាក់ទងនឹងការខ្វល់ខ្វាយពីស្នាព្រះហស្ត។ លោកបប់ និងគ្រួសាររបស់គាត់បានរស់នៅជាច្រើនឆ្នាំនៅអាស៊ីខាងត្បូង ហើយពេលនេះគាត់កំពុងតែជួយប្រទេសជាច្រើនទៀតនៅជុំវិញពិភពលោក។

> សម្គាល់៖ ប្រសិនបើវីឌីអូមិនអាចប្រើប្រាស់បានទេ សូមបន្តទៅខគម្ពីរ និងសំណួរនៅចុងមេរៀន បន្ទាប់មកសូមទៅមើលសំណួរទី ១១ ពេលដែលអ្នកបានបញ្ចប់វគ្គសិក្សានេះ។

វីឌីអូនេះអាចប្រើប្រាស់បាន តាមរយៈការចុចលើតំណរភ្ជាប់នេះ៖
https://vimeo.com/605038367/82bee419db

12. តើលោកបណ្ឌិតស្លូកា បាននិយាយអ្វីអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ដែលអ្នកគិតថាគួរឱ្យចាប់អារម្មណ៍? តើគាត់និយាយអ្វីខ្លះអំពីព្រះយេស៊ូ និងស្នាព្រះហស្តដែលជារឿងថ្មីសម្រាប់អ្នក?

ចម្លើយរបស់អ្នក
- ✓
- ✓
- ✓

លោកបណ្ឌិត ស្លូកា បាននិយាយអំពីក្លាមតូចមួយ ហើយ “ភាពជាក្លាមនេះ” គឺជាផ្នែកមួយនៃការថ្វាយព្រះជាម្ចាស់ជាសកល។ តើនេះមានន័យយ៉ាងដូចម្តេច? តើស្នាព្រះហស្តសរសើរតម្កើងព្រះជាម្ចាស់ដោយរបៀបណា?

ចម្លើយរបស់អ្នក
- ✓
- ✓
- ✓

តើគំនិតរបស់លោកបណ្ឌិត ស្លូកា លើកទឹកចិត្តអ្នក ឬជំរុញអ្នកដូចម្តេចខ្លះ នៅពេលដែលអ្នកគិតអំពីការខ្វល់ខ្វាយពីស្នាព្រះហស្ត?

ចម្លើយរបស់អ្នក
- ✓
- ✓
- ✓

## តើតាមរបៀបណាខ្លះដែលយើងអាច... (១០ នាទី)

13. ចាប់ផ្តើមការពិភាក្សារបស់យើងនៅថ្ងៃនេះ តាមរយៈការមើលទៅលើការអស្ចារ្យដែលព្រះអាទិករបានដាក់នៅជុំវិញយើង។ បន្ទាប់មកយើងមើលទៅលើការខូចខាតដែលបានកើតឡើងចំពោះស្នាព្រះហស្ត។

> តើសហគមន៍សកម្មដែលដើរតាមព្រះយេស៊ូអាចធ្វើអ្វីខ្លះដើម្បីរក្សាភាពស្រស់ស្អាត និងស្តារនូវអ្វីដែលបានខូចខាតនេះ?
>
> តើការខ្វល់ខ្វាយពីស្នាព្រះហស្តអាចចូលរួមក្នុងការបង្កើតសហគមន៍សកម្មដែលដើរតាមព្រះយេស៊ូ ដោយរបៀបណាខ្លះ?

ចម្លើយរបស់អ្នក

✓
✓
✓
✓
✓

## សរុបសេចក្តី... (១០ នាទី)

14.តើការខ្វល់ខ្វាយពីស្នាព្រះហស្តបង្កើតការផ្លាស់ប្រែដូចម្តេចខ្លះពេលដែលយើងគិតអំពីការខ្វល់ខ្វាយពីស្នាព្រះហស្តជាគុណតម្លៃដែលប៉ះពាល់ដល់របៀបដែលយើងរស់នៅ និងកិច្ចការដែលយើងធ្វើ (ដូចជាសុចរិតភាព ភាពសប្បុរស ការគោរពអ្នកដទៃ) ជាជាងគិតអំពីសកម្មភាព ឬកម្មវិធីរបស់យើង?

15. ក្នុងនាមយើងជាក្រុម តើជំហានអ្វីដែលយើងនឹងឈានដើម្បីខ្វល់ខ្វាយពីស្នាព្រះហស្តកាន់តែប្រសើរជាងមុន?

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

សូមគិតអំពីសហគមន៍ដែលមិនទាន់លឺដំណឹងល្អដែលយើងបម្រើ ឬអធិស្ឋានឱ្យ។ នៅពេលដែលពួកគេចាប់ផ្តើមសិក្សា និងទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ តើការខ្វល់ខ្វាយពីស្នាព្រះហស្តគឺជាផ្នែកមួយនៃការដើរតាមព្រះយេស៊ូដោយរបៀបណា?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីប្រាំមួយ *បេសកកម្មគ្រប់ជ្រុងជ្រោយ*
ឬមើលវីឌីអូទាំងដប់ពីរស្តីពីការខ្វល់ខ្វាយពីស្នាព្រះហស្តដែលបានមកពី Lausanne Global Classroom តាមរយៈតំណភ្ជាប់៖ https://www.lausanne.org/lausanne-global-classroom/creation-care-episode

## សម្រាប់អ្នកដែលមិនអាចមើលវិឌីអូជាមួយលោកបណ្ឌិត រូបឺត ស្លូកា

សូមមើលខគម្ពីរខាងក្រោម៖

កូឡុស ១:១៥-២០

*ដែលទ្រង់ជារូបអង្គនៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក ១៦*
*ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី*
*ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់*
*ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់*
*ហើយសំរាប់ទ្រង់ទាំងអស់ផង ១៧ ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏ស្ថិតស្ថេរ*
*ដោយសារទ្រង់ ១៨ ទ្រង់ជាសិរសារបស់រូបកាយ គឺជាពួកជំនុំ ទ្រង់ជាដើម*
*ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឱ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់ ១៩*
*ដ្បិតព្រះបានសព្វព្រះហឫទ័យ ឱ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់ ២០*
*ហើយឱ្យបានផ្សះផ្សាគ្រប់ទាំងអស់ ឱ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ*
*ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំងស្ពានមេត្រី*
*ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់។*

គំនិតមួយចេញពីអត្ថបទខគម្ពីរនេះ
គឺមានទំនាក់ទំនងចម្បងបីដែលព្រះយេស៊ូមានជាមួយនឹងស្នាព្រះហស្តរបស់ព្រះអង្គ មិនមែនជាគំរូ (ដូចជាកូនច្បងគេ) នោះទេ ប៉ុន្តែជាអ្វីមួយដែលទ្រង់តែងតែធ្វើ កំពុងតែធ្វើ ឬនឹងធ្វើ។

តើអ្នកអាចកំណត់ប្រភេទទាំងបីនេះបានដែរឬទេ?

ចម្លើយដែលចង់បាន៖

✓
✓
✓

គ្រប់ទាំងស្នាព្រះហស្តទាំងអស់នៅមុខរាជបល្ល័ង្ករបស់ព្រះជាម្ចាស់។
តើស្នាព្រះហស្តសរសើរថ្វាយបង្គំព្រះជាម្ចាស់ដោយរបៀបណា?

*វិវរណៈ ៥:៩-១៣*

*៩ ពួកទាំងនោះក៏ច្រៀងទំនុក ១ ថ្មីថា៖ “ទ្រង់គួរនឹងយកក្រាំងនេះ ហើយនិងបកត្រាផង*
*ដ្បិតទ្រង់បានត្រូវគេធ្វើគុត ហើយទ្រង់បានលោះយើងរាល់គ្នា ដោយព្រះលោហិតទ្រង់*
*ចេញពីគ្រប់ទាំងពូជមនុស្ស គ្រប់ភាសា គ្រប់នគរ ហើយពីគ្រប់ទាំងសាសន៍ ថ្វាយដល់ព្រះ ១០*
*ក៏តាំងយើងរាល់គ្នាឡើងជានគរ ហើយជាពួកសង្ឃ ថ្វាយដល់ព្រះនៃយើងរាល់គ្នា*
*ឱ្យយើងបានសោយរាជ្យលើផែនដី។” ១១ នោះខ្ញុំឃើញ ហើយក៏ឮសំឡេងទេវតាជាច្រើននៅជុំវិញបល្ល័ង្ក*
*ព្រមទាំងតួមានជីវិត និងពួកចាស់ទុំផង ឯចំនួននៃទេវតានោះ មានទាំងម៉ឺនទាំងសែន*
*ហើយទាំងពាន់រាប់ជាពាន់*
*១២ គ្រប់គ្នាក៏បន្លឺសំឡេងថា៖*

*“កូនចៀមដែលគេបានសំឡាប់ នោះគួរនឹងបានព្រះចេស្តា ទ្រព្យសម្បត្តិ ប្រាជ្ញា ឥទ្ធិឫទ្ធិ*
*កិត្តិនាម សិរីល្អ និងព្រះពរ”*

*១៣ នោះខ្ញុំក៏ឮគ្រប់ទាំងអស់ ដែលមានជីវិត នៅស្ថានសួគ៌នៅផែនដី នៅក្រោមដី*
*ហើយនៅក្នុងសមុទ្រ និងគ្រប់ទាំងអស់ដែលនៅស្ថានទាំងនោះនិយាយថា៖ “សូមថ្វាយព្រះពរ កិត្តិនាម*
*សិរីល្អ និងព្រះចេស្តា ដល់ព្រះអង្គដែលគង់លើបល្ល័ង្ក ហើយដល់កូនចៀម*
*នៅអស់កល្បជានិច្ចរៀងរាបតទៅ”*

សូមមើលអត្ថបទខគម្ពីរនេះឱ្យកាន់តែលម្អិតជាងនេះបន្តិច។
តើនរណាជាអ្នកសរសើរតម្កើងព្រះជាម្ចាស់ និងកូនចៀម?

ចម្លើយរបស់អ្នក

✓

✓

✓

តើនេះគឺជាគំនិតថ្មីអំពីព្រះយេស៊ូ និង ស្នាព្រះហស្តសម្រាប់អ្នកមែនទេ?

តើគំនិតទាំងនេះអាចបង្កើតការផ្លាស់ប្រែ  លើកទឹកចិត្តអ្នក ឬជំរុញអ្នកដូម្តេចខ្លះ នៅពេលដែលអ្នកគិតអំពីការខ្វល់ខ្វាយពីស្នាព្រះហស្ត?

សូមមើលទៅកាន់សំណួរទី ១១ ខាងលើ



# គោលការណ៍ទីប្រាំពីរ៖
# និមិត្តសម្រាប់សហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ និងការផ្លាស់ប្តូរបុគ្គលថ្មី និងសហគមន៍។

គោលបំណងនៃការពិភាក្សា៖

1. ក្រុមរបស់ខ្ញុំនឹងទទួលស្គាល់ពីសារៈសំខាន់នៃការស្តាប់អ្នកដទៃ ជាពិសេសគឺអ្នកដើរតាមព្រះយេស៊ូនៅក្នុងសហគមន៍ដែលយើងបម្រើ។

2.ក្រុមរបស់ខ្ញុំនឹងទទួលស្គាល់ពីសារៈសំខាន់ក្នុងការមាននិមិត្តច្បាស់លាស់ពីការបង្កើតសហគមន៍ដែលដើរ តាមព្រះយេស៊ូ។

3. ក្រុមរបស់ខ្ញុំនឹងឃើញទំនាក់ទំនងរបស់ពេលវេលា គោលបំណង និងការបង្ហាញ និងការពន្យល់ពីដំណឹងល្អ។

## ការរំលឹក (៥ នាទី)

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីប្រាំមួយ៖ "ការខ្វល់ខ្វាយពីស្នាព្រះហស្ត គឺជាសកម្មភាពនៃការថ្វាយបង្គំ បន្ទាល់ និងការស្តាប់បង្គាប់"

2. ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន គឺត្រូវគិតអំពីសហគមន៍ដែលមិនទាន់លឺដំណឹងល្អដែលយើងបម្រើ ឬអធិស្ឋានឱ្យ។ នៅពេលដែលពួកគេចាប់ផ្តើមសិក្សា និងទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ តើការខ្វល់ខ្វាយពីស្នាព្រះហស្តគឺជាផ្នែកមួយនៃការដើរតាមព្រះយេស៊ូដោយរបៀបណា?

សូមចំណាយពេល ៣-៤ នាទី ដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## សេចក្តីផ្តើម (១០ នាទី)

3. សប្តាហ៍នេះ យើងនឹងសិក្សាអំពីគោលការណ៍ទីប្រាំពីរ។

គោលការណ៍ទីប្រាំពីរ ការសង្ខេប៖ *"និមិត្តសម្រាប់សហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ និងការផ្លាស់ប្តូរបុគ្គល និងសហគមន៍"*

4. តើយើងអាចឱ្យនិយមន័យនៃពាក្យ "ការផ្លាស់ប្តូរថ្មី" បានយ៉ាងដូចម្តេច?

5. សូមគិតអំពីរឿងដែលបង្ហាញពីលក្ខណៈរបស់ "និមិត្តនៃការផ្លាស់ប្តូរថ្មី និងសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ"។

*នៅដើមឆ្នាំ ២០០០*
*អង្គការបេសកម្មគ្រិស្តបរិស័ទពីរបានចាប់ផ្តើមធ្វើការនៅក្នុងសហគមន៍ដាច់ស្រយាលមួយ*

*នៅក្នុងប្រទេសមួយនៅអាស៊ី។ ការងាររបស់ពួកគេផ្តោតលើសុខភាព និងការអភិវឌ្ឍសហគមន៍ និងការអប់រំក្រៅផ្លូវការ។ សមាជិកក្រុម ទាំងគ្រិស្តបរិស័ទ អ្នកមិនជឿ ព្រមទាំងសមាជិកសហគមន៍បានធ្វើការរួមគ្នា ហើយប៉ុន្មានឆ្នាំក្រោយមកបានឃើញពីការរីកចម្រើននៅក្នុងសុខភាពស្ត្រី និងកុមារ ទឹក និងអនាម័យ សុវត្ថិភាពស្បៀងអាហារ អក្ខរកម្ម និងកត្តាផ្សេងៗទៀត។ អង្គការនោះបានទាក់ទងទៅកាន់ក្រុមជំនុំជាច្រើននៅក្នុងប្រទេសនោះ ហើយចុងក្រោយបានបញ្ជូនគ្រូគង្វាលម្នាក់ដើម្បីដាំក្រុមជំនុំមួយនៅក្នុងតំបន់នោះ។ បុគ្គលិកគ្រិស្តបរិស័ទដែលបានគាំទ្រគាត់ និងបានកសាងទំនាក់ទំនងនៅតាមរបៀបផ្សេងៗ។ តែគួរឱ្យសោកស្តាយដោយសារក្រុមជំនុំនេះត្រូវបានបំបែកទៅជាពីរក្រុមជំនុំប៉ុន្មានឆ្នាំក្រោយមក ដោយសារតែជម្លោះរវាងអ្នកដឹកនាំពីរនាក់ ដែលតម្រូវឱ្យបុគ្គលិកនោះត្រូវគាំទ្រដល់ក្រុមជំនុំទាំងពីរ។ ប្រមាណជាម្ភៃឆ្នាំក្រោយមក មានក្រុមជំនុំដាំងដប់ផ្សេងទៀតត្រូវបានបង្កើតឡើងនៅក្នុងតំបន់នោះ ដែលមានសមាជិកជាង ២០០ នាក់។ ការរីកចម្រើននៅក្នុងសហគមន៍កាន់តែប្រសើរឡើងតាមរយៈកិច្ចការរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ ក្រុមជំនុំជាច្រើនក៏បានបម្រើសហគមន៍តាមរបៀបផ្សេងៗគ្នាផងដែរ។*

លោក ម៉ាក ហ្គាលភីន បានសរសេរនៅក្នុងសៀវភៅ បេសកកម្មគ្រប់ជ្រុងជ្រោយ ថារឿងនេះគឺបង្ហាញពីបញ្ហាប្រឈម និងឱកាសនៅក្នុងការអភិវឌ្ឍសហគមន៍ និងការដាំក្រុមជំនុំនៅតាមសហគមន៍ដែលមិនទាន់លឺដំណឹងល្អ។

តើអង្គការបេសកកម្មនេះមានបញ្ហាប្រឈមចំពោះមុខអ្វី?

ចម្លើយរបស់អ្នក

6. មានកម្រិតផ្សេងៗគ្នានៃការផ្លាស់ប្តូរថ្មី (ឬការផ្លាស់ប្រែ) ដែលបានកើតឡើងនៅក្នុងសហគមន៍។ សម្រាប់យើង ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូ មានកម្រិតសេរីភាពផ្សេងៗគ្នាក្នុងការប្រកាសទៅតាមពេលវេលាខុសៗគ្នា។

តើអ្នកចង់ឱ្យមនុស្សនៅក្នុងសហគមន៍ទទួលបានបទពិសោធន៍ក្នុងការផ្លាស់ប្តូរថ្មី ឬសេរីភាពក្នុងចំណុចណាខ្លះ?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓

## តែងតែត្រូវត្រៀមខ្លួន (១០ នាទី)

7. គោលការណ៍ទីប្រាំពីរ បង្ហាញពីតម្រូវការក្នុងការមាននិមិត្ត និងមានគោលបំណង។ រួមបញ្ចូលទាំងការត្រៀមខ្លួន។ សូមមើលពីអ្វីដែលលោកពេត្រុសនិយាយអំពីរឿងនេះ។

*ចូរឱ្យតាំងព្រះគ្រីស្ទឡើង ជាបរិសុទ្ធ នៅក្នុងចិត្តអ្នករាល់គ្នា ទុកជាព្រះអម្ចាស់ចុះ*
*ហើយឱ្យប្រុងប្រៀបជានិច្ច ដោយសុភាព ហើយកោតខ្លាច*
*ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នា*
*ព្រមទាំងមានបញ្ញាចិត្តជ្រះថ្លា ដើម្បីឱ្យពួកអ្នកដែលនិយាយដើមពីអ្នករាល់គ្នា*
*ទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ បានអៀនខ្មាសវិញ*
*ដោយព្រោះគេនិយាយបង្កាច់ពីកិរិយាល្អដែលអ្នករាល់គ្នាប្រព្រឹត្តក្នុងព្រះគ្រីស្ទ (NLT)*

8. តើ "ការត្រៀមខ្លួន" មានន័យដូចម្តេចដើម្បីធ្វើការពន្យល់? តើគំនិតនេះសមស្របនឹងគំនិតក្នុង "ការបង្ហាញ និងការពន្យល់" អំពីដំណឹងល្អក្នុងរបៀបរួបរួមដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓

9. តើយើងស្គាល់ឱកាសក្នុងការពន្យល់ពីក្តីសង្ឃឹមដែលយើងមានដោយរបៀបណា? តើយើងអាចដឹងថាយើងគួរ ឬមិនគួរចែកចាយដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓

10. ពេលខ្លះ តើអ្នកធ្លាប់មានអារម្មណ៍ថាអ្នកមានឱកាសដើម្បី "ពន្យល់ពីក្តីសង្ឃឹមដែលអ្នកមាន" ប៉ុន្តែអ្នកមិនមានទំនុកចិត្តដែរឬទេ?

តើអ្នកអាចបង្កើតទំនុកចិត្តនេះបានដោយរបៀបណា
ដើម្បីឱ្យអ្នកអាចត្រៀមខ្លួននៅពេលដែលពេលមកដល់?
តើកិច្ចការជាក់លាក់ណាខ្លះដែលអ្នកអាចធ្វើបានដើម្បី "កសាងជំនួយរបស់អ្នក"
ដើម្បីឱ្យអ្នកត្រៀមខ្លួនដើម្បីពន្យល់?

ចម្លើយរបស់អ្នក

✓
✓
✓

11. តើពាក្យថា "ធ្វើកិច្ចការនេះដោយសុភាព និងដោយក្តីគោរព" នៅក្នុងបរិបទរបស់អ្នក មានន័យយ៉ាងដូចម្តេច?□□

ចម្លើយរបស់អ្នក

✓
✓
✓

## ត្រូវប្រយ័ត្នអំពីពេលវេលា (១០ នាទី)

12. យើងចង់ឱ្យគ្រប់ឱកាសទាំងអស់ដែលយើងមានត្រូវបានប្រើប្រាស់ឱ្យមានប្រសិទ្ធភាព មានគោលបំណងច្បាស់លាស់ និងរៀបចំឱ្យបានល្អ។ យ៉ាងណាមិញ ការពិតនោះគឺនឹងមានពេលដែល "ការពន្យល់" ពីដំណឹងល្អអាចមានគុណវិបត្តិជាជាងគុណសម្បត្តិ។
តើពេលណាដែលវាអាចទៅជាបែបនេះបាន?

ចម្លើយរបស់អ្នក
✓
✓
✓
✓

13.តើអ្នកធ្វើឱ្យមានតុល្យភាពរវាងអារម្មណ៍ពីឱកាសក្នុងពេលនេះធៀបនឹងការគិតរយៈពេលវែងដោយរបៀបណា?

នៅក្នុងជំពូកនេះដែលនិយាយអំពី "ការប្រកាសដំណឹងល្អប្រកបដោយសីលធម៌" ក្នុងសៀវភៅបេសកកម្មគ្រប់ជ្រុងជ្រោយ លោកម៉ាក ហ្គាលភីន ចង់និយាយអំពីការឆ្លើយតបផ្សេងៗ—យ៉ាងហោចណាស់គឺពេលវេលា—រហូតដល់រឿងដែលគាត់ប្រាប់លើកមុន បានបញ្ជាក់អំពីការចាប់ផ្តើមការសម្រេចចិត្ត។

*ភ្លាមៗបន្ទាប់ពីគ្រោះរញ្ជួយដីនៅក្នុងប្រទេសនេប៉ាល់កាលពីឆ្នាំ ២០១៥ អង្គការគ្រិស្តបរិស័ទជាច្រើនបានចូលមកដើម្បីផ្តល់ជំនួយ។ នៅក្នុងការប្រជុំអង្គការគ្រិស្តបរិស័ទផ្តល់ជំនួយដែលខ្ញុំបានចូលរួមនោះ មានអ្នកតំណាងអង្គការមួយបានចែកចាយអំពីការខិតខំប្រឹងប្រែងរបស់ខ្លួនដំណើរការបានល្អ ប៉ុន្តែវាគឺជា "ការលំបាកក្នុងការបញ្ចូលដំណឹងល្អចូលទៅក្នុងជំនួយរបស់ពួកគេ"។*

*ក្នុងនាមជាមនុស្សម្នាក់ដែលនៅក្នុងបន្ទប់នោះដែលមានបទពិសោធន៍ប៉ុន្មានសប្តាហ៍នៅក្នុងប្រទេសនេប៉ាល់ ខ្ញុំក៏បានឆ្លើយតបយ៉ាងច្បាស់ៗថា មិនថាក្នុងកាលៈទេសៈណាក៏ដោយ សូមកុំព្យាយាមបញ្ចូលដំណឹងល្អនៅក្នុងជំនួយរបស់ពួកគេ។ ហេតុអ្វីបានជាខ្ញុំមានអារម្មណ៍បែបនេះ? ខ្ញុំបានដឹងយ៉ាងច្បាស់ថានៅក្នុងប្រទេសនេប៉ាល់ តែងតែការចោទប្រកាន់ថាការអង្គការគ្រិស្តបរិស័ទតែងតែ "បញ្ឆោះបញ្ចូល" និងបង្ខំមនុស្សឱ្យក្លាយជាគ្រិស្តបរិស័ទ។ បន្ទាប់ពីគ្រោះរញ្ជួយដី រដ្ឋាភិបាលតែងតែឃ្លាំមើលលើរឿងនេះ។ ប្រសិនបើមានសញ្ញានៃការបញ្ឆោះបញ្ចូល មិនត្រឹមតែបំផ្លាញកេរ្តិ៍ឈ្មោះអង្គការខ្លួនឯងនោះទេ ប៉ុន្តែក៏អាចបំផ្លាញដល់គ្រិស្តបរិស័ទផ្សេងទៀតផងដែរ។ វានឹងនាំឱ្យមានផ្នត់គំនិតអវិជ្ជមានលើដំណឹងល្អ និងអាចធ្វើឱ្យមានការហាមឃាត់គ្រិស្តបរិស័ទពីការផ្តល់ជំនួយ និងការសាងសង់ឡើងវិញ ដែលអាចកាត់បន្ថយជំនួយ និងការគាំទ្រក្នុងពេលដែលកំពុងតែត្រូវការ។*

*ក្រុមជំនុំនៅក្នុងប្រទេសនេប៉ាល់ បានដឹងថានេះគឺជាពេលដែលត្រូវជួប និងជួយមនុស្សភ្លាមៗ ហើយមិនត្រូវបញ្ចូលការប្រកាសដំណឹងល្អនោះទេ។ តាមរយៈការធ្វើបែបនេះ ពួកគេមានទំនុកចិត្តថាពេលនេះ គឺជាពេលដែលពួកគេគឺជាបន្ទាល់ពីសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត មិនថាពួកគេមានជំនឿបែបណានោះទេ។ នឹងមានពេលដែលពួកគេអាចប្រកាសដំណឹងល្អ ប៉ុន្តែនេះគឺជាពេលដែលត្រូវបង្ហាញ។*

*អង្គការបានបញ្ជាក់ថា ពួកគេមិនយល់ពីបរិបទនេះទេ។ យុទ្ធសាស្ត្ររបស់ពួកគេគឺពួកគេយល់ថា ពួកគេកំពុងតែធ្វើ "បេសកកម្មគ្រប់ជ្រុងជ្រោយ" ដោយខ្លួនឯងនៅក្នុងស្ថានភាពនេះ។ ការយល់ឃើញបែបនេះ គឺបណ្តាលមកពីការដាក់កម្រិត និងការយល់ដឹងមានកម្រិតអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ ក្នុងករណីនេះ*

*ពួកគេធ្វើឱ្យមានគុណវិបត្តិជាជាងគុណសម្បត្តិ។*

ក. តាមរយៈរឿងនេះ តើមានការយល់ឃើញអ្វីខ្លះដែលត្រឹមត្រូវ
និងអ្វីខ្លះដែលខុសចំពោះអ្នកដែលនៅខាងក្រៅមកលើអង្គការគ្រិស្តបរិស័ទ?
មុនពេលប្រជុំនេះ តើពួកគេស្តាប់នរណា?

ចមម្លើយអាចជា៖

✓
✓
✓

ខ. តើការយល់ឃើញពីខាងក្រៅគិតយ៉ាងដូចម្តេចមកលើក្រុមជំនុំនៅប្រទេសនេប៉ាល់?
តើអ្វីទៅដែលជានិមិត្តរបស់ពួកគេ? ហេតុអ្វីបានជាការយល់ឃើញរបស់ពួកគេសំខាន់?

ចម្លើយរបស់អ្នក

✓
✓
✓

គ. តាមរយៈរឿងនេះ តើវាបានប្រាប់យើងអ្វីខ្លះអំពីការបញ្ចូល ក) គោលបំណង និងនិមិត្ត
ជាមួយនឹង ខ) ការមើលឃើញរយៈពេលយូរអង្វែង និងចំណុចរសើបចំពោះពេលវេលា?

ចម្លើយរបស់អ្នក

✓
✓
✓

ឃ. តើរឿងនេះបានណែនាំយើងអំពីរបៀបក្នុងការបញ្ចូល “ការបង្ហាញ” និង “ការពន្យល់”
ដំណឹងល្អដូចម្តេចខ្លះ?

ចម្លើយរបស់អ្នក

✓
✓
✓

## សេចក្តីសន្និដ្ឋាន (១០ នាទី)

14. ផ្នែកចុងក្រោយក្នុងសៀវភៅ ១ ពេត្រុស ៣:១៦ ប្រាប់យើងថា “ព្រមទាំងមានបញ្ញាចិត្តជ្រះថ្លា ដើម្បីឱ្យពួកអ្នកដែលនិយាយដើមពីអ្នករាល់គ្នា ទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ បានអៀនខ្មាសវិញ ដោយព្រោះគេនិយាយបង្កាច់ពីកិរិយាល្អដែលអ្នករាល់គ្នាប្រព្រឹត្តក្នុងព្រះគ្រិស្ទ។”

ហេតុអ្វីបានជាវាគឺជារឿងសំខាន់ក្នុងការរស់ជាជីវិតល្អក្នុងចំណោមប្រជាជននៅក្នុងសហគមន៍?
តើមានអ្វីកើតឡើងប្រសិនបើយើងជាជីវិតល្អ?

15. តាមរយៈការពិភាក្សាថ្ងៃនេះ តើមានចំណុចលេចធ្លោអ្វីសម្រាប់អ្នក? តើអ្នកបានរៀនអ្វីដើម្បីជួយឱ្យអ្នក និងក្រុមរបស់អ្នកអាចអនុវត្តបាន?

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

នៅក្នុងមេរៀននេះ យើងបានសិក្សាអំពីសារៈសំខាន់ក្នុងការមាននិមិត្ត និងគោលបំណងច្បាស់លាស់ប្រសិន បើយើងមានបំណងចិត្តចង់ឃើញការផ្លាស់ប្តូរកើតឡើង។ តើក្រុមរបស់អ្នកមាននិមិត្ត និងគោលបំណងច្បាស់លាស់ដែរឬទេ? តើអ្នកអាចធ្វើឱ្យប្រសើរជាងមុនដោយរបៀបណាខ្លះ?

តើអ្នកមើលឃើញសហគមន៍ដែលដើរតាមព្រះយេស៊ូបានចូលរួមបង្កើតការផ្លាស់ប្រែនៅក្នុងសហគមន៍ដែលអ្នករស់នៅ និងបម្រើតាមរបៀបណាខ្លះ?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីប្រាំពីរ និងការឆ្លុះបញ្ចាំងពីការផ្សាយដំណឹងល្អប្រកបដោយសីលធម៌
*បេសកកម្មគ្រប់ជ្រុងជ្រោយ*



# គោលការណ៍ទីប្រាំបីៈ ក្រុមការងារអភិវឌ្ឍន៍សហគមន៍ ប្តេជ្ញាធ្វើការឱ្យបានល្អប្រសើរប្រកបដោយវិជ្ជាជីវៈ

គោលបំណងនៃការពិភាក្សាៈ
1. ក្រុមរបស់យើងនឹងយល់កាន់តែច្បាស់ពីរបៀបដែលការធ្វើការអាចក្លាយជាសកម្មភាពនៃការថ្វាយបង្គំ។
2. យើងក៏នឹងយល់កាន់តែច្បាស់អំពីអត្ថន័យនៃការធ្វើការឱ្យបានល្អប្រសើរប្រកបដោយវិជ្ជាជីវៈ និងមូលហេតុដែលវាសំខាន់នៅពេលដែលយើងបម្រើសហគមន៍។

## ការរំលឹក (៥ នាទី)

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីប្រាំពីរៈ
"ការផ្លាស់ប្រែពិតប្រាកដត្រូវការនិមិត្តសម្រាប់សហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ និងការផ្លាស់ប្តូរថ្មីនៃបុគ្គល និងសហគមន៍"

ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវគិតពិចារណាថាតើប្រភេទនៃនិមិត្ត និងគោលបំណងគឺជាការពិតនៃអ្នក និងក្រុមរបស់អ្នក។ តើអ្នកអាចធ្វើឱ្យប្រសើរជាងមុនដោយរបៀបណាខ្លះ?

តើអ្នកមើលឃើញសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូបានចូលរួមបង្កើតការផ្លាស់ប្រែនៅក្នុងសហគមន៍ដែលអ្នករស់នៅ និងបម្រើតាមរបៀបណាខ្លះ?

សូមចំណាយពេល ៣-៤ នាទីដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## តើការធ្វើការឱ្យបានល្អប្រសើរប្រកបដោយវិជ្ជាជីវៈគឺជាអ្វី? (១០-១៥ នាទី)

2. សប្តាហ៍នេះ យើងនឹងសិក្សាអំពីគោលការណ៍ទីប្រាំបី។

> គោលការណ៍ទីប្រាំបី ការសង្ខេបៈ
> *"ក្រុមការងារអភិវឌ្ឍន៍សហគមន៍ប្តេជ្ញាធ្វើការឱ្យបានល្អប្រសើរប្រកបដោយវិជ្ជាជីវៈ"*

3. សូមចាប់ផ្តើមដោយយល់ពីអត្ថន័យរបស់យើងអំពីការធ្វើការឱ្យបានល្អប្រសើរប្រកបដោយវិជ្ជាជីវៈ។ តើយើងអាចឱ្យនិយមន័យនៃពាក្យ "ប្រកបដោយវិជ្ជាជីវៈ" បានយ៉ាងដូចម្តេច?

ចម្លើយរបស់អ្នក

4. ពាក្យមួយទៀតដែលយើងនឹងមើលនោះគឺ “ភាពល្អប្រសើរ”។ តើអ្នកយល់យ៉ាងដូចម្តេចអំពីគំនិតនៃភាពល្អប្រសើរ?

ចម្លើយរបស់អ្នក

5. ជាទូទៅមនុស្សតែងតែភ្ញាក់ផ្អើលនឹងភាពល្អប្រសើរ ដោយសារតែភាពល្អប្រសើរគឺលើសពីអ្វីដែលជាតម្រូវការអប្បបរមា។

ក. សូមគិតអំពីរឿងនាងរស់ដែលបានចែងនៅក្នុងព្រះគម្ពីរ។ ប្រសិនបើនាងរស់ និងលោកបូអូសធ្វើត្រឹមតែអ្វីដែលជាតម្រូវការអប្បបរមារបស់ច្បាប់ ឬសង្គម ប្រហែលជានឹងមានរឿងផ្សេងកើតឡើងសម្រាប់ពួកគេ។
ខ. តើនាងរស់បានធ្វើលើសពីការរំពឹងទុកអ្វីខ្លះ?

គ. ចុះសម្រាប់លោកបូអូសវិញ? តើលោកបានធ្វើលើសពីអ្វីដែលតម្រូវឱ្យធ្វើដោយរបៀបណាខ្លះ?

ឃ. តាមរយៈការធ្វើលើសពីអ្វីដែលតម្រូវឱ្យធ្វើ តើពួកគេទទួលបានលទ្ធផលអ្វី?

6. យើងអាចនិយាយបានថា សកម្មភាពរបស់នាងរស់ និងលោកបូអូសគឺជាសកម្មភាពនៃការថ្វាយបង្គំ ដោយសារតែពួកគេបានថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។ សកម្មភាពរបស់ពួកគេបង្ហាញពីសេចក្តីស្រឡាញ់ដែលថែទាំដោយភាពស្មោះត្រង់របស់ព្រះជាម្ចាស់។ ការងាររបស់យើងក៏អាចជាសកម្មភាពនៃការថ្វាយបង្គំដែរ។ តាមរយៈការងាររបស់អ្នក តើអ្នកបានឃើញថាវាគឺជាសកម្មភាពនៃការថ្វាយបង្គំដោយរបៀបណាខ្លះ?

ចម្លើយរបស់អ្នក

7. ការងារគឺជាអំណោយទានពីព្រះជាម្ចាស់ដែលបានប្រទានមកលោកអាដាំ និងនាងអេវ៉ាមុនពេលពួកគេប្រព្រឹត្តិអំពើបាប។ ការងាររបស់យើង មិនត្រឹមតែជាលទ្ធផល "អាក្រក់" បានមកពីអំពើបាបនោះទេ។

- អត្ថបទគម្ពីរប្រាប់យើងថា ការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឱ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់។ (កូឡុស ៣:២៣)
- អត្ថបទគម្ពីរក៏ប្រាប់យើងថា យើងជាពួកសង្ឃហ្លួង ។ (១ ពេត្រុស ២:៩) សំដៅទៅលើជីវិតរបស់យើងទាំងមូល មិនមែនគ្រាន់តែសកម្មភាពនានានៅក្នុងសាសនានោះទេ។

8. សូមគិតអំពីកិច្ចការដែលយើងធ្វើ។ នៅក្នុងកិច្ចការដែលយើងធ្វើ តែងតែមានស្តង់ដារសម្រាប់យើង (ពីរដ្ឋាភិបាល អង្គការវិជ្ជាជីវៈ សមាគមន៍ ស្ថាប័ន សហព័ន្ធ មនុស្សផ្តល់ការទទួលស្គាល់ ។ល។)។ ឧ. នៅក្នុងប្រទេសជាច្រើន ត្រូវចុះបញ្ជីធ្វើជាគិលានុបដ្ឋាយិកា ឬគ្រូពេទ្យ។ អ្នកអាចមានសមត្ថភាពគ្រប់គ្រាន់ ប៉ុន្តែអ្នកនៅតែត្រូវចុះឈ្មោះនៅក្នុងប្រទេសដែលអ្នកចង់ធ្វើការ។

តើស្តង់ដារវិជ្ជាជីវៈអ្វីខ្លះ សម្រាប់យើង និងមនុស្សដែលមានការងារស្រដៀងគ្នាក្នុងសហគមន៍របស់យើង? វាអាចជាស្តង់ដារដែលអ្នកបានបង្កើតឡើងដោយក្រុមអ្នកផ្ទាល់ ឬអ្នកដឹកនាំរបស់អ្នក។

ចម្លើយរបស់អ្នក

✓
✓
✓

9. សម្រាប់យើង ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូ យើងមានស្តង់ដារយោងតាមគុណតម្លៃព្រះគម្ពីរ។ ឧ. អត្ថបទខគម្ពីរបានប្រាប់យើងថា ចូរឱ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ (យ៉ាកុប ១:១៩)។ តើមានស្តង់ដារអ្វីខ្លះដែលយោងតាមគុណតម្លៃព្រះគម្ពីរ?

ចម្លើយរបស់អ្នក

✓
✓
✓

10. យើងមានភាគីពាក់ព័ន្ធជាច្រើន។

*ភាគីពាក់ព័ន្ធគឺជាអ្នកដែលចាប់អារម្មណ៍លើគម្រោង ឬសកម្មភាពរបស់យើង។ ពួកគេអាចទទួលលទ្ធផល (ល្អ ឬមិនល្អ) ពីគម្រោងរបស់យើង។ ភាគីពាក់ព័ន្ធរួមមានសហគមន៍ដែលយើងបម្រើ អ្នកខាងក្រៅដែលជួយដល់គម្រោង រដ្ឋាភិបាល ម្ចាស់ជំនួយ និងភាគីផ្សេងៗទៀត។ "ភាគីពាក់ព័ន្ធចម្បងៗ" គឺជាអ្នកដែលទទួលផលប៉ះពាល់ខ្លាំងពីគម្រោង ឬអ្នកដែលវិនិយោគធំជាងគេនៅក្នុងគម្រោងនេះ។*

សហគមន៍ដែលយើងបម្រើ ភាគច្រើនគឺជាភាគីពាក់ព័ន្ធដែលត្រូវបានមើលរំលង។ យើងចង់ផ្តល់តម្លៃដល់ពួកគេ។ ពួកគេត្រូវបានបង្កើតឡើងស្របតាមលក្ខណៈរបស់ព្រះជាម្ចាស់។ មនុស្សជាច្រើនចូលមកសហគមន៍ ហើយ "ប្រាប់" ពួកគេពីអ្វីដែលពួកគេត្រូវការ ប៉ុន្តែយើងចង់ស្តាប់ពីពួកគេ។ ព្រះជាម្ចាស់បានផ្តល់ឱ្យពួកគេមានសមត្ថភាពក្នុងការធ្វើកិច្ចការល្អៗសម្រាប់ពួកគេ ហើយធ្វើដោយភាពល្អប្រសើរ យើងចង់ទាញភាពល្អប្រសើរចេញពីពួកគេ។ ដើម្បីធ្វើកិច្ចការទាំងអស់នេះបាន យើងត្រូវតែបង្កើតទំនាក់ទំនងជាមួយពួកគេជាមុនសិន។

ពេលនោះ សហគមន៍នឹងក្លាយទៅជាម្ចាស់លើសកម្មភាព ឬគម្រោងដែលយើងធ្វើ ជាជាងទទួលយកគម្រោង ឬសកម្មភាពពីខាងក្រៅ។

11. សូមគិតអំពីគម្រោងដែលយើងចូលរួមធ្វើ (ឬគម្រោងដែលយើងស្គាល់ ឬអាចនឹងចូលរួមធ្វើ)។ តើនរណាគឺជាភាគីពាក់ព័ន្ធ?

ចម្លើយរបស់អ្នក

✓
✓
✓

នៅក្នុងស្ថានភាពជាក់លាក់របស់យើង
តើភាគីពាក់ព័ន្ធសំខាន់ៗរបស់យើងនៅក្នុងសហគមន៍រំពឹងអ្វីខ្លះពីយើង?

ចម្លើយរបស់អ្នក

✓
✓
✓

12. លោក ហ្គាប្រីអែល ម៉ាយើស
បានប្រាប់យើងពីរឿងដ៏សំខាន់មួយអំពីសហគមន៍ដែលយើងបម្រើនោះ គឺជាភាគីពាក់ព័ន្ធ។

*ដូចដែលបានបញ្ជាក់ខាងលើនៅក្នុងវគ្គបណ្តុះបណ្តាលរបស់យើង ខ្ញុំបានសម្របសម្រួលគម្រោងសាងសង់ដ៏ធំមួយនៅក្នុងប្រទេសស្រីលង្កា មួយថ្ងៃបន្ទាប់ពីថ្ងៃគ្រីស្តម៉ាស់ក្នុងឆ្នាំ ២០០៤ រលកយក្សស៊ូណាមិបានធ្វើឱ្យប្រជាជនរាប់ពាន់អ្នកគ្មានផ្ទះសម្បែង។ មានពេលព្រឹកមួយខ្ញុំបានទទួលទូរសព្ទពីសហការីដែលជាភ្នាក់ងារដៃគូអឺរ៉ុបះ គាត់បានសុំខ្ញុំឱ្យមកលឿនតាមតែអាចធ្វើទៅបាន ដោយសារមានមនុស្សម្នាក់កាន់ប៉ែលដេញតាម និងគំរាមសម្លាប់គាត់។*

*ភ្លាមៗនោះ ខ្ញុំក៏បើកឡានទៅទីតាំងភ្លាម ហើយបានជួយឱ្យគាត់ស្ងប់អារម្មណ៍។ បុរសអឺរ៉ុបនោះមិនដឹងថាគាត់បានធ្វើខុសអ្វីនោះទេ បានជាគាត់ខឹងខ្លាំងណាស់— ប៉ុន្តែគាត់មានអារម្មណ៍ថាបុរសស្រីលង្កានោះមិនបានដឹងគុណដល់កិច្ចការដែលបានធ្វើនោះទេ។ ខ្ញុំបានមើលទៅបុរសស្រីលង្កានោះ ហើយក៏និយាយភាសាស្រីលង្កាជាមួយគាត់ សួរអំពីរឿងនេះ។ គាត់បាននិយាយថា "យើងដឹងគុណ ប៉ុន្តែពួកគេមិនស្តាប់យើងនោះទេ"*

*ចុងក្រោយនោះគឺ បុរសអឺរ៉ុបនោះមានប្លង់ផ្ទះល្អ—ប៉ុន្តែភ្លេចរឿងដ៏សំខាន់មួយ។ សម្រាប់អ្នកភូមិហិណ្ឌូ ទ្វារផ្ទះត្រូវបែរទៅទិសខាងកើតដើម្បីទទួលពរពីព្រះអាទិត្យរះ (នោះបីផ្លូវនៅខាងណាក៏ដោយ)។ បុរសអឺរ៉ុបមិនបានស្តាប់ ហើយវិះនឹងបានសាងសង់ផ្ទះនេះទៀត ដែលធ្វើឱ្យអ្នកភូមិមិនបានដឹងគុណលើការសាងសង់ផ្ទះនេះទេ (វិះតែនឹងបាត់បង់ជីវិតបុគ្គលិកអង្គការនេះទៀត)។*

រឿងនេះប្រាប់យើងអំពីសារៈសំខាន់ក្នុងការស្តាប់សហគមន៍ដែលយើងបម្រើ និងស្វែងយល់អំពីអ្វីដែលសំខាន់សម្រាប់ពួកគេ។ លើសពីរឿងដ៏សំខាន់នេះ នៅក្នុងស្ថានភាពរបស់យើង តើភាគីពាក់ព័ន្ធសំខាន់ៗរបស់យើងទាំងសហគមន៍ និងភាគីផ្សេងៗទៀត (រួមបញ្ចូលទាំងម្ចាស់ជំនួយ និងមន្ត្រីរដ្ឋាភិបាល) រំពឹងអ្វីខ្លះពីយើងដែលពាក់ព័ន្ធនឹងពួកគេ?

ចម្លើយរបស់អ្នក

ការឆ្លុះបញ្ចាំង/សេចក្ដីសន្និដ្ឋាន (១០ នាទី)

13. យើងឃើញហើយថាមានការរំពឹងសម្រាប់យើងពីក្រុមរបស់យើង អាជ្ញាធរខាងក្រៅ ពីសហគមន៍ពីភាគីផ្សេងៗទៀត និងពីព្រះជាម្ចាស់។

សូមគិតអំពីតួនាទីរបស់អ្នក។ មិនមែនតែការអភិវឌ្ឍសហគមន៍នោះទេ ប៉ុន្តែក៏សម្រាប់កិច្ចការផ្សេងៗដែលអ្នកធ្វើដែរ។ ពេលដែលវាយតម្លៃការងាររបស់អ្នក តើការធ្វើត្រឹមអប្បបរមានៃការរំពឹងទុក និងការធ្វើឱ្យល្អប្រសើរ មានលក្ខណៈខុសគ្នាអ្វីខ្លះ?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓

14. ពេលដែលយើងប្ដេជ្ញាធ្វើឱ្យល្អប្រសើរប្រកបដោយវិជ្ជាជីវៈ តើវាបានធ្វើឱ្យយើងធ្វើជាបន្ទាល់មានលក្ខណៈបែបណាខ្លះ?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓

15. តាមរយៈការពិភាក្សាថ្ងៃនេះ តើមានចំណុចលេចធ្លោអ្វីខ្លះសម្រាប់អ្នក? ហេតុអ្វី?

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

នៅក្នុងសហគមន៍ដែលខ្ញុំបម្រើ ឬសង្ឃឹមថានឹងបម្រើ
តើមានចំណុចណាខ្លះដែលខ្ញុំត្រូវរីកចម្រើនជំនាញវិជ្ជា  ជីវៈរបស់ខ្ញុំថែមទៀត?
តើខ្ញុំអាចអភិវឌ្ឍជំនាញទាំងនោះបានដោយរបៀបណា?
ដោយសារតែខ្ញុំមិនអាចធ្វើកិច្ចការទាំងអស់ដោយខ្លួនឯងបាន តើខ្ញុំ (ឬក្រុមរបស់ខ្ញុំ) ត្រូវការជំនួយ ឬដំបូន្មានពីអ្នកដែលប្រកបដោយជំនាញវិជ្ជាជីវៈនៅក្នុងផ្នែកណាខ្លះ?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីប្រាំបី *បេសកកម្មគ្រប់ជ្រុងជ្រោយ*



# គោលការណ៍ទីប្រាំបួន៖ គោលការណ៍ភាពល្អប្រសើរ

គោលបំណងនៃការពិភាក្សា៖
1. ក្រុមរបស់ខ្ញុំនឹងឃើញរបៀបដែលភាពល្អប្រសើរនៃការអភិវឌ្ឍសហគមន៍ និងគោលការណ៍ VCJF ជួយបំពេញគ្នាទៅវិញទៅមក។
2. ក្រុមរបស់ខ្ញុំនឹងឃើញរបៀបនៃការអភិវឌ្ឍសហគមន៍សម្របខ្លួនខំប្រឹងប្រែងអនុវត្តដើម្បីមើលឃើញសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូបានបង្កើតឡើង និងរីកចម្រើន។

## ការរំលឹក (៥ នាទី)

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីប្រាំបី៖ ដំណឹងល្អជះឥទ្ធិពលដល់លក្ខណៈទាំងអស់របស់មនុស្ស និងលក្ខណៈទំនៀមទម្លាប់ទាំងអស់ ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវគិតទៅលើចំណុចដែលខ្ញុំត្រូវ រីកចម្រើនជំនាញវិជ្ជាជីវៈរបស់ខ្ញុំ។ តើខ្ញុំអាចអភិវឌ្ឍជំនាញទាំងនោះបានដោយរបៀបណា? ដោយសារតែខ្ញុំមិនអាចធ្វើកិច្ចការទាំងអស់ដោយខ្លួនឯងបាន តើខ្ញុំ (ឬក្រុមរបស់ខ្ញុំ) ត្រូវការជំនួយ ឬដំបូន្មានពីអ្នកដែលប្រកបដោយជំនាញវិជ្ជាជីវៈនៅក្នុងផ្នែកណាខ្លះ?

2. សូមចំណាយពេល ៣-៤ នាទីដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

## សេចក្តីផ្តើម (៣ នាទី)

3. សប្តាហ៍នេះ យើងនឹងសិក្សាអំពីគោលការណ៍ទីប្រាំបួន។

គោលការណ៍ទីប្រាំបួន ការសង្ខេប៖
*“មានគោលការណ៍ភាពល្អប្រសើរច្រើនណាស់នៅក្នុងការអភិវឌ្ឍសហគមន៍ និងការបង្កើតសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ។”*

4. សូមស្តាប់ពីបទពិសោធន៍របស់អ្នកស្រី អេនគ្រ្គា ដែលនិយាយអំពីថ្ងៃគ្រិស្តម៉ាស់មួយនៅតំបន់អាស៊ីកណ្តាល ថាតើយើងអាចរៀនបានអ្វីខ្លះពីខ្លួនឯង។

> *ពេលល្ងាចមួយមុនបុណ្យគ្រិស្តម៉ាស់នៅក្នុងទីក្រុងដ៏តូចមួយនៅតំបន់អាស៊ីកណ្តាល អ្នកស្រី អេនគ្រ្គា បានចម្អិនអាហារពីផ្ទះរបស់គាត់ ដែលគាត់បានគិតថាការចម្អិនម្ហូបនេះនឹងមិនចម្លែកសម្រាប់មិត្តភក្តិគាត់នោះទេ៖ មាន់ដុតបន្លែស្ងោ និងបាយ។*
>
> *តាមប្រពៃណី គាត់បានលាតកម្រាលតុ និងបានយកម្ហូបមកជូនមិត្តភក្តិរបស់គាត់។ ពួកគេបានហុចម្ហូបទៅវិញទៅមក ខ្លះញ៉ាំមាន់ ហើយខ្លះទៀតមិនញ៉ាំមាន់។*
>
> *ដោយអស់ភាពអត់ធ្មត់ អេនគ្រ្គាបានសួរថា “ហេតុអ្វីបានជាអ្នករាល់គ្នាមិនញ៉ាំមាន់នេះ? នេះគ្រឿងផ្សំមិនខុសពីមាន់ពីលូនោះទេ” អាស្លូនីស មិត្តរបស់នាងមើលទៅអេនគ្រ្គាក៏ឆ្លើយថា “មែនហើយ បើដឹងហើយ ហេតុអ្វីបានចម្អិនដាច់ដោយឡែកបែបនេះ បើចម្អិនជាមួយគ្នាវាមានរសជាតិឆ្ងាញ់ជាង?”*

ក. បើមើលពីជីវិតរបស់យើងវិញ តើនេះមានអត្ថន័យយ៉ាងដូចម្ដេច? តើជីវិតរបស់យើងគឺជាជីវិតរួមគ្នា ឬដាច់ដោយឡែក?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓

ខ. តើដំណើរជីវិតរួមគ្នាមានអត្ថប្រយោជន៍អ្វីខ្លះ? តើដំណើរជីវិតដាច់ដោយឡែកពីគ្នាមានអត្ថប្រយោជន៍អ្វីខ្លះ?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓
- ✓

5. ពេលដែលអ្នកត្រលប់ទៅគិតអំពីការពិភាក្សាវិញ តាមរយៈរឿងនេះ តើវាបានធ្វើឱ្យអ្នកគិតអ្វីខ្លះអំពីពាក្យ "បេសកកម្មគ្រប់ជ្រុងជ្រោយ" "ការបង្ហាញ និងការពន្យល់ពីដំណឹងល្អ" ការអភិវឌ្ឍសហគមន៍ និងសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ?

ចម្លើយរបស់អ្នក

- ✓
- ✓
- ✓
- ✓

## ការប្រៀបធៀបគោលការណ៍ (១០-២០ នាទី)

6. អង្គការ OM បានបង្កើត "គោលការណ៍ VCJF ទាំងដប់ដើម្បីជួយតម្រង់ព័ន្ធកិច្ចរបស់យើង"។ គោលការណ៍ទាំងនេះមានគោលការណ៍ជាច្រើនដែលជាគោលការណ៍ដ៏ល្អប្រសើរនៃការអភិវឌ្ឍសហគមន៍។



| គោលការណ៍ VCJF | ការអនុវត្តគោលការណ៍លើការអភិវឌ្ឍសហគមន៍ |
|---|---|
| ការអធិស្ឋាន និងតមអាហារ | យើងខ្វល់ខ្វាយពីក្មេងកំព្រា និងស្ត្រីមេម៉ាយ នេះគឺជាការតមអាហារដ៏ពិតប្រាកដនៅក្នុងសៀវភៅអេសាយ ហើយពេលដែលយើងចូលរួមបង្កើតការអភិវឌ្ឍ យើងត្រូវតែប្រយ័ត្នពីទស្សនៈលោកិយ៍ និងអំណាចវត្ថុស័ក្តសិទ្ធិនៅក្នុងសហគមន៍នេះ។ (សូមមើលជំពូកទី ៥) |
| ការសហការ | យើងសហការជាមួយសហគមន៍ និងភាគីពាក់ព័ន្ធទាំងអស់។ ការអភិវឌ្ឍគួរតែជាដំណើរការបរិយាប័ន្ន។ |
| ត្រៀមខ្លួនដើម្បីរងទុក្ខ | យើងរស់នៅក្នុងចំណោមមនុស្សដែលកំពុងរងទុក្ខលំបាក និងឈឺចាប់ ទោះបីជាការនេះមានហានិភ័យសម្រាប់យើងក៏ដោយ។ យើងរួមគ្នាយល់អំពីទុក្ខលំបាក។ |
| ធ្វើអ្វីដែលអ្នកបន្តបាន | គម្រោងអភិវឌ្ឍន៍របស់យើងគឺយោងទៅតាមធនធាន និងបច្ចេកវិទ្យាដែលមានក្នុងសហគមន៍ដែលពួកគេអាចបន្តអនុវត្ត និងពង្រីកបាន។ |
| ការខិតខំប្រឹងប្រែងរបស់យើងគឺពិតជាសំខាន់ អាចអនុវត្តបាន និងមានគោលបំណងចាប់យកជំហានបន្ទាប់ | យើងបញ្ចូលសេចក្តីពិតខាងវិញ្ញាណដែលពាក់ព័ន្ធ និងត្រូវតាមបរិបទសហគមន៍ចូលទៅក្នុងបណ្តាញដ៏ធំ តាមរយៈការបញ្ចូលបរិបទសហគមន៍របស់យើង។ |
| យើងប្តេជ្ញា និងឈោងចាប់សហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់ | សហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់ ជាទូទៅក៏មិនសូវមានការអភិវឌ្ឍដូចជាវិស័យអប់រំ និងសេដ្ឋកិច្ចដែរ។ ជាពិសេសគឺនៅសហគមន៍ក្រីក្របំផុតក្នុងពិភពលោក តាមរយៈការធ្វើការជាអ្នកអភិវឌ្ឍន៍នៅក្នុងសហគមន៍ ពិតជាអនុញ្ញាតឱ្យយើងយល់ពីពួកគេ។ |
| ការបង្កើត និងប្រើប្រាស់ក្រុមបានត្រឹមត្រូវ | ការអភិវឌ្ឍសហគមន៍គឺជាការងារជាក្រុម ដែលមានវប្បធម៌ និងភ្នាក់ងារជាច្រើនមករួមគ្នាធ្វើការជាមួយគ្នា។ |
| ផ្តោតនៅលើក្រុម | យើងអនុវត្តការបង្កើតសហគមន៍ និងសហគមន៍ដែលមានសុខភាពល្អគំរូ ដែលមានសមាជិកសហគមន៍ជួយគាំទ្រគ្នា និងរៀនពីគ្នាតាមរយៈគម្រោងរបស់យើង។ |
| បង្កើតសាវ័ក មិនមែនផ្លាស់ប្តូរទេ | ការអភិវឌ្ឍសហគមន៍តែងតែមើលមកកាន់អ្នកចូលរួមថាជាភ្នាក់ងារដែលបង្កើតការផ្លាស់ប្តូរ ជាអ្នកដែលមានសក្តានុពលដើម្បីបង្កើតការផ្លាស់ប្តូរ និងបំផ្លាស់បំប្រែសង្គម និងសហគន៍របស់ពួកគេ។ |
| ដៃគូក្នុងស្រុក និងភាពជាម្ចាស់ | ការអភិវឌ្ឍសហគមន៍គឺជាជំនួយរយៈពេលខ្លី។ យើងធ្វើជាគំរូ ផ្តល់ជំនួយ ដឹកនាំ និងបង្កើតអ្នកដឹកនាំសហគមន៍។ ក្នុងនាមជាអង្គការគ្រិស្តបរិស័ទអភិវឌ្ឍសហគមន៍ យើងធ្វើជាគំរូ និងបង្រៀនអ្នកបម្រើ និងគង្វាលភាពជាអ្នកដឹកនាំទៅកាន់សហគមន៍គ្រប់កម្រិតទាំងអស់។ |

7. ពេលដែលអ្នកមើលទៅលើគោលការណ៍ទាំងនេះ តើការប្រៀបធៀបគោលការណ៍ទាំងពីរប្រភេទបង្ហាញពីបេសកកម្មគ្រប់ជ្រុងជ្រោយដោយរបៀបណា?

ចម្លើយរបស់អ្នក

✓

✓

✓

8. សូមមើលពីគោលការណ៍ទាំងនេះឱ្យបានកាន់តែលម្អិតជាងមុនបន្តិច។ អ្នកនិពន្ធជំពូកទី ៩ នៅក្នុងមេរៀន *បេសកកម្មគ្រប់ជ្រុងជ្រោយ* នេះបានសរសេរថា នេះគឺជាការផ្តោតលើការអភិវឌ្ឍដែលនាំការផ្លាស់ប្រែដោយលោក Bryant Myers៖

> គោលការណ៍នៃការអភិវឌ្ឍសហគមន៍ដ៏សំខាន់បំផុតនោះគឺ ការចូលរួមយ៉ាងសកម្មរបស់សហគមន៍នៅក្នុងការស្វែងរកដំណោះស្រាយ និងកំណត់គោលដៅ និងទិសដៅនៅក្នុងដំណើរការនៃការអភិវឌ្ឍ។ លោក Bryant Myers បានរំលឹកយើងតាមរយៈសៀវភៅរបស់គាត់ ដើរជាមួយជនក្រីក្រ (ទំព័រទី ២១៨) ថា បើចង់ចែកចាយរឿងរបស់យើង យើងត្រូវស្តាប់រឿងគេជាមុនសិន។ លោក Bryant Myers បានបន្តទៀតថា៖
>
> > *"...យើងជួបបញ្ហាប្រឈម តើយើងបញ្ចូលរឿងទាំងនេះដោយរបៀបណា ដើម្បីឱ្យវាជួយគ្នាទៅវិញទៅមក ហើយគ្រប់ៗគ្នាអាចរៀន និងរីកចម្រើនបាន? ចំណុចសំខាន់នោះគឺត្រូវក្លាយខ្លួនជា សហគមន៍... ជួយកសាងសហគមន៍គ្នាទៅវិញទៅមក នេះគឺជាអ្វីដែលអ្នកជិតខាងល្អធ្វើ។"*
>
> ក. តើត្រង់កន្លែងណាដែលអ្នកមើលឃើញពីការចូលរួមយ៉ាងសកម្មរបស់សហគមន៍នៅក្នុងការអភិវឌ្ឍសហគមន៍ ឬកិច្ចការដែលស្រដៀងនឹងការងារនេះ? តើយើងអាចស្តាប់រឿងរបស់ពួកគេ និងក្លាយទៅជាសហគមន៍របស់ពួកគេបានដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓
✓

ខ. តើយើងមើលឃើញពីការបង្កើតក្រុមជំនុំ ឬសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូដោយរបៀបណា ឬនៅកន្លែងណា?

ចម្លើយរបស់អ្នក

✓
✓
✓

9. គោលការណ៍សំខាន់មួយទៀតក្នុងការអភិវឌ្ឍសហគមន៍គឺលទ្ធភាពសម្រេចបាន និងលទ្ធភាពរស់រវើក។ តើការអន្តរាគមរបស់អ្នកនឹងត្រូវបានជ្រើសរើសដោយសហគមន៍ និងធ្វើឡើងវិញនៅក្នុងសហគមន៍ដែរឬទេ? តើវាសាមញ្ញគ្រប់គ្រាន់ទេដោយប្រើធនធានដែលមានក្នុងសហគមន៍? តើមាននរណាម្នាក់អាចធ្វើឡើងវិញតាមអ្វីដែលអ្នកកំពុងធ្វើគំរូ?

- តើអាចអនុវត្តតាមកិច្ចការរបស់អ្នកបានដោយរបៀបណា?
- ចុះយុទ្ធសាស្ត្ររបស់អ្នកក្នុងការជួយមនុស្សឱ្យចម្រើនជំនឿ និងភាពជាសាវ័កវិញ?

ចម្លើយរបស់អ្នក

✓
✓
✓

10. សហការីម្នាក់របស់អង្គការ OM របស់យើងគឺជាគ្រូពេទ្យដែលមានអាជ្ញាប័ណ្ណមានជំនាញក្នុងការជួយបុគ្គលដែលមានពិការភាព។ នាងបានសរសេរថា៖

*ចំណុចស្នូលនៃការអភិវឌ្ឍសហគមន៍គឺសុខភាព ការស្តារនីតិសម្បទា ការអប់រំ និងក្រុមជួយខ្លួនឯង (SHGs) គឺជាអ្វីដែលមនុស្សនៅក្នុងសហគមន៍ត្រូវការបំផុត។ យើងសំដៅទៅលើសុខភាពប្រជាជន ធៀបជាមួយនឹងចំនួនមន្ទីរពេទ្យព្យាបាលដែលនៅជិតទីក្រុង សាលារៀនតាមភូមិដែលបានបង្កើតឡើងនៅទីដាច់ស្រយាល រួមបញ្ចូលការអប់រំសម្រាប់កុមារដែលមានពិការភាព ជាជាងការបង្កើតជម្រើសការអប់រំពិសេស និងការទទួលបានជំនួយផ្លូវច្បាប់ និងការជួយគ្នាទៅវិញទៅមកពីសមាជិកក្រុមតាមរយៈក្រុមស្ត្រីជួយខ្លួនឯង ជាជាងការផ្តាច់ខ្លួននៅតែឯង។*

ក. តើអ្នកអាចអនុវត្តលើការងាររបស់អ្នកក្នុងការបម្រើ និងរបៀបដែលអ្នកចង់ជួយសហគមន៍ស្វែងរកដំណោះស្រាយលើសេចក្តីត្រូវការរបស់ពួកគេដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓

ខ. តើអាចអនុវត្តដើម្បីបង្កើតសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓

11. បន្ទាប់ពីបានពិភាក្សាអំពីគុណតម្លៃនៃការ "ព្រួសគ្រាប់ពូជ" តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ។ល។ គ្រូពេទ្យក៏បានសរសេរទៀតថា៖

*ការងារអភិវឌ្ឍន៍សង្គម ជាទូទៅគឺផ្តោតលើការអនុវត្តដំណោះស្រាយ បច្ចេកទេស និងចំណេះដឹង។ យ៉ាងណាមិញ នៅក្នុងវប្បធម៌ភាគច្រើនសំណួរចម្បងពាក់ព័ន្ធនឹងតម្រូវការក្នុងការអភិវឌ្ឍភាគច្រើននោះគឺខាងទំនាក់ទំនង និងវិញ្ញាណ។ ក្នុងនាមជាគ្រិស្តបរិស័ទ យើងអាចឆ្លើយសំណួរពាក់ព័ន្ធនឹងព្រលឹងវិញ្ញាណទាំងនេះ ដែលបានសួរថា "តើអ្នកណាបានធ្វើបាប មនុស្សនេះ ឬឪពុកម្តាយរបស់គាត់?" (យ៉ូហាន ៩:២)។ ការចែករំលែកការអភិវឌ្ឍ និងដំណឹងល្អដល់ក្រុម និងបណ្តាញសហគមន៍ជួយដល់អ្នកដែលពិតជាចង់ស្វែងរកព្រះជាម្ចាស់ និងសេចក្តីពិត។ តាមរយៈការសាបព្រួសទៅក្នុងបណ្តាញដ៏ធំរបស់ស្ត្រី កសិករ និងអាណាព្យាបាល និងការបន្តស្រោចទឹកគ្រាប់ពូជទាំងនេះតាមរយៈការចូលរួមក្នុងក្រុម អាចធ្វើឱ្យពួកគេត្រៀមខ្លួនដើម្បីឈានទៅជំហានថ្មីមួយទៀត គឺការអានព្រះបន្ទូលព្រះជាម្ចាស់។ ការអានព្រះបន្ទូលព្រះជាម្ចាស់ នឹងនាំមកនូវការផ្លាស់ប្រែ ហើយក្នុងករណីខ្លះនឹងនាំមកនូវការផ្លាស់ប្រែដល់អាជ្ញាធរ និងមន្ត្រីថែមទៀតផង។ ការផ្លាស់ប្រែទាំងនេះ នឹងនាំឱ្យមានការផ្លាស់ប្រែឥរិយាបទ ព្រមទាំងនាំមកនូវការផ្លាស់ប្រែដល់សហគមន៍ទាំងមូលថែមទៀតផង ដែលបណ្តាលមកពីការស្តាប់តាមព្រះបន្ទូលព្រះជាម្ចាស់។*

ក. តើការនេះអាចអនុវត្តចំពោះអ្នកបានយ៉ាងដូចម្តេច? តើអ្នក “កំពុងតែសាបព្រួស” គំនិតនិងព័ត៌មានល្អៗដែលជួយបំពេញតម្រូវការ និងការផ្លាស់ប្រែនៅក្នុងសហគមន៍ដែរឬទេ?

ចម្លើយរបស់អ្នក

✓
✓
✓

ខ.តើការសាបព្រួសនៅក្នុងបណ្តាញធំៗអាចជួយសហគមន៍អ្នកតាមព្រះយេស៊ូបានបង្កើតឡើងដែរឬទេ?

ចម្លើយរបស់អ្នក

✓
✓
✓

12. ការសរសេរមកពីតំបន់អាស៊ីកណ្តាល និងបរិបទអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដែលផ្តោតលើការអភិវឌ្ឍសហគមន៍ អ្នកស្រីបាននិយាយថា៖

*ហេតុអ្វីបានជាអ្នកដែលចូលរួមនៅក្នុងការអភិវឌ្ឍអន្តរជាតិបានធ្វើជាគំរូសម្រាប់ក្រុមជំនុំ និងបានចូលរួមនៅក្នុងបេសកម្មនៅក្នុងសហគមន៍ដែលមិនទាន់លឺដំណឹងល្អ គួរតែជឿ និងត្រៀមដើម្បីសម្របខ្លួនតាម? រួមបញ្ចូលទាំងការសម្របខ្លួនឱ្យមានភាពចម្រុះ និងអន្តរជាតិ ផ្តល់ឱកាសសម្រាប់អ្នកជឿអាចរីកចម្រើនបាន ហើយពេលដែលពួកគេទទួលបានបទពិសោធន៍ និងឱកាសដើម្បីបម្រើក្នុងកម្រិតអន្តរជាតិ។ ប្រសិនបើអង្គការបេសកកម្ម និងក្រុមជំនុំអាចកាន់តែចម្រុះ និងទទួលបានការផ្តល់អំណាច— ដោយមើលឃើញសហការីរបស់យើងដែលជាសាវ័ករបស់យើងនៅក្នុងវាលស្រែ និងជាអ្នកដឹកនាំជំនាន់ក្រោយរបស់សហគមន៍ និងស្ថាប័ន— នោះយើងនឹងធ្វើដំណើរបានយ៉ាងវែងឆ្ងាយ។*

ក. តើការនេះអនុវត្តចំពោះការងាររបស់អ្នកមែនដែរឬទេ? តើអ្នកអាចនិយាយដោយស្មោះជាមួយក្រុមអំពីស្ថានភាពដែលមនុស្សទទួលបានការផ្តល់អំណាចដើម្បីឱ្យរីកចម្រើនក្នុងតួនាទី ហើយទទួលយកទំនួលខុសត្រូវនេះបានដែរឬទេ? ប្រសិនបើអាច (និងត្រូវប្រយ័ត្នអំពីអ្នកដែលចូលរួម) តើស្ថានភាពរបស់ពួកគេនឹងមិនមានឱកាសបែបនេះដែរឬទេ?

ចម្លើយរបស់អ្នក

✓
✓
✓

ខ. តើយើងកំពុងតែតោងជាប់នឹងអំណាច ឬជួយឱ្យអ្នកដទៃអភិវឌ្ឍជំនាញរបស់ពួកគេដើម្បីរីកចម្រើនក្លាយជាអ្នកដឹកនាំដែរឬទេ? ពេលដែលអ្នកបានទទួលជំនួយបាន តើមតិ ឬគំរូវិជ្ជមានអ្វីខ្លះដែលអ្នកអាចបង្ហាញបាន?

ចម្លើយរបស់អ្នក

✓
✓
✓

13. បណ្តាញ Micah Declaration បានលើកឡើងថា៖

*បើយើងមិនខ្វល់ពីពិភពលោក យើងកំពុងតែក្បត់នឹងព្រះបន្ទូលព្រះជាម្ចាស់ ដែលទ្រង់បញ្ជូនយើងមកដើម្បីបម្រើពិភពលោក។ បើយើងមិនខ្វល់ពីព្រះបន្ទូលព្រះជាម្ចាស់ យើងក៏គ្មានអ្វីជាប្រយោជន៍ដល់ពិភពលោកនេះដែរ។ យុត្តិធម៌ និងសុច្ចរិតតាមរយៈជំនឿ ការថ្វាយបង្គំ និងសកម្មភាពនយោបាយ ខាងវិញ្ញាណ និងសម្ភារៈ ការផ្លាស់ប្រែបុគ្គល និងរចនាសម្ព័ន្ធគឺនៅជាមួយគ្នា។ តាមរយៈជីវិតរបស់ព្រះយេស៊ូ ការនិយាយ និងសកម្មភាពគឺជាចំណុចស្នូលនៃការងារគ្រប់ជ្រុងជ្រោយរបស់យើង។*

- ពេលដែលយើងគិតអំពីគោលការណ៍ផ្សេងៗខាងលើដែលនិយាយអំពីការអភិវឌ្ឍសហគមន៍ល្អ តើអ្នកឃើញគោលការណ៍ទាំងនោះស្របគ្នាជាមួយនឹងរបៀបដែលយើងធ្វើជាបន្ទាល់ដែរឬទេ?
- តើគំរូទាំងនេះគឺជាគំរូល្អអំពីការបង្ហាញ និងការពន្យល់ពីដំណឹងល្អដែលសមស្របជាមួយគ្នាដែរឬទេ?
- ក្នុងនាមជាក្រុមការងារអភិវឌ្ឍន៍សហគមន៍ (ឬតួនាទីដែលមានលក្ខណៈស្រដៀងនឹងតួនាទីនេះ) តើអ្នកបានឃើញថាការងាររបស់អ្នកមានភាពល្អប្រសើរនៅត្រង់កន្លែងណាខ្លះ? ហើយតើអ្នកបានធ្វើអ្វី (ឬគួរតែធ្វើអ្វី) ដើម្បីបង្កើតសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ?

ចម្លើយរបស់អ្នក

✓
✓
✓

## ការអនុវត្ត (១០ នាទី)

14. សូមអនុវត្តតាមរយៈការគិតអំពីរបៀបដែលយើងត្រូវអនុវត្តគំនិតទាំងនេះ។

- តើយើងអាចធ្វើអ្វីដែលខុសពីមុន?
- តើយើងនឹងអនុវត្តការផ្លាស់ប្តូរដោយរបៀបណា?
- តើសមាជិកក្រុមរបស់យើងនឹងទទួលខុសត្រូវផ្នែកណាខ្លះ?
- តើពេលណាដែលនឹងទទួលបានលទ្ធផលនៃការផ្លាស់ប្រែ?

✓
✓
✓

## សេចក្តីសន្និដ្ឋាន (១០ នាទី)

15. សូមបញ្ចប់ដោយអានរឿងនេះ ដែលជាបទពិសោធន៍ពីសហការីរបស់យើង។

*កាលពីប៉ុន្មានខែមុន ខ្ញុំបានទៅលេងក្រុមគ្រួសារភៀសខ្លួនមួយនៅទីក្រុងក្នុងតំបន់មជ្ឈិមបូព៌ាជាមួយនឹងក្រុមអង្គការរបស់យើង ដែលមានក្រុមគ្រូពេទ្យពីលោកខាងលិច និងឱសថការីមកពីតំបន់មជ្ឈិមបូព៌ា។ ពួកគេទាំងពីរចេះនិយាយភាសាអង់គ្លេស និងអារ៉ាប់បានយ៉ាងល្អ ហើយក៏ស្រឡាញ់មនុស្សដែលគេបម្រើផងដែរ។ យើងបានទៅលេងក្រុមគ្រួសារក្រីក្រមួយ៖ មានស្ត្រីម្នាក់កំពុងតែជួបបញ្ហានឹងគ្រួសាររបស់គាត់ កូនប្អូននាក់ក្នុងចំណោមប្រាំមួយនាក់មានពិការភាព ឬមានជំងឺភ្លើក។ ពេលដែលខ្ញុំកំពុងអង្កេត ក្រុមបានស្តាប់ពីបញ្ហារបស់គាត់ និងបានព្យាយាមលួងលោមគាត់ ផ្តល់ដំបូន្មានល្អៗ ហើយបានជួយគាត់ឱ្យចេះអានវេជ្ជបញ្ជាគ្រូពេទ្យ។ ពួកគេបានសើចសប្បាយជាមួយគ្នា និងបានច្រៀងចម្រៀងជាមួយក្មេងៗ*

*និងបានឱ្យលំហាត់ដល់ក្មេងស្រីៗដែលពួកគេសង្ស័យថាមានបញ្ហាខួរក្បាល។ មុនពេលចាកចេញ អ្នកជិតខាងក៏បានមកដល់។ សហការីជនជាតិអារ៉ាប់របស់ខ្ញុំក៏បានប្រាប់ពីរឿងព្រះយេស៊ូ បានឆ្លើយសំណួរយ៉ាងច្រើន ព្រមទាំងបានអធិស្ឋានសុំព្រះពរសម្រាប់គ្រួសារនេះផងដែរ។ បន្ទាប់មក យើងក៏បានចាកចេញ។*

*ខ្ញុំមិនសូវបានឃើញអ្វីដែលខ្ញុំបានសរសេរមកអនុវត្តក្នុងពេលដ៏តិចនេះទេ— បេសកម្មគ្រប់ជ្រុងជ្រោយ និងការអភិវឌ្ឍសហគមន៍បានលេចចេញជារូបរាងក្នុងរយៈពេលត្រឹមតែ ៦០ នាទីនៃការមកសួរសុខទុក្ខអ្នកភូមិ ក្លាយជាការអបអរសាទរដែលមានគ្រប់រសជាតិលាយបញ្ចូលគ្នាយ៉ាងល្អ ហើយជាទីពេញចិត្តចំពោះមនុស្ស និងគាប់ព្រះហឫទ័យព្រះ។*

*សូមឱ្យយើងរក្សាអ្វីដែលនៅជាមួយគ្នានៅតែនៅជាមួយគ្នាដដែល ម្ហូបកាន់តែឆ្ងាញ់ពេលដែលវាលាយចូលគ្នាបានល្អ*

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

សប្តាហ៍នេះយើងបានសិក្សាអំពីគោលការណ៍ភាពល្អប្រសើរដើម្បីការអភិវឌ្ឍសហគមន៍ និងការបង្កើតសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ។

តើគោលការណ៍ទាំងនេះលេចធ្លោសម្រាប់អ្នកដែរឬទេ? តើគោលការណ៍មួយណា? ហេតុអ្វី?

តើអ្នកគិតថាព្រះជាម្ចាស់ចង់ឱ្យអ្នកអនុវត្តគោលការណ៍ទាំងនេះ ឬនាំការផ្លាស់ប្រែដែរឬទេ? ប្រសិនបើពិតមែននោះ សូមសរសេរគំនិតមួយចំនួនដែលអ្នកចង់អនុវត្តនិងនាំការផ្លាស់ប្រែ។ តើអ្នកអាចចែករំលែកគំនិតទាំងនេះ ព្រមទាំងអធិស្ឋានជាមួយនរណាបាន ដើម្បីឱ្យរបៀបរបស់ព្រះជាម្ចាស់អាចធ្វើការបានមុន?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីប្រាំបួន *បេសកកម្មគ្រប់ជ្រុងជ្រោយ*



# គោលការណ៍ទីដប់៖
# អ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់ជាហេតុផលដែលយើងជួយ

គោលបំណងនៃការពិភាក្សា៖
1. ក្រុមរបស់យើងនឹងត្រូវគិតឆ្ងាយជាងមុន នៅពេលដែលយើងគិតអំពីអ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់។
2. ក្រុមរបស់ខ្ញុំនឹងយល់កាន់តែច្បាស់អំពីមូលហេតុដែលដំណឹងល្អមិនទាន់ចូលទៅដល់។
3. ក្រុមរបស់យើងនឹងយល់ពីរនាំងដែលរារាំងដំណឹងល្អមិនឱ្យចូលទៅដល់។
4. ក្រុមរបស់ខ្ញុំនឹងយល់កាន់តែច្បាស់ថាមានកិច្ចការជាច្រើនដែលយើងត្រូវរៀនពីអ្នកដែលដំណឹងល្អមិនទាន់ចូលទៅ ដល់ ពីរបៀបដែលព្រះជាម្ចាស់ប្រើប្រាស់ពួកគេដើម្បីផ្លាស់ប្រែពួកយើង។

## ការរំលឹក

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីប្រាំបួន៖ ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវគិតទៅលើគោលការណ៍ដែលលេចធ្លោសម្រាប់អ្នកជាងគេ គោលការណ៍ភាពល្អប្រសើរដើម្បីអភិវឌ្ឍសហគមន៍ ដែលសមស្របជាមួយនឹងការបង្កើតសហគមន៍សកម្មអ្នកដើរតាមព្រះយេស៊ូ។
   - តើគោលការណ៍មួយណាដែលលេចធ្លោសម្រាប់អ្នកជាងគេ? ហេតុអ្វី?
   - តើអ្នកគិតថាព្រះជាម្ចាស់ចង់ប្រើប្រាស់អ្នកដើម្បីអនុវត្តគោលការណ៍ទាំងនេះ ឬដើម្បីនាំការផ្លាស់ប្រែដែរឬទេ? (សំណួរបិទ – តើយើងអាចប្តូរវាទៅជាសំណួរបើកបានយ៉ាងដូចម្តេច?)

2, សូមចំណាយពេល ៣-៤ នាទី ដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរទាំងនេះ។

## សេចក្តីផ្តើម

3. សប្តាហ៍នេះ យើងនឹងសិក្សាអំពីគោលការណ៍ទីដប់។

គោលការណ៍ទីដប់ ការសង្ខេប៖ *"អ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់ជាហេតុផលដែលយើងជួយ"*

## ផ្នែកទីមួយ៖ តើនរណាដែលដំណឹងល្អមិនទាន់ចូលទៅដល់? (១០ នាទី)

4. តើពាក្យថា "ដំណឹងល្អមិនទាន់ចូលទៅដល់" មានន័យដូចម្តេចចំពោះអ្នក?

ចម្លើយរបស់អ្នក
- ✓
- ✓
- ✓

5. នៅក្នុងអង្គការ OM យើងឱ្យនិយមន័យនៃពាក្យថា "ដំណឹងល្អមិនទាន់ចូលទៅដល់" នៅក្នុងសហគមន៍

- គឺជាអ្នកដែលគ្មាននរណាម្នាក់ចែកចាយអំពីព្រះយេស៊ូទៅកាន់ពួកគេ។
- អ្នកដើរតាមព្រះយេស៊ូដែលនៅក្នុងសហគមន៍នោះមិនបានបង្រៀនពួកគេអំពីព្រះយេស៊ូ។
- រនាំងផ្សេងៗដូចជាភាសា និងវប្បធម៌បានញែកមនុស្សចេញពីអ្នកដើរតាមព្រះយេស៊ូ។

6. ជាច្រើនលើកច្រើនសារ យើងប្រើពាក្យថា "មិនទាន់ចូលទៅដល់" និងពាក្យថា "មិនបានទទួលដំណឹងល្អ" យើងប្រើលេខធំៗ "ភាគរយនៃចំនួនប្រជាជនដែលទទួលដំណឹងល្អ" និងស្ថិតិផ្សេងៗទៀត។

ប៉ុន្តែសម្រាប់អង្គការ OM ពេលដែលយើងឱ្យនិយមន័យនៃពាក្យថា "ដំណឹងល្អមិនទាន់ចូលទៅដល់" យើងចង់សំដៅទៅលើការប្រៀបធៀបគំនិតៈ "សហគមន៍នេះគឺដំណឹងល្អមិនទាន់ចូលទៅដល់ជាងសហគមន៍នោះ"។ យើងមិនចង់ឱ្យស្ថិតិនេះត្រូវបានកំណត់ដោយស្ថិតិនិងតួរលេខរាប់ដោយអ្នកមិនពាក់ព័ន្ធ ឬច្នៃស្ថិតិឡើងដោយក្រុមជនជាតិដើមភាគតិចនោះទេ។

ក. តើស្ថិតិ "លេខធំ" មានឥទ្ធិពលអ្វីដល់ការគិតរបស់យើងអំពីអ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់?

ចម្លើយរបស់អ្នក

✓
✓
✓

ខ. តើព្រះជាម្ចាស់ចង់ឱ្យយើងគិតអំពីអ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់យ៉ាងដូចម្ដេច?

ចម្លើយរបស់អ្នក

✓
✓
✓

7. តាមរយៈគំនិតនេះ

- តើនរណាជាអ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់?
- តើពួកគេនៅជិតអ្នក ឬនៅឆ្ងាយពីអ្នក
- ក្នុងពេលដែលយើងអាចនឹងគិតអំពីប្រជាជនដូចជា "ប្រជាជនអារ៉ាប់នៅអាហ្វ្រិកខាងជើង" ឬ "ពុទ្ធបរិស័ទនៅក្នុងប្រទេសទីបេ" ថាជាមនុស្សដែលដំណឹងល្អមិនទាន់ចូលទៅដល់ តើនរណាអាចជាសហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់ដែលនៅជិតអ្នក ដែលត្រូវបានមើលរំលងពីក្រុមគ្រិស្តបរិស័ទដែលនៅក្នុងតំបន់របស់អ្នក។

ចម្លើយរបស់អ្នក

✓
✓
✓

## ផ្នែកទីពីរ - "ជាហេតុផលដែលយើងជួយ" (១៥ នាទី)

8. តើមានរនាំងអ្វីដែលធ្វើឱ្យសហគមន៍ក្លាយជាសហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់? តើអ្វីដែលធ្វើឱ្យមនុស្សប្រភេទនេះកាន់តែពិបាកក្នុងការឈោងចាប់ពួកគេ?

ចម្លើយរបស់អ្នក

✓

✓

✓

9. អ្នកស្រី រ៉ូសម៉ារី ហេគ បានប្រាប់យើងពីមនុស្សម្នាក់ដែលគាត់បានដាក់ឈ្មោះគាត់ថា សាលី។

*ខ្ញុំតែងតែចាំពីពេលដែលខ្ញុំបានជួបសាលីជាលើកដំបូង*។ សាលីគឺជាជនជាតិម៉ាឡេកាន់សាសនាឥស្លាម។*
*នៅក្នុងប្រទេសរបស់នាងមានការដាក់ទោសយ៉ាងធ្ងន់ធ្ងរសម្រាប់អ្នកដែលបានកែប្រែចិត្តគំនិតជឿ និងធ្វើជាបន្ទាល់របស់ព្រះយេស៊ូ។ យ៉ាងណាមិញ សាលី*
*មានរនាំងកាន់តែធ្ងន់ធ្ងរដែលបានញែកនាងចេញពីសហគមន៍ នាងបានផ្លាស់ប្តូរភេទ និងមានផ្ទុកមេរោគអេសដ៍។*
*សាលីតែងតែរត់ និងលាក់ខ្លួនគេចពីអាជ្ញាធរ នាងពិតជាពិបាកទទួលបានសេវាសុខភាព ឬទូរសព្ទទៅកាន់ប៉ូលិសដើម្បីទទួលបានការការពារ*
*នាងត្រូវតែរត់គេចពីប៉ូលិសដោយសារតែការកែភេទគឺជារឿងខុសច្បាប់ ហើយការកែភេទតែងតែរងការវាយដំពីអ្នកដែលគួរតែការពារនាង។*
*តើនរណានឹងនាំដំណឹងល្អអំពីព្រះគ្រិស្តទៅកាន់សាលី ដែលនឹងឈរជាមួយនាង និងតស៊ូមតិសម្រាប់នាងដើម្បីទទួលបានសិទ្ធិមូលដ្ឋានក្នុងនាមជាមនុស្សជាតិដែលជាស្នាព្រះហស្តព្រះជាម្ចាស់?*

បន្ទាប់ពីបានប្រាប់រឿងនេះ អ្នកស្រីបាននិយាយថា៖ "ការចូលទៅកាន់ពិភពរបស់សាលីភាគច្រើននឹងធ្វើឱ្យយើងមានអារម្មណ៍មិនស្រួល។"

តើអ្នកយល់ស្របដែរឬទេ?
តើអ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់
ធ្វើឱ្យយើងមានអារម្មណ៍មិនស្រួលបានយ៉ាងដូចម្តេច? ហេតុអ្វី?

ចម្លើយរបស់អ្នក

✓

✓

✓

✓

10. ដូច្នេះ ពេលដែលយើងគិតអំពីអ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់ និងរនាំងដែលញែក ឬលាក់បាំងពួកគេ តើរនាំងទាំងនោះជារបស់អ្នកណា?
តើរនាំងទាំងនោះអាចជារនាំងរបស់យើងដែរឬទេ?

តើរនាំងណាខ្លះដែលជារបស់ខ្ញុំ មិនមែនជារបស់ពួកគេ?

ចម្លើយរបស់អ្នក

✓
✓
✓
✓

11. ក្នុងពេលបច្ចុប្បន្ន តើព្រះយេស៊ូអាចស្ថិតនៅទីណា? ហេតុអ្វី?

ចម្លើយរបស់អ្នក

✓
✓
✓
✓

## ផ្នែកទីបី - ដូច្នេះ? (១០ នាទី)

12. ពេលខ្លះ យើងគិតថាយើងតែងតែមានចម្លើយ យើងមិនចាំបាច់រៀននោះទេ—យ៉ាងហោចណាស់គឺមិនចេញមកពី "សហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់" ដែលយើងចង់បម្រើ។ សហការីម្នាក់ដែលបានមកពីអាហ្វ្រិកខាងត្បូងបានរកឃើញវិធីសាស្ត្រក្នុងការផ្លាស់ប្តូរឥរិយាបទពេលដែលនាងបានទៅលេងជំរំជនភៀសខ្លួន។

> *គ្រប់ពេលដែលខ្ញុំជិះទៅជំរំជនភៀសខ្លួន ខ្ញុំតែងតែឃើញអ៊ីស្រីម្នាក់អង្គុយនៅក្បែរផ្លូវ។ រហូតដល់ពេលមួយដែលខ្ញុំព្រមស្តាប់ព្រះវិញ្ញាណដែលតែងតែចង់ប្រាប់ខ្ញុំថា៖ "តើអ្នកឃើញអ៊ីស្រីនោះដែរឬទេ? ខ្ញុំឃើញគាត់។ ឈប់បន្តិចទៅសួរសុខទុក្ខគាត់ទៅចឹង។"*
>
> *មានថ្ងៃមួយដែលខ្ញុំព្រមឈប់ នោះហើយគឺជាបទពិសោធន៍ដ៏អស្ចារ្យ។ ខ្ញុំបានបន្ទាបខ្លួនខ្លាំងទៅជួបគាត់ដូចព្រះយេស៊ូជួបខ្ញុំអញ្ចឹង—និងបានចែកចាយអំពីភាពជាមនុស្សរបស់យើង និងការគោរពចំពោះគាត់។ ខ្ញុំមិនបានចែកចាយដំណឹងល្អទៅគាត់ទេ ប៉ុន្តែខ្ញុំពិតជាគិតថាខ្ញុំបានបង្ហាញដំណឹងល្អតាមរយៈសកម្មភាពខ្ញុំចំពោះគាត់។ ខ្ញុំពិតជាឃើញព្រះយេស៊ូនៅក្នុងគាត់។ ប្រហែលជាអ្នកដែលដំណឹងល្អមិនទាន់ទៅដល់ងាយស្រួលឈោងចាប់ជាងអ្វីដែលយើងគិត ហើយយើងត្រូវសុំឱ្យព្រះយេស៊ូប៉ះពាល់យើងតាមរយៈពួកគេក្នុងរបៀបថ្មី។*

ក. តើស្ត្រីម្នាក់នេះបានរៀនអ្វីខ្លះពីអ៊ីស្រីម្នាក់នេះ? តើឃ្លាចុងក្រោយរបស់គាត់មានន័យយ៉ាងដូចម្តេច ពេលដែលគាត់និយាយថា ព្រះយេស៊ូប៉ះពាល់យើងតាមរយៈពួកគេ?

ចម្លើយរបស់អ្នក

✓
✓
✓

ខ. តើអ្នកធ្លាប់មានបទពិសោធន៍បែបនេះដែរឬទេ? តើអ្នកចង់ទទួលបានបទពិសោធន៍បែបនេះដែរឬទេ?

ចម្លើយរបស់អ្នក

13. អ្នកស្រី រ៉ូស បានប្រាប់អំពីរឿងនៃការផ្លាស់ប្ដូរ
ជារឿងនិយាយការជួយមនុស្សពេលដែលពួកគេកំពុងតែត្រូវការ។

*នៅលើភ្នំក្នុងប្រទេសនេប៉ាល់ មានមនុស្សច្រើនណាស់ដែលមានផ្ទុកមេរោគអេសដ៍
និងទទួលរងនូវការរើសអើង។
ខណៈពេលដែលប្រទេសនេះកំពុងជួបប្រទះនឹងការរីកចម្រើននៃក្រុមជំនុំជាច្រើន នៅក្នុងតំបន់
អ្នកមានផ្ទុកមេរោគអេដស៍ត្រូវបានគេទុកចោល ដាក់ឱ្យនៅដាច់ដោយឡែក
និងមាក់ងាយសូម្បីតែក្រុមជំនុំក៏ធ្វើបែបនេះដែរ — ដោយពួកគេជឿថាទុក្ខលំបាករបស់ពួកគេ
ព្រះជាម្ចាស់យល់ពីទុក្ខលំបាកដែលពួកគេកំពុងជួបប្រទះ។*

*យ៉ាងណាមិញ
សេវាមើលថែអ្នកផ្ទុកមេរោគអេសដ៍គឺមានតែនៅក្នុងទីក្រុងខាត់មាន់ឌូតែប៉ុណ្ណោះ។
អ្នកផ្ទុកមេរោគអេសដ៍ត្រូវធ្វើដំណើរមកទីក្រុងដើម្បីទទួលសេវាមើលថែទាំ
ឬត្រូវស្លាប់នៅក្នុងភូមិរបស់ពួកគេ។ អ្នកជំងឺភាគច្រើនមកកាន់ទីក្រុងតែម្នាក់ឯង
គ្មានអ្នកមកជាមួយ ពិបាកក្នុងការស្វែងរកមន្ទីរពេទ្យ ហើយក៏គ្មានកន្លែងស្នាក់ដែរ
ក្នុងករណីដែលពួកគេត្រូវបញ្ជូនចេញពីមន្ទីរពេទ្យវិញ។*

*មានអ្នកដើរតាមព្រះយេស៊ូមួយចំនួន
ភាគច្រើនគឺជាជនជាតិនេប៉ាល់ដែលមានផ្ទុកមេរោគអេដស៍ សុខចិត្តលះបង់ពេលវេលា
និងទឹកចិត្តដើម្បីផ្ដល់កន្លែងស្នាក់នៅ និងជួយអ្នកជំងឺថ្មីនៅមន្ទីរពេទ្យ។ ពួកគេបានចាប់
ផ្ដើមបោះទីតាំងនៅតាមសហគមន៍ជនបទ ដែលត្រូវធ្វើដំណើរជាច្រើនម៉ោង
និងប្រកបដោយគ្រោះថ្នាក់។*

*ផ្សាយដំណឹងល្អអំពីព្រះគ្រិស្ត និងជួយសហគមន៍នេប៉ាល់តាមតែអាចធ្វើទៅបាន។
សម្រាប់អ្នកផ្ទុកមេរោគអេដស៍ដែលបានទាក់ទងមកព័ន្ធកិច្ច
ពួកគេដឹងថាព្រះជាម្ចាស់ស្រឡាញ់ពួកគេ ហើយមានមនុស្សដែលយល់
នឹងចង់ជួយពួកគេដោយមិនគិតអំពីភាពអាម៉ាស់ និងការរើសអើងពីសង្គមរបស់ពួកគេឡើយ។
នៅក្នុងការប្រជុំក្រុមជំនួយប្រចាំខែ អ្នកកាន់សាសនាហិណ្ឌូ ឥស្លាម
និងគ្រិស្តបរិស័ទប្រកបអាហារ អធិស្ឋាន និងថ្វាយបង្គំព្រះជាម្ចាស់ជាមួយគ្នា។*

*ការប្រជុំនេះគឺមានក្រុមមនុស្សដែលមានជំនឿផ្សេងៗគ្នា ហើយអ្វីដែលពួកគេធ្វើនោះគឺ
ពួកគេចែករំលែកទុក្ខលំបាក និងស្នើសុំឱ្យអធិស្ឋានឱ្យគ្នាទៅវិញទៅមក។
អ្វីដែលពួកគេមានរឿងពីរដូចគ្នា គឺ៖ មេរោគអេដស៍ និងព័ន្ធកិច្ចដែលជួយពួកគេ។
មានមនុស្សជាច្រើនដែលមិនមែនជាអ្នកជឿ ប៉ុន្តែកំពុងតែបើកចិត្តដើម្បីទទួលព្រះគ្រិស្ត។
មានម្ដាយម្នាក់បានបើកចិត្តទទួលពិធីជ្រមុជទឹក និងចាប់ផ្ដើមដើរតាមព្រះយេស៊ូ។
មានគេសួរកូនប្រុសរបស់គាត់ថាតើគាត់គឺអ្នកជឿដែរឬទេ ចម្លើយរបស់គាត់នោះគឺ
“មិនទាន់ទេ” ឆ្លើយដោយស្នាមញញឹម
ដែលបញ្ជាក់ថាមិនយូរនោះទេគាត់នឹងក្លាយទៅជាអ្នកជឿដែរ។*

សូមគិតអំពីរឿងនេះ៖ គិតអំពីសហគមន៍ដែលដំណឹងល្អមិនទាន់ចូលទៅដល់។

ក. តើមានបញ្ហាអ្វីខ្លះ? តើបញ្ហាទាំងនោះត្រូវបានយកឈ្នះដោយរបៀបណា?
តើនរណាដែលហ៊ានឈានជើងចេញដើម្បីផ្លាស់ប្ដូរស្ថានភាព?
តើវាជារឿងងាយស្រួលសម្រាប់ពួកគេដែរឬទេ?

ចម្លើយរបស់អ្នក
✓
✓
✓

ខ. តើអ្វីដែលធ្វើឱ្យមនុស្សដែលកាន់សាសនាហិណ្ឌូ ឥស្លាម និងគ្រិស្តបរិស័ទមករួបរួមគ្នា?

ចម្លើយរបស់អ្នក

✓
✓
✓

## ផ្នែកទីបួន - សេចក្ដីសន្និដ្ឋាន (១០ នាទី)

14. អ្នកស្រី រ៉ូស បានបញ្ចប់ជំពូករបស់គាត់ដោយបានសរសេរថា៖

*អ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់គឺតែងតែត្រូវបានមើលរំលង និងបានញែកចេញ មិនត្រឹមតែញែកចេញពីយើងនោះទេ ប៉ុន្តែក៏ញែកចេញពីសង្គមរបស់ពួកគេដោយសារបរិយាកាសមិនស្វាគមន៍ គ្រោះថ្នាក់ ជំងឺ យេនឌ័រ ការមាក់ងាយ ភាពក្រីក្រ និងបញ្ហាស្មុគស្មាញជាច្រើនដែលបណ្ដាលមកពីអំពើបាប។ បានមើលរំលងពួកគេ ហើយពេលខ្លះគឺដោយសារតែយើងមិនបានស្ដាប់តាមការណែនាំពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ នៅពេលដែលយើងបន្ថែមការខិតខំប្រឹងប្រែងក្នុងការស្វែងរក ជាពិសេសគឺការយល់ និងបម្រើពួកគេ យើងអាចរកឃើញខ្លួនយើងនៅកន្លែងដែលយើងមិននឹកស្មានដល់  លោក ប្រាយអិន មេយ័រ បាននិយាយថា [នៅក្នុងការសន្ទនាជាមួយលោក ដេវីដ ហ្វ្រឺនលី] 'ការភ្ញាក់ផ្អើលដ៏រីករាយ' ដែលអាចបើកចិត្ត និងគំនិត ដូចព្រះគ្រិស្តបានត្រាស់ហៅយើងឱ្យបម្រើ និងបង្ហាញសេចក្ដីស្រឡាញ់។*

តើអ្នកធ្លាប់មានការភ្ញាក់ផ្អើលដ៏រីករាយដូចអ្វីដែលលោក ប្រាយអិន មេយ័រ បាននិយាយដែរឬទេ? សូមប្រាប់ក្រុមអំពីបទពិសោធន៍នេះ។

15. ថ្ងៃនេះយើងបានមើលអំពីអ្នកដែល "ដំណឹងល្អមិនទាន់ចូលទៅដល់" និងបានមើលអំពីមូលហេតុដែល "ដំណឹងល្អមិនទាន់ចូលទៅដល់" ពួកគេ។

តាមរយៈការសិក្សាអំពីរឿងនេះបានភ្ជាប់យើងទៅនឹងការពិភាក្សាចាស់ៗដូចម្ដេចខ្លះ?

ចម្លើយរបស់អ្នក

✓
✓
✓

16. តើការសន្ទនាថ្ងៃនេះបានបង្កើតការផ្លាស់ប្ដូរអ្វីខ្លះ? តើមានអ្វីដែលយើងចង់ឃើញផ្លាស់ប្ដូរដែរឬទេ? បើមាន តើមានអ្វីខ្លះ?

✓
✓
✓

## សម្រាប់ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖

តើដំណឹងល្អចូលមកកាន់សហគមន៍ មនុស្ស ភូមិ ឬជនជាតិភាគតិចរបស់អ្នកនៅពេលណា? ប្រហែលជាដំណឹងល្អបានចូលមកយូរហើយ ប្រសិនបើអ្នកស្ថិតនៅកន្លែងមួយចំនួនដូចជាប្រទេសក្រិច សម្រាប់ប្រទេសអាហ្វ្រិក ប្រហែលជា ២០០ ឆ្នាំមុន។

តើដំណឹងល្អចូលមកកាន់មនុស្ស ឬសហគមន៍របស់អ្នកដោយរបៀបណា? តើអ្នកទទួលបានដំណឹងល្អដោយរបៀបណា? តើសហគមន៍របស់អ្នកលែងជាសហគមន៍ដែល “ដំណឹងល្អមិនទាន់ចូលទៅដល់” ដោយរបៀបណា?

តើរឿងរបស់អ្នក រឿងសហគមន៍របស់អ្នក បានលើកទឹកចិត្តអ្នកអ្វីខ្លះពេលដែលអ្នកសម្រេចចិត្តក្នុងការជួយសហគមន៍ផ្សេងទៀតឱ្យក្លាយជាអ្នកដើរតាមព្រះយេស៊ូ?

## សម្រាប់ការសិក្សាបន្ថែមទៀត...

ជំពូកទីដប់ *បេសកកម្មគ្រប់ជ្រុងជ្រោយ*



## មើលត្រលប់ទៅក្រោយវិញ និងមើលពីអ្វីដែលយើងបានរៀន

គោលបំណងនៃការពិភាក្សា៖
1. យើងនឹងរួមគ្នារំលឹកអំពីគោលការណ៍ដែលយើងបានរៀន និងចំណុចដែលយើងបានរៀន។
2. យើងនឹងកំណត់ជំហានមួយចំនួនដែលយើងអាចធ្វើបានដើម្បីអនុវត្តអ្វីដែលយើងបានរៀន។
3. យើងនឹងចែកចាយគំនិតអំពីរបៀបដែលវគ្គបណ្តុះបណ្តាលនេះអាចកាន់តែមានប្រសិទ្ធភាពសម្រាប់អ្នកផ្សេងទៀតនាពេលអនាគត។

### ការរំលឹក (៥ នាទី)

1. សប្តាហ៍មុន យើងបានមើលពីគោលការណ៍ទីដប់៖
"អ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់ជាហេតុផលដែលយើងជួយ"

ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនគឺត្រូវឆ្លើយសំណួរថា៖ តើដំណឹងល្អចូលមកកាន់សហគមន៍ មនុស្ស ភូមិ ឬជនជាតិភាគតិចរបស់អ្នកនៅពេលណា? តើដំណឹងល្អចូលមកកាន់មនុស្ស ឬសហគមន៍របស់អ្នកដោយរបៀបណា? តើអ្នកទទួលបានដំណឹងល្អដោយរបៀបណា? តើសហគមន៍របស់អ្នកលែងជាសហគមន៍ដែល "ដំណឹងល្អមិនទាន់ចូលទៅដល់" ដោយរបៀបណា? តើរឿងរបស់អ្នក រឿងសហគមន៍របស់អ្នក បានលើកទឹកចិត្តអ្នកអ្វីខ្លះពេលដែលអ្នកសម្រេចចិត្តក្នុងការជួយសហគមន៍ផ្សេងទៀតឱ្យក្លាយជាអ្នកដើរតាមព្រះយេស៊ូ?

2, សូមចំណាយពេល ៣-៤ នាទីដើម្បីចែករំលែកអំពីរបៀបដែលយើងឆ្លើយសំណួរនេះ។

### ការត្រលប់ទៅមើលគោលការណ៍ (១៣ នាទី)

3. យើងបានសិក្សាអំពីគោលការណ៍ទាំងដប់ក្នុងសៀវភៅ បេសកកម្មគ្រប់ជ្រុងជ្រោយ គោលការណ៍អំពីអ្នកដើរតាមព្រះយេស៊ូ និងការអភិវឌ្ឍសហគមន៍សម្រាប់អ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់។

តើគោលការណ៍ទាំងនេះមានន័យសម្រាប់អ្នកដែរឬទេ គោលការណ៍ដែលពិសេសសម្រាប់អ្នក? តើយើងអាចញែកគោលការណ៍បានដែរឬទេ—ឬត្រូវរក្សាគោលការណ៍ទាំងនេះឱ្យនៅជាមួយគ្នា? តើមានរឿងអ្វីកើតឡើងបើយើងព្យាយាមញែកគោលការណ៍ទាំងនេះ?



- គោលការណ៍ទីមួយ ការសង្ខេបៈ “ការស្វែងយល់អំពីព្រះរាជ្យព្រះជាម្ចាស់គឺជាមូលដ្ឋានគ្រឹះ”
- គោលការណ៍ទីពីរ ការសង្ខេបៈ “ការយល់ដឹងពីរបៀបដែលមនុស្សចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ជួយយើងឱ្យចេះធ្វើព័ន្ធកិច្ច”
- គោលការណ៍ទីបី ការសង្ខេបៈ ដំណឹងល្អមានឥទ្ធិពលគ្រប់លក្ខណៈមនុស្សទាំងអស់ និងគ្រប់បរិបទទាំងអស់
- គោលការណ៍ទីបួន ការសង្ខេបៈ “យើងមាននិមិត្តដ៏ធំរួមគ្នាគឺដើម្បីថ្វាយសិរីរុងរឿងដល់ព្រះគ្រិស្ត នៅពេលដែលមនុស្សជឿលើព្រះអង្គ ហើយសហគមន៍ទទួលបានការប៉ះពាល់ពីព្រះរាជ្យរបស់ព្រះជាម្ចាស់។”
- គោលការណ៍ទីប្រាំ ការសង្ខេបៈ “ការអធិស្ឋាន និងសង្គ្រាមខាងវិញ្ញាណគឺជាចំណុចស្នូលនៃដំណើរការនៃការផ្លាស់ប្រែ”
- គោលការណ៍ទីប្រាំមួយ ការសង្ខេបៈ “ការខ្វល់ខ្វាយពីស្នាព្រះហស្ត គឺជាការថ្វាយបង្គំ ការធ្វើជាបន្ទាល់ និងការស្ដាប់បង្គាប់”
- គោលការណ៍ទីប្រាំពីរ ការសង្ខេបៈ “ការបំផ្លាស់បំប្រែពិតប្រាកដត្រូវការនិមិត្តសម្រាប់សហគមន៍សកកម្មអ្នកដើរតាមព្រះយេស៊ូ និងការផ្លាស់ប្ដូរបុគ្គល និងសហគមន៍”
- គោលការណ៍ទីប្រាំបី ការសង្ខេបៈ “ក្រុមការងារអភិវឌ្ឍន៍សហគមន៍ប្ដេជ្ញាធ្វើការប្រកបដោយវិជ្ជាជីវៈ”
- គោលការណ៍ទីប្រាំបួន ការសង្ខេបៈ “មានគោលការណ៍ភាពល្អប្រសើរច្រើនណាស់នៅក្នុងការអភិវឌ្ឍសហគមន៍ និងការបង្កើតសហគមន៍សកកម្មអ្នកដើរតាមព្រះយេស៊ូ។”
- គោលការណ៍ទីដប់ ការសង្ខេបៈ” អ្នកដែលដំណឹងល្អមិនទាន់ចូលទៅដល់ជាហេតុផលដែលយើង ជួយ។”

## លក្ខណៈពេញលេញរបស់មនុស្ស បេសកកម្មគ្រប់ជ្រុងជ្រោយ (១៥ នាទី)

4. នៅក្នុងសេចក្ដីបញ្ចប់សៀវភៅ បេសកកម្មគ្រប់ជ្រុងជ្រោយ លោកបណ្ឌិត ប៉ូល បេនឌ័រ-សាំយ៉ូអែល បានប្រាប់រឿងមួយចេញពីបទពិសោធន៍របស់គាត់នៅអាហ្វ្រិកខាងជើង បទពិសោធន៍នេះហើយគឺជាចំណងជើងសៀវភៅនេះ។

> *អ្នកដែលព្រះជាម្ចាស់បានអញ្ជើញឱ្យចូលរួមព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ និងការអភិវឌ្ឍសហគមន៍ដើម្បីធ្វើជាបន្ទាល់ដំណឹងល្អ បានយល់ថាតាមរយៈការធ្វើជាបន្ទាល់គឺជាការសិក្សា និងការរីកចម្រើនៈ ដំណើរជីវិតភាពជាសាវ័ក។ នេះគឺជាបទពិសោធន៍ដែលខ្ញុំ និងប្រពន្ធរបស់ខ្ញុំមានក្នុងអំឡុងពេលដែលយើងបានចំណាយពេលដប់ពីរឆ្នាំធ្វើការនៅអាហ្វ្រិក ខាងជើង នៅក្នុងការអភិវឌ្ឍសហគមន៍ និងការបង្កើតសហគមន៍ដែលដើរតាមព្រះយេស៊ូ។ មានរឿងមួយដែលខ្ញុំបាននឹកឃើញពេលគិតពីពេលនោះៈ*
>
> *ព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឱ្យធ្វើដំណើរចាកចេញពីទីក្រុង ទៅកាន់ខេត្តមួយដែលក្រុមរបស់យើងបានធ្វើការនៅទីនោះអស់រយៈពេលប្រាំឆ្នាំហើយ។ កាលពីពីរឆ្នាំចុងក្រោយ មានក្រុមអ្នកដើរតាមព្រះយេស៊ូតូចមួយបានធ្វើជាបន្ទាល់ដោយសារបានមើលឃើញពីជីវិតរបស់បុរសម្នាក់ដែលទទួលបានការផ្លាស់ប្រែ។ មានគេចាប់បានគាត់លួចប្រាក់ពីកន្លែងធ្វើការរបស់គាត់ ហើយចៅហ្វាយរបស់គាត់គឺជាក្រុមរបស់យើង បានអត់ទោសឱ្យគាត់ និងផ្ដល់ឱកាសឱ្យគាត់បានកែប្រែ។ ការឆ្លើយតបរបស់គាត់គឺគាត់សុំសៀវភៅរបស់យើង។ តើព្រះយេស៊ូជានរណាដែលអាចផ្លាស់ប្ដូរកិរិយាបទរបស់ចៅហ្វាយម្នាក់នេះខ្លាំងយ៉ាងនេះ ឱ្យខុសពីចៅហ្វាយផ្សេងៗទៀត? នៅពេលដំបូង ដោយសារគាត់បានជួបជាមួយព្រះគ្រិស្ត ទ្រង់បានផ្លាស់ប្រែគាត់ ប្រពន្ធរបស់គាត់ និងក្រុមគ្រួសាររបស់គាត់ ហើយបន្ទាប់មកបានសាយភាយដល់សហគមន៍ផ្សេងទៀត។ ប៉ុន្មានខែក្រោយមក ប៉ូលិសបានគិតថាមិនត្រូវឱ្យក្រុមនេះបន្តជំនឿទៀតទេ ទើបក្រុមនេះត្រូវបានបិទ។*

*បញ្ហាមិនចប់ត្រឹមនេះទេ។ នាយកតំបន់ផ្នែកសុខាភិបាល មិត្តជិតស្និតរបស់ខ្ញុំនៅក្នុងប្រទេសត្រូវបានគេចោទប្រកាន់។ "តើអ្នកបានសូកប៉ាន់គាត់អ្វីខ្លះទើបធ្វើឱ្យគាត់ផ្លាស់ប្តូរសាសនាបែបនេះ? អ្នកបានប្រព្រឹត្តិអំពើពុករលួយនៅក្នុងវប្បធម៌របស់យើង។" ភ្លាមៗនោះ ក្រសួងសុខាភិបាលបានដកកតម្រោងរបស់យើងចេញទាំងអស់ ដែលធ្វើឱ្យអនាគតស្ថាប័ននេះគ្មានស្ថេរភាព។ ពេលនោះហើយដែលខ្ញុំមិនដឹងថាគួរនិយាយអ្វីជាមួយអភិបាលខេត្ត ពេលទៅប្រជុំជាមួយគាត់។ ខ្ញុំបានដើរចូលទៅក្នុងការិយាល័យដ៏ធំរបស់គាត់ ហើយគាត់ក៏ស្វាគមន៍ខ្ញុំ។ ខ្ញុំចាប់ផ្តើមដោយនិយាយថា "សូមគោរពឯកឧត្តម លោកបានដឹងហើយថាយើងខ្ញុំគឺជាក្រុមគ្រិស្តបរិស័ទដែលទទួលការគាំទ្រពីក្រុមជំនុំ អ្វីដែលយើងធ្វើនោះគឺធ្វើប្រកបដោយវិជ្ជាជីវៈ បម្រើដោយមានសុច្ចរិតភាព។*

*អ្វីដែលជំរុញយើងឱ្យធ្វើការងារប្រកបដោយភាពល្អប្រសើរនោះ គឺមកពីបទពិសោធន៍នៃសេចក្តីស្រឡាញ់ដែលយើងទទួលបានពីព្រះជាម្ចាស់។ នេះមានន័យថា បើមាននរណាម្នាក់សួរយើងអំពីជំនឿរបស់យើង យើងត្រូវតែចែកចាយអំពីសេចក្តីស្រឡាញ់នោះ ព្រោះយើងទទួលបានសេចក្តីស្រឡាញ់នេះដោយឥតគិតថ្លៃ។ យើងពិតជាគោរពតាមការសម្រេចនោះបើជាចង់ឱ្យយើងនៅ ឬទៅ។ យ៉ាងណាមិញ លោកមិនអាចបញ្ឈប់យើងចេញពីជំនឿរបស់យើងនោះទេ ដោយសារនេះគឺជាលក្ខណៈរបស់យើងដែលជំរុញយើងឱ្យធ្វើកិច្ចការប្រកបដោយភាពល្អប្រសើរ។ ពេលនោះ ឯកឧត្តមបានចាប់ដៃខ្ញុំ ហើយសុំយើងឱ្យបន្តនៅក្នុងខេត្តរបស់ពួកគេ។*

បន្ទាប់មកលោកបណ្ឌិត បេនឌ័រ-សាំម៉ូអែល បាននិយាយថា យើងគឺជា "មនុស្សពេញលក្ខណៈ ឬមិនពេញលក្ខណៈ" គឺតាមរយៈការថ្វាយសិរីរុងរឿងដល់ដំណឹងល្អ។

សូមគិតត្រលប់ទៅវិញអំពីការពិភាក្សារបស់យើង តាមរយៈវគ្គបណ្តុះបណ្តាលនេះ តើការធ្វើជាមនុស្សពេញលក្ខណៈមានន័យយ៉ាងដូចម្តេច? តើពាក្យថា បេសកកម្មគ្រប់ជ្រុងជ្រោយ មានន័យយ៉ាងដូចម្តេចចំពោះអ្នក?

ចម្លើយរបស់អ្នក

✓

✓

✓

តើ គំនិតនៃការបង្ហាញ និងការពន្យល់អំពីដំណឹងល្អដាក់បញ្ចូលគ្នាដោយរបៀបណា?

ចម្លើយរបស់អ្នក

✓

✓

✓

## ការអនុវត្តមកលើខ្លួនអ្នកផ្ទាល់

5.សូមគិតអំពីសំណួរទាំងនេះដើម្បីសិក្សាបន្ថែមឬចែក ចាយសំណួរទាំងនេះជាមួយក្រុមរបស់អ្នក និងអ្នកដឹកនាំនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។

- តើការសិក្សានេះបានផ្លាស់ប្ដូរអ្នកអ្វីខ្លះ?
- តើអ្នករៀនបានពីការពិត និងព័ត៌មានអ្វីខ្លះ?
- តើមានសំណួរណាខ្លះដែលអ្នកមិនទាន់មានចម្លើយ?
- តើមានជំនាញណាដែលអ្នកគិតថាអ្នកត្រូវតែរីកចម្រើនដែរឬទេ?
- តើអ្នកគិតថាព្រះជាម្ចាស់ចង់ប្រើប្រាស់អ្នកឱ្យអនុវត្តអ្វីខ្លះ? ក្រុមរបស់អ្នក?
- តើអ្នកនឹងអនុវត្តអ្វីដែលបានរៀនយ៉ាងដូចម្ដេច?

## សូមអរគុណដែលបានចូលរួម!

សូមអរគុណច្រើនដែលបានចូលរួមនៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ។
យើងពិតជាខិតខំដើម្បីបង្កើតមេរៀននេះ—
ហើយពិតជាសូមអរគុណដែលបានខិតខំប្រឹងប្រែងសិក្សាពីមេរៀនដែលមានក្នុងសៀវភៅនេះ។

យើងពិតជាចង់ដឹងថាតើសៀវភៅនេះបានផ្លាស់ប្ដូរអ្នកអ្វីខ្លះ
ព្រមទាំងចង់ដឹងថាអ្នកនឹងអនុវត្តអ្វីដែលបានរៀនយ៉ាងដូចម្ដេច?
យើងក៏សូមស្វាគមន៍រាល់មតិយោបល់ដើម្បីធ្វើឱ្យសៀវភៅនេះកាន់តែប្រសើរឡើង។

ចុងក្រោយ សូមមេត្តាអានសៀវភៅ បេសកកម្មគ្រប់ជ្រុងជ្រោយ ដែលបានបោះពុម្ពផ្សាយដោយ Regnum នៅក្នុងឆ្នាំ២០២០ និងបានកែសម្រួលដោយលោក ដាវីដ ហ្គ្រីនលី លោក ម៉ាក ហ្គាលភីន និងលោក ប៉ូល  បេនឌ័រ-សាំម៉ូអែល។ អ្នកអាចស្វែងរកសៀវភៅនេះបាននៅក្នុងប្រទេសអង់គ្លេស និងតាមរយៈបណ្ណាគារអនឡាញ សូមចូលទៅកាន់គេហទំព័រ https://www.regnumbooks.net/, www.kobo.com; Amazon, ដើម្បីទទួលបានកំណែជាសៀវភៅអេឡិចត្រូនិច។

ក្រុមសរសេរសៀវភៅ ការស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ
Tinashe Mafuta, Sally Ababa, Andrea Vogt, និង David Greenlee

ខែកក្កដា ឆ្នាំ២០២៥។

***ការអនុវត្ត ការស្វែងយល់អំពីបេសកកម្មគ្រប់ជ្រុងជ្រោយ***

យើងបានសិក្សាអំពីបេសកកម្មគ្រប់ជ្រុងជ្រោយ  ដែលជាផ្នត់គំនិតនៃការមិនបែងចែកការបង្ហាញចេញពីការពន្យល់អំពីដំណឹងល្អ។
ពេលដែលយើងមកដល់ចុងបញ្ចប់នៃការសិក្សានេះ សូមចាប់ផ្តើមគិតអំពីសំណួរទាំងនេះ ហើយសរសេរចម្លើយរបស់អ្នកចូល។

គំនិតទាំងនេះ គឺដើម្បីឆ្លុះបញ្ចាំងមកលើខ្លួនរបស់អ្នក ការសម្រេចចិត្ត និងការអនុវត្តរបស់អ្នក។ ចម្លើយល្អៗ

គឺជាចម្លើយដែលអាចជួយអ្នកឱ្យអនុវត្តអ្វីដែលអ្នកបានសិក្សារៀនសូត្រ។
អ្នកមិនចាំបាច់ចែករំលែកចម្លើយជាមួយអ្នកដទៃនោះទេ យ៉ាងណាមិញ

- សូមគិតពេលវេលា និងរបៀបដែលអ្នកអាចចែករំលែកខ្លះជាមួយក្រុម ឬសហការីរបស់អ្នកបាននៅពេលសមស្រប
- ម្យ៉ាងទៀត នៅពេលដែលយើងមកជួបគ្នានៅក្នុងមេរៀនទី១១ យើងនឹងផ្តល់ឱកាសឱ្យអ្នកចែកចាយពីគំនិតរបស់អ្នកជាមួយក្រុម។

សូមឱ្យចម្លើយរបស់អ្នកសម្រាប់សំណួរទី១-៤
ជួយអ្នកឱ្យបង្កើតផែនការចម្បងក្នុងការអនុវត្តសកម្មភាព ស្របពេលដែលអ្នកនឹងឆ្លើយសំណួរទី៥-៦។

ពេលដែលយើងបន្តដំណើរទៅមុខជាមួយគ្នា សូមចាំថា នឹងមានអ្នកដែលអាចជួយអ្នកបានរួមបញ្ចូលទាំងគ្រូបង្គោលផងដែរ។ សាលី អាបាបា ដែលជាជំនួយការអ្នកដឹកនាំព័ន្ធកិច្ចកាតាលីទិកមានបទពិសោធន៍ច្រើនណាស់ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សហគមន៍ គាត់ និងលោក David Greenlee ដែលជាអ្នកបង្កើតមេរៀននេះ រីករាយក្នុងការជួយតាមតែអាចធ្វើទៅបាន។

1. តើមេរៀននេះ បានផ្លាស់ប្តូរអ្នកអ្វីខ្លះ?

   ចម្លើយរបស់អ្នក
   ✓
   ✓
   ✓
   ✓

2. តើអ្នកបានរៀនពីរឿងពិត និងទទួលបានព័ត៌មានអ្វីខ្លះ?

   ចម្លើយរបស់អ្នក
   ✓
   ✓
   ✓
   ✓

3. តើនៅមានសំណួរណាខ្លះដែលអ្នកមិនទាន់ទទួលបានចម្លើយ?

   ចម្លើយរបស់អ្នក
   ✓
   ✓
   ✓
   ✓

4. តើអ្នកគិតថាមានជំនាញណាខ្លះដែលអ្នកគួរតែអភិវឌ្ឍន៍?

ចម្លើយរបស់អ្នក

✓
✓
✓
✓

5. តើអ្នកគិតថាព្រះជាម្ចាស់ចង់ឱ្យអ្នកអនុវត្តអ្វីខ្លះ? ក្រុមរបស់អ្នក?

ចម្លើយរបស់អ្នក

✓
✓
✓
✓

6. តើអ្នកនឹងអនុវត្តដោយរបៀបណា?

ចម្លើយរបស់អ្នក

✓
✓
✓
✓

